ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 03-May-2013, 13:05
CMS/CFO: Sann Rada

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី
# ជំនុំជម្រះក្តីនៅដំណាក់កាលដំបូង
# សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៣**

**ម៉ោង ០៩: ០៦នាទី**

**សវនាការលើកទី១៧២**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍ *(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ *(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង) *(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ម៉ាតេអូ គ្រីប៉ា *(Mr.Matteo CRIPPA)*

លោក ឌុច ផារី

លោក ដាវ អានសាន

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក ឃីត រេយ៍ន័រ *(Mr.RAYNOR Keith)*

កញ្ញា សុង ផវ័ន្ត

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក វ៉ិចទ័រ កូប៉េ *(Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ *(Ms. Anta GUISSE)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត

*(Ms. Elisabeth SIMONNEAU-FORT)*

លោក សំ សុគង់

លោក ឡេង ជុនធី

លោក វ៉េន ពៅ

លោកស្រី ជេត វណ្ណលី

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោកស្រី ស្វ សុទ្ធាវី

**បញ្ជីឈ្មោះអ្នកនិយាយ៖**

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍ | អង់គ្លេស |
| លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត | បារាំង |
| លោក ពេជ អង្គ | ខ្មែរ |
| លោក វ៉ែន ពៅ | ខ្មែរ |
| លោក គង់ សំអុន | ខ្មែរ |
| លោក ឃីត រេយ៍ន័រ | អង់គ្លេស |
| លោក វ៉ិចទ័រ កូប៉េ | អង់គ្លេស |
| លោក សុន អរុណ | ខ្មែរ |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| កញ្ញា សុង ឆវ័ន្ត | ខ្មែរ |
| លោក ស សារិន (TCCP-186) | ខ្មែរ |
| លោក អ៊ុំង ឆាត់ (TCW-752) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅដើមបណ្តឹងរដ្ឋប្បវេណី៖ លោក ស សារិន** (TCCP-186)


សួរដោយប្រធានអង្គជំនុំ ផ្តើមពី ....................................ទំព័រ ២

សួរដោយលោក វ៉ែន ពៅ ផ្តើមពី ....................................ទំព័រ ៤

សួរដោយ ពេជ អង្គ ផ្តើមពី ....................................ទំព័រ ២៥

សួរដោយលោក ឃីត រេយ៍ន័រ ផ្តើមពី....................................ទំព័រ ២៨


**ការសួរសំណួរទៅសាក្សី៖ លោក អ៊ុំ ឆាត់** (TCW-752)


សួរដោយប្រធានអង្គជំនុំ ផ្តើមពី ....................................ទំព័រ ៥២

សួរដោយកញ្ញា សុង ឆវ័ន្ត ផ្តើមពី ....................................ទំព័រ ៥៥

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០៦:៣៣]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ តាមកាលវិភាគដែលបានគ្រោងទុកកិច្ចដំណើរការសវនាការថ្ងៃនេះ អង្គជំនុំជម្រះធ្វើសវនាការស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណីដែលមានរហស្សនាម TCCP-186។ ហើយដើមបណ្តឹងរដ្ឋប្បវេណីរូបនេះនឹងតាំងសំណួរដេញដោលដោយក្រុមសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីមុនភាគីដទៃទៀតនៃរឿងក្តី។ ហើយភាគីទាំងសងខាងមានរយៈពេលមួយ -- កន្លះថ្ងៃក្នុងការសួរដេញដោលនេះ គឺដើមបណ្តឹងរដ្ឋប្បវេណី រួមនឹងសហព្រះរាជអាជ្ញាគឺមានរយៈពេលកន្លះថ្ងៃ ហើយនិងមេធាវីការពារក្តីពីរក្រុមមានពេលវេលាកន្លះថ្ងៃក្នុងការសួរដើមបណ្តឹងរដ្ឋប្បវេណី ស សារិន។

លោក ឌុច ផារី ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន និងអវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

[០៩:០៧:៥៨]

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន! សម្រាប់សវនាការនៅថ្ងៃនេះ គ្រប់ភាគីទាំងអស់នៃរឿងក្តីនេះមានវត្តមាន។ សូមកត់សម្គាល់ថាលោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនដែលនៅពីខាងក្រោមបន្ទប់សវនាការនេះ តាមសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដោយមូលហេតុបញ្ហាសុខភាព។ តាមកាលវិភាគបុគ្គលដែលត្រូវមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះថ្ងៃនេះ គឺដើមបណ្តឹងរដ្ឋប្បវេណី ដែលមានរហស្សនាម TCCP-186។ ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះមានវត្តមាននៅក្នុងបន្ទប់រង់ចាំៗការកោះហៅពីអង្គជំនុំជម្រះ។

នៅក្នុងសវនាការថ្ងៃនេះ មានសាក្សីបម្រុងមួយរូបគឺសាក្សីដែលមានរហស្សនាម TCCP-752។ សាក្សីរូបនេះ បានធ្វើសម្បថនៅចំពោះមុខរូបលោកតាដំបងដែកនៅព្រឹកនេះរួចហើយ។ សាក្សីបានបញ្ជាក់ថា តាមសមត្ថភាពដែលគាត់អាចដឹងគឺគាត់មិនមានជាប់ចំណងញាតិលោហិត ឬញាតិពន្ធជាមួយ

នឹងជនជាប់ចោទទាំងពីររូប គឺលោក នួន ជា និង លោក ខៀវ សំផន ឬភាគីដើមបណ្ដឹងរដ្ឋប្បវេណីណាមួយដែលត្រូវបានទទួលស្គាល់នៅក្នុងរឿងក្ដីនេះនោះទេ។ សាក្សីរូបនេះមានមេធាវីប្រឹក្សាឈ្មោះ មឿន សុវណ្ណ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អរគុណ។ មន្ត្រីរដ្ឋបាលតុលាការអញ្ជើញដើមបណ្ដឹងរដឋប្បវេណី ចូលមកកាន់កន្លែងផ្ដល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការ!

*(ដើមបណ្ដឹងរដ្ឋប្បវេណីចូលក្នុងបន្ទប់សវនាការ)*

[០៩:១០:៥១]

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** បាទ ជម្រាបសួរដើមបណ្ដឹងរដ្ឋប្បវេណី។ តើលោកឈ្មោះអី?

**លោក ស សារិន៖**

**ឆ៖** សូមគោរព! ខ្ញុំឈ្មោះ ស សារិន។

**ស៖** បាទ អរគុណ។ ហើយលោក ស សារិន មុននឹងឆ្លើយលោកបង្អង់បន្តិចរង់ចាំរហូតដល់ក្បាលមីក្រូហ្វូនប្រតិបត្តិការដោយឱ្យភ្លើងសញ្ញាក្រហមនៅទីនោះ ឬក៏នៅប៊ូតុងខាងក្រោមនេះ លោកអាចមើលឃើញនៅពេលដែលមានសញ្ញាក្រហម ភ្លើងក្រហមបែបនេះមានន័យថាក្បាលមីក្រូហ្វូនហ្នឹងប្រតិបត្តិការហើយ។ លោកអាចនិយាយទៅប្រព័ន្ធសំឡេងរបស់លោកនឹងអាចផ្សព្វផ្សាយចែកផ្សាយដល់អ្នកចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធីនេះរួមទាំងសាធារណជន ជាពិសេស គឺអង្គភាពបកប្រែភាសាដើម្បីបកភាសាសម្ដីរបស់លោកទៅជាភាសាពីរទៀតគឺអង់គ្លេសនិងបារាំង។

តើលោកកើតនៅខែថ្ងៃឆ្នាំណា?

ម្ដងទៀត!

**ឆ៖** ខ្ញុំបាទ កើតនៅថ្ងៃអង្គារទី៧ ខែកក្កដា ឆ្នាំ១៩៥៧។

**ស៖** បាទ អរគុណលោក សារិន។ តើទីកន្លែងកំណើតរបស់លោកនៅទីកន្លែងណា?

**ឆ៖** ខ្ញុំមានស្រុកកំណើតនៅភូមិត្រពាំងក្រពើ ឃុំមោងរៀវ ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម។

**ស៖** អរគុណ។ ហើយចុះទីលំនៅសព្វថ្ងៃរបស់លោកតើលោករស់នៅទីកន្លែងណា?

**ធ៖** នៅក្រុមទី១ ផ្ទះលេខ ៤៩ ភូមិទី៥ សង្កាត់វាលវង់ ក្រុងកំពង់ចាម។

**ស៖** បាទ អរគុណ។ តើលោកសព្វថ្ងៃនេះប្រកបមុខរបររកស៊ីធ្វើអ្វី?

**ធ៖** ខ្ញុំ សព្វថ្ងៃហ្នឹងខ្ញុំចូលនិវត្តន៍ហើយ នៅផ្ទះទេ។

[០៩:១៣:២៣]

**ស៖** តើលោកអាចប្រាប់ដល់អង្គសវនាការបានទេ តើឪពុកបង្កើតរបស់លោកឈ្មោះអី ម្ដាយបង្កើតរបស់លោកឈ្មោះអី? ហើយប្រពន្ធរបស់លោកឈ្មោះអី? និងកូន -- លោកមានកូនប៉ុន្មាននាក់?

**ធ៖** ឪពុកខ្ញុំឈ្មោះ ស សេន (ស្លាប់)។ ម្ដាយខ្ញុំឈ្មោះ សាន សារឿន (ស្លាប់)។ ខ្ញុំមានកូនទាំងអស់ប្រាំនាក់ ស្រីបី ប្រុសពីរ។

**ស៖** ចុះប្រពន្ធរបស់លោកគាត់ឈ្មោះអី?

**ធ៖** ប្រពន្ធខ្ញុំឈ្មោះ ម៉ម សារ៉ុន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយអំមិញអង្គជំនុំជម្រះបានជម្រាបជូនហើយថាតំណាងសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីគឺអង្គជំនុំជម្រះផ្ដល់វេទិកាទៅ ក្នុងការធ្វើសក្ខីកម្ម ដើមបណ្ដឹងរដ្ឋប្បវេណីមុនភាគីដទៃទៀតនៃរឿងក្ដី។ ហើយមុននឹងផ្ដល់វេទិកាអង្គជំនុំជម្រះសូមជម្រាប រំឭកនូវសិទ្ធិរបស់លោក ស សារិន ក្នុងនាមលោកជាដើមបណ្ដឹងរដ្ឋប្បវេណីដែលបានចូលរួមនៅក្នុងកិច្ចដំណើរការសវនាការផ្ដល់សក្ខីកម្មនូវចំពោះមុខអង្គជំនុំជម្រះនៅពេលនេះ លោកអាចថ្លែងរៀបរាប់ដល់អង្គជំនុំជម្រះអំពីស្ថានភាពទុក្ខវេទនា ព្យសនកម្ម ដែលកើតចេញ កើតមានចំពោះលោកដែលជាអាទិ៍ គឺខូចខាតខាងផ្លូវចិត្ត ផ្លូវកាយ និងសម្ភារៈ ហើយព្យសនកម្មផ្ទាល់ដែលជាបច្ច័យកើតឡើងដោយផ្ទាល់ពីបទឧក្រិដ្ឋ និងដែលបានកើតពិតប្រាកដរហូតដល់សព្វថ្ងៃនេះ ដែលពាក់ព័ន្ធទៅនឹងបទចោទប្រកាន់លើជនជាប់ចោទទាំងពីររូប ដែលបានប៉ះពាល់ចំពោះលោកក្នុងអំឡុងពេលរបបកម្ពុជាប្រជាធិបតេយ្យ ចាប់ពីថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ រហូតដល់ថ្ងៃ០៦ មករា ឆ្នាំ៧៩។

[០៩:១៥:៣៨]

នេះយើងប្រាប់ជម្រាបសិទ្ធិរបស់លោក គឺអង្គជំនុំជម្រះនឹងផ្ដល់សិទ្ធិនេះដល់លោកនៅនាទីចុងក្រោយនៃផ្ដល់សក្ខីកម្មរបស់លោក។ បានន័យថា មុននឹងបញ្ចប់អង្គជំនុំជម្រះនឹងផ្ដល់ឱកាសចុងក្រោយសម្រាប់លោកធ្វើសេចក្ដីថ្លែងរៀបរាប់អំពីទុក្ខវេទនានេះ។ សូមលោកជ្រាប។

បាទជាបន្តអង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅក្រុសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីមានឱកាសក្នុងនៅការតាំងសំណួរដេញដោលចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។ សូមអញ្ជើញ!

**លោក ពេជ អង្គ៖**

សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម និងអង្គសវនាការ។ ជាបឋមគឺលោក វ៉ែន ពៅ ដែលជាមេធាវីរបស់លោក ស សារិន និងសួរសំណួរ។ បន្ទាប់មក ខ្ញុំនឹងបន្តសំណួរបន្ទាប់ពីលោក វ៉ែន ពៅ មុននឹងផ្តល់វេទិកាបន្តទៀតជូនទៅខាងតំណាងសហព្រះរាជអាជ្ញា។ សូមលោកប្រធានអនុញ្ញាត។

[០៩:១៦:៣០]

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញ!

**លោក វ៉ែន ពៅ៖**

បាទ សូមគោរពប្រធាន សូមគោរពលោក លោកស្រីចៅក្រមជាតិ និងអន្តរជាតិ សូមគោរពតំណាងសហព្រះរាជអាជ្ញា និងសូមគោរពអង្គសវនាការទាំងមូល។

**ការតាំងសំណួរដោយសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

**សួរដោយលោក វ៉ែន ពៅ៖**

**ស៖** ជម្រាបសួរពូ ស សារិន! ខ្ញុំបាទឈ្មោះ វ៉ែន ពៅ ខ្ញុំជាមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី។ ខ្ញុំចង់ឲ្យពូធ្វើការបញ្ជាក់ ក៏ដូចជាបំភ្លឺ និងបង្ហាញអំពីអ្វីដែលពូបានជួបប្រទះ ជាពិសេសបទពិសោធន៍របស់ពូនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដែលពាក់ព័ន្ធទៅនឹងការចូលរៀនវគ្គរៀនសូត្រអប់រំនយោបាយជាមួយមេដឹកនាំកំពូលនៅសម័យនោះ។

[០៩:១៧:១៥]

ហើយឯកសារដែលខ្ញុំបាទនឹងត្រូវលើកយកមកសួរពូ គឺភាគច្រើនទៅនឹងបទសម្ភាសន៍របស់ពូដែលបានធ្វើឡើងជាមួយនឹងមជ្ឈមណ្ឌលឯកសារកម្ពុជា កាលពីថ្ងៃទី០៥, ០៦ ខែឧសភា ឆ្នាំ២០០៩ ដែលមានលេខឯកសារ D230/1.1.874c។ លោកប្រធានខ្ញុំសូមអនុញ្ញាតលោកប្រធានផ្តល់ឯកសារនេះជូនគាត់ដើម្បីឲ្យគាត់បានមើលបាទ។

**ប្រធានអង្គជំនុំ៖**

ឯកសារនេះទំនងជាគាត់បានដឹងជាមុន បានធ្លាប់បានស្គាល់ឯកសារនេះទេ តាមបទពិសោធន៍នៅក្នុងការរៀបចំសវនាការកន្លងនេះ ឯកសារដែលរៀបចំឡើងដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ភាគីដែលពាក់ព័ន្ធនឹងផ្ដល់ចម្លើយមិនដែលបានឃើញនូវឯកសារនោះទេ។ ពីព្រោះការធ្វើសម្ភាសនោះគឺដោយថតជាសំឡេង ហើយភ្នាក់ងារដែលស៊ើបអង្កេតហ្នឹងយកខ្សែអាត់សំឡេងហ្នឹងទៅរៀបចំ។ ហើយប្រសិនបើភាគី មុខគោលដៅដែលត្រូវសួរហ្នឹងគាត់អត់ដែលស្គាល់ឯកសារទេ ការបង្ហាញវានាំឱ្យខាតពេល។

[០៩:១៨:២៤]

លោកអាចដកស្រង់នូវខ្លឹមសារសួរបាន ប៉ុន្តែមិនឱ្យដកស្រង់អ៊ីចឹងទេ គឺដកស្រង់លើខ្លឹមសារជាទូទៅអាចសួរដេញដោលបាន ដោយផ្អែកលើមូលដ្ឋាននោះ ប៉ុន្តែមិនគប្បីដាក់បង្ហាញទេ ព្រោះដាក់បង្ហាញទំនងជាលោកមានភស្តុតាងអ្វី ដែលបញ្ជាក់ថាគាត់បានឃើញឯកសារនេះពីមុនដែរឬទេ?

**សួរដោយលោក វ៉េន ពៅ៖**

បាទ លោកប្រធានខ្ញុំអាចសួរគាត់ថា គាត់មានអាន ឬឃើញឯកសារនេះបានទេ ប្រហែលជា--

**ស៖** តើពូអាចមានឃើញឯកសារបទសម្ភាសន៍ពូនេះទេបាទ?

**ប្រធានអង្គជំនុំ៖**

កុំអាលៗទាន់!

**លោក ស សារិន៖**

**ឆ៖** ខ្ញុំធ្លាប់បានឃើញឯកសារហ្នឹង ដែលឌី.ស៊ី.ខេម គេចម្លងពីកាសែតហ្នឹង គេជូនមកខ្ញុំមួយច្បាប់ដែរ។

[០៩:១៩:២៥]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត! មន្ត្រីរដ្ឋបាលតុលាការទទួលយលឯកសារជាក្រដាសពីលោកតំណាងសហមេធាវីនាំមុខដើម្បីជូនមកដើមបណ្ដឹងរដ្ឋប្បវេណីពិនិត្យ!

*(មន្ត្រីតុលាការយកឯកសារជូនសាក្សី)*

**សួរដោយលោក វ៉េន ពៅ៖**

**ស៖** បាទ សូមអរគុណ។ សំណួររបស់ខ្ញុំជាដំបូងនេះ គឺពាក់ព័ន្ធទៅនឹងប្រវត្តិរបស់លោកដែលចូលចម្រើក្នុងចលនាបដិវត្តន៍។ តើពូចូលចលនាបដិវត្តន៍នៅពេលណា ហើយនៅឆ្នាំណាដែរបាទ?

[០៩:២០:០៩]

**ប្រធានអង្គជំនុំ៖**

លោកៗ សារិន មិនបាច់ប៉ះពាល់ទេ។ អាហ្នឹងគឺមានខាងភ្នាក់ងារសម្របសម្រួលហើយ ព្រោះមូលហេតុគឺបង្អង់បន្តិច ពីព្រោះចង់អ្នកបកប្រែហ្នឹងមានការបកប្រែនូវសំណួរឱ្យបានត្រឹមត្រូវ រួចមានពេលវេលាឃ្លាតបន្តិច ទើបចប់ ទើបលោកអាចឆ្លើយបាន។ អ៊ីចឹងហើយមានការឃ្លាតគ្នាបន្តិច។ មិនមែនដូចយើងឆ្លើយឆ្លងផ្ទាល់ភ្លាមៗបានទេ។

**លោក ស សារិន៖**

**ឆ៖** បាទ លោកមេធាវី។ ខ្ញុំចូលបម្រើក្នុងចលនាបដិវត្តន៍នេះ តាំងពីខ្ញុំមានអាយុ១៣ឆ្នាំមកម្ល៉េះ គឺចូលដំបូងនៅការផ្សព្វផ្សាយការងាររណសិរ្ស និងផ្សព្វផ្សាយវប្បធម៌ សិល្បៈបដិវត្តន៍។ ក៏ប៉ុន្តែអត់ទាន់ហៅថាបែកពីឪពុកម្ដាយ គឺថាចូលដោយប្រយោលទេដំបូងនោះ។ ហើយដល់ចូលពេញសិទ្ធិហ្នឹង គឺខ្ញុំនៅចាំ នៅពេលដែលសហរដ្ឋអាមេរិកដកសង្គ្រាមអាកាសចេញហ្នឹង គឺនៅខែ៨ ខែសីហា ថ្ងៃទី១៥ហ្នឹង ថ្ងៃហ្នឹងហើយ ដែលជាខ្ញុំចូលបដិវត្តន៍ពេញសិទ្ធិ ចូលបម្រើក្នុងជួរកងទ័ព។

[០៩:២១:៣១]

**ស៖** ឆ្នាំណាដែរបាទ?

**ឆ៖** ឆ្នាំ១៩៧៣ បាទ។

**ស៖** តើការចូលចលនាបដិវត្តន៍របស់ពូនោះ ដំបូងនោះអ្នកណាអ្នកដែលនាំឱ្យពូចូល ហើយហេតុអ្វីបានពូចូលចលនានេះ?

**ប្រធានអង្គជំនុំ៖**

មិន-- ភ្លេច។

**លោក ស សារិន៖**

**ឆ៖** អ្នកដែលនាំចូលបដិវត្តន៍ហ្នឹង គឺដំបូងឡើយមានឈ្មោះបង ទន់ គ្រី គាត់ជាមេបញ្ជាការយោធាតំបន់២១ហ្នឹង និងបងគីន ជាប្រធានភូមិ ត្រូវជាបងជីដូនមួយខ្ញុំហ្នឹង និងមេឃុំឈ្មោះ ចិន្តា ហៅ

តេក ម្នាក់ទៀតដែលគាត់ណែនាំឲ្យចូលបម្រើកងទ័ពដែលយុទ្ធនាការមួយវ៉ៃផ្តាច់ទីក្រុងភ្នំពេញ គឺប្រមែប្រមូលយុវជនស្ម័គ្រចិត្តទាំងអស់នៅក្នុងឃុំហ្នឹងបាន ១៣០នាក់ គឺស្មើនឹង លើសមួយគរបន្តិចផងសម័យនុំង ហើយរៀនក្បួនយុទ្ធសាស្ត្រហ្នឹងដើម្បីទៅប្រយុទ្ធជាមួយកងទ័ព លន់ នល់ នោះសម័យហ្នឹង។

[០៩:២២:៥៤]

**សះ** បាទ ពូបានបញ្ជាក់ហើយថា ពូបានចូលដំបូង គឺចូលក្នុងក្រុមសិល្បៈ ខ្ញុំចង់សួរឲ្យពូមេត្តាបញ្ជាក់ថែមទៀត ថាតើការសម្តែងក្រុមសិល្បៈពូហ្នឹង គេអប់រំអំពីអ្វីខ្លះទៅ ពូមាននៅនឹកឃើញចាំទេបាទ អត្ថន័យនៃការអប់រំក្រុមសិល្បៈពូនោះ?

**ឆះ** ក្រុមសិល្បៈសម័យនុំងហ្នឹង គឺនិយាយរួមមាគ៌ានយោបាយរបស់រណសិរ្សហ្នឹង គឺធ្វើទៅតាមតែបទចម្រៀង តាមខ្ញុំវិភាគមើល និងដូចថាការផ្សព្វផ្សាយការងាររណសិរ្សហ្នឹង គេប្រាប់បងប្អូនអ្នកភូមិអ៊ីចឹងថាមកមើលសិល្បៈ តែយើងឆ្លៀតឱកាសហ្នឹងដើម្បីផ្សព្វផ្សាយនូវមាគ៌ានយោបាយរណសិរ្សហ្នឹង។ គឺខ្លួនខ្ញុំអ្នកផ្សព្វផ្សាយផ្ទាល់ គឺមានកូនសៀវភៅមួយតូច ធំជាងបាទដៃហ្នឹងបន្តិច គឺមុននឹងសិល្បៈសម្តែង គឺឲ្យខ្ញុំហ្នឹងឡើងអានពីនយោបាយរណសិរ្ស ព្រោះមានតា សាឡាត់ និងតាម៉ក់ – ជី – ហ្នឹងគាត់ជា គេហៅចៅសង្កាត់ កាលហ្នឹងគេមិនមែនហៅមេឃុំទេ។ មេឃុំគេថាពាក្យសក្តិភូមិ។ គាត់ឲ្យខ្ញុំ អ្នកធំៗនិយាយឡើងសម្តែងអី គេអត់សូវចាប់អារម្មណ៍មើលកាលហ្នឹង។ ហើយដល់ខ្ញុំតូចជាងគេឡើងនិយាយ ឡើងអានទៅ ប្រជាជនគាត់ចូលចិត្តមកស្តាប់។ ដល់អ៊ីចឹង គាត់តែងតែឲ្យគាត់អាន ខ្ញុំនៅចាំពាក្យពេចន៍ហ្នឹងទាល់រាល់ថ្ងៃហ្នឹង។

[០៩:២៤:៤៦]

ដំបូងនោះគឺ “ថារណសិរ្សរួបរួមជាតិកម្ពុជា រួបរួមរាល់អង្គការ សាសនា ព្រះមហាក្សត្ររាជវង្សានុវង្ស ដោយមិនប្រកាន់ពូជសាសន៍ និងព៌ណសម្បុរឡើយ”។ បាទ រួបរួមរាល់អង្គការសាសនាព្រះមហាក្សត្រដោយឥតប្រកាន់ទេ គឺរណសិរ្ស -- ការងាររណសិរ្សយើងហ្នឹង។ ហើយបន្ទាប់ពីហ្នឹងទៅបងៗមួយចំនួនទៀត គាត់ផ្សព្វផ្សាយអំពីប្រវត្តិតស៊ូរបស់ចលនាបដិវត្តន៍ តាំងពីអាចារ្យស្វា, ពោធិ៍កំបោរ, អាចារ្យហែម ចៀវ អីជាដើម...។ល។ អ៊ីចឹងទៅហូរហែ។ ដល់បន្តបន្ទាប់មកបានគេច្រៀងជាសិល្បៈអ៊ីចឹងទៅ ដើម្បីកំដរបងប្អូនមកៗចាំស្តាប់សិល្បៈហ្នឹង ក៏ប៉ុន្តែឆ្លៀតឱកាសហ្នឹងដើម្បីផ្សព្វផ្សាយការងាររណសិរ្សហ្នឹង ដែលជាមានសម្តេចព្រះនរោត្តមជាប្រធាន មានលោក ខៀវ សំផន អីជាអនុប្រធានរណសិរ្ស ហើយនិងសម្តេច ប៉ែន នុត អីនុំង កាលនុំងខ្ញុំនៅចាំបានអ៊ីចឹង មាន ហ៊ូ យន់, ហ៊ូ នឹម

អីហ្នឹង។ ការងាររណសិរ្ស ការផ្សព្វផ្សាយពីដំបូងឡើយនៅចុងឆ្នាំ៧១ ដើមឆ្នាំ៧២ហ្នឹង គឺខ្ញុំត្រូវលោកចៅសង្កាត់ហ្នឹងនាំដើរផ្សព្វផ្សាយរហូតនៅក្នុងឃុំរបស់ខ្ញុំហ្នឹង។ អាហ្នឹងខ្ញុំគ្រាន់តែជូនលោកមេធាវី ដើម្បីឲ្យជ្រាបអំពីការផ្សព្វផ្សាយមាគ៌ានយោបាយហ្នឹង តែប៉ុណ្ណឹងឯង។

**ស៖** បាទ សូមអរគុណ។ តើពូធ្លាប់បានអាន ឬធ្លាប់ឃើញ ឬស្គាល់ទស្សនាវដ្ដីទង់បដិវត្តទេនៅមុនឆ្នាំ១៩៧៥បាទ?

**ឆ៖** ធ្លាប់បានឃើញទង់ទស្សនាវដ្ដីទង់បដិវត្តហ្នឹង ប៉ុន្តែទាល់តែថ្នាក់ដឹកនាំបានគេមាន ខ្ញុំគ្រាន់តែមើល អត់ដែលបានមើលអីច្រើន គ្រាន់តែឃើញតែសំបកទង់បដិវត្ត តែសៀវភៅហ្នឹងគេសរសេរដៃទេ មិនមែនបោះពុម្ពដូចយើងរាល់ថ្ងៃទេ សៀវភៅសរសេរដៃ រួចគេអូស។ សរសេរដៃហ្នឹងគេដូចថាមិនមែនជាអក្សរពុម្ព ជាលក្ខណៈអក្សរអូស តែមិនសូវជាមានរូបភាពស្អាតទេ ដែលបោះពុម្ពដោយរោងពុម្ពតំបន់២១ ខ្ញុំមើលអក្សរហ្នឹងឃើញក្រោមហ្នឹងអីចឹងទៀតណា។ បាទ ហើយមានឯកសារខ្លះមានទស្សនាវដ្ដីខ្លះ ក៏ដាក់អីចឹងដែរ ដាក់ "ពន្លឺបូព៌ា រោងពុម្ពតំបន់២១"។ ភាគច្រើនដែលជាគេយកមកផ្សព្វផ្សាយទៅតាមទឹកដីនៃតំបន់រំដោះ កាលហ្នឹងគេហៅ "ទឹកដីតំបន់រំដោះ"។

[០៩:២៨:០៥]

**ស៖** បាទ សូមអរគុណ។ សំណួររបស់ខ្ញុំជាបន្តទៀតនេះ ពាក់ព័ន្ធនឹងចំណុចមួយទៀតគឺនៅក្រោយ១៧ មេសា ឆ្នាំ១៩៧៥ ខ្ញុំចង់ឲ្យពូបញ្ជាក់ថា តើពូត្រូវបានគេឲ្យចូលមកទីក្រុងភ្នំពេញនោះនៅពេលណា បន្ទាប់ពី១៧ មេសា ៧៥? ហើយអ្នកណាអ្នកឲ្យពូចូល? ហើយពូបានធ្វើការងារអ្វីខ្លះនៅពេលនោះបាទ?

**ឆ៖** បើតាមប្រវត្តិរបស់ខ្ញុំហ្នឹងវែងឆ្ងាយណាស់ ទម្រាំបានមកដល់ភ្នំពេញហ្នឹង។ គឺក្រោយពីខ្ញុំចូលបដិវត្តន៍ ដាច់ពីម៉ែឪខ្ញុំមក គេឲ្យខ្ញុំរៀនយុទ្ធសាស្ត្រហ្នឹង៣ខែ រួចគេប្រមូលកងទ័ពទាំងអស់ហ្នឹងទៅប្រយុទ្ធនៅសមរភូមិខាងកើតទន្លេមេគង្គហ្នឹង។ តែដោយខ្សែកខ្លួនខ្ញុំហ្នឹងតូចជាងគេ មានគ្នាប្រហែលជាបីនាក់។ គេរែករកឃើញនៅកណ្ដាល គេដឹកដៃចេញអត់ឲ្យទៅ គេថា "មិត្តឯងតូចពេក មិនអាចទៅប្រយុទ្ធគ្នាបានទេ អីចឹងមិត្តឯងនៅខាងប្រមូលស្បៀង" រួចត្រូវបង ទន់ គ្រី គណៈមេបញ្ជាការយោធាតំបន់ហ្នឹង គាត់អត់ឲ្យយកទៅ គាត់ថា "ផ្ញើទុកមិត្តហ្នឹងនៅហ្នឹងឃុំហ្នឹងសិនហើយ ទុកឲ្យគាត់ប្រមូលស្បៀងនៅហ្នឹងសម្រាប់ផ្គត់ផ្គង់ខាងក្រុមខ្ញុំ"។ ដល់អីចឹងទៅខ្ញុំរស់នៅហ្នឹង គឺសម្រាប់ប្រមូលស្បៀងតាមមូលដ្ឋាន គឺមានបាយកញ្ចប់ និងអង្ករតស៊ូហ្នឹង គេហៅ "អង្ករក្ដាប់" ដើរប្រមូលតាមភូមិហ្នឹង ១ថ្ងៃមួយ

ភូមិបានប្រហែលជា៥០គីឡូដែរ រៀងរាល់ថ្ងៃ។ ភូមិប្រាំពីរប្រាំបីហ្នឹង បានបីបួនបាវដែរ សម្រាប់ឧបត្ថម្ភកងទ័ពហ្នឹង។ មានមាន់, មានទា, មានត្រី, មានសាច់, អំបិល, ផ្អក, ប្រហុក អីចឹងទៅ សម្រាប់កងទ័ព។ ដល់ទៅ ដាច់៧៥ទៅ បាយកញ្ចប់ហ្នឹង ខ្ញុំហ្នឹង លែងឲ្យកងទ័ពនៅសមរភូមិហ្នឹងវិញហើយ បង្វែរឲ្យមកខាងទាហាន លន់ នល់ វិញ ដែលគេក្រោយ ១៧មេសា ហ្នឹង ទាហាន លន់ នល់ ហ្នឹងត្រូវចុះចូលមកខាងកងទ័ពរំដោះហ្នឹងទាំងអស់។ គេយកមកដាក់នឹងវត្តមួយ នៅក្នុងឃុំខ្ញុំហ្នឹង ហៅថា វត្តមោងហ្នឹង។ ដូច្នេះ អង្ករ -- អ៎! បាយទាំងឡាយហ្នឹង គឺយកមកឧបត្ថម្ភខាងទាហានហ្នឹងវិញ។

[០៩:៣១:០៦]

ដល់ទៅក្រោយមកទៀត បានមានការជ្រើសរើសពីមជ្ឈិមទៅហ្នឹង មិនដឹងពី -- សម័យហ្នឹង គេនិយាយពីថ្នាក់លើ ប៉ុន្តែចលនាតស៊ូបដិវត្តន៍ហ្នឹង ប្រៀបបីដូចទឹកបាក់ទំនប់អីចឹង។ គឺថ្នាក់លើស្នើប៉ុន្មាន គឺឡើងទៅប៉ុណ្ណឹង។ ហើយវគ្គដំបូងនោះ តាមដែលខ្ញុំធ្លាប់ឃើញជាក់ស្តែងនៅក្នុងឃុំខ្ញុំហ្នឹង គឺគេហៅវគ្គអន្ទិត១។ ក្រោយពី៧៥មក គឺលោកសង្ឃទាំងអស់ត្រូវតែផ្សឹកជាដាច់ខាត។ មុន៧៥ហ្នឹង ការផ្សឹកព្រះសង្ឃហ្នឹង គឺផ្សឹកទៅដោយការឃោសនា។ ការឃោសនាយ៉ាងម៉េច? ខ្ញុំនៅចាំបងចម្រៀងមួយបទគឺចម្រៀងត្រុដិហ្នឹង គេធ្វើឲ្យមនុស្សដែលកងទ័ពបដិវត្ត យ៉ាងម៉េចបានក្លាហាន បានសម្បូរ ទោះបីស្លាប់ធ្វើពលិកម្មយ៉ាងម៉េច ក៏នៅតែសម្បូរកងទ័ព។ គឺសម័យនុ៎ង គឺដូចថា ធ្វើទៅតាមមាគ៌ានយោបាយ អប់រំផ្នែកអប់រំសិល្បៈហ្នឹង។ គ្រាន់តែចម្រៀងត្រុដិបទហ្នឹង មនុស្សចូលបម្រើកងទ័ពច្រើនណាស់ ហើយព្រះសង្ឃខ្លះក៏ត្រូវផ្សឹក ខ្លះ ប៉ុន្តែផ្សឹកពីដំបូងហ្នឹង ផ្សឹកដោយស្ម័គ្រចិត្តទេ ឥតមានអ្នកណាបង្ខំទេ ខ្ញុំនៅចងចាំទាំងអស់។ ហើយចម្រៀងហ្នឹងគឺគេវាយលុបបំបាត់នូវវណ្ណៈនាយទុន វណ្ណៈសក្តិភូមិ និងធ្វើឲ្យស្អប់ដល់និស្សិត ដល់បញ្ញវន្ត អ្នកណាដែលមានសញ្ញាប័ត្រហ្នឹង គេមិនចូលចិត្ត។ មិត្តនារីហ្នឹងគេមិនស្រឡាញ់ទេ ទាល់តែចូលបម្រើកងទ័ព ឬចុះជនបទ កែប្រែជីវភាពប្រជាជនអី បានគេស្រឡាញ់។ អាហ្នឹងក្នុងអត្ថន័យហ្នឹង បើខ្ញុំច្រៀងហ្នឹង វែងឆ្ងាយណាស់ អាហ្នឹងគ្រាន់តែខ្ញុំសង្ខេបខ្លីៗទៅចុះ។

[០៩:៣៣:៣៩]

បាទ បន្តបន្ទាប់ពីហ្នឹងទៀតទៅ ខ្ញុំនៅចាំ នៅក្នុងតំបន់២១ហ្នឹង មានស្រុកត្បូងឃ្មុំ ស្រុកពាមជីលាំង ស្រុកក្រូចឆ្មា ស្រុកឆ្លូង ស្រុកតំបែរ ស្រុកទឹកជ្រៅ ស្រុកត្រមូង ស្រុកមេមត់។ ហើយក្នុងតំបន់២១ហ្នឹង គឺគេផែនការគេឲ្យរើសយក១០០០នាក់។ រួចខ្ញុំឡើងពីឃុំហ្នឹងទៅ ទៅជួបគ្នានៅស្នាក់ការតំបន់គេហ្នឹង នៅក្នុងព្រៃ។ នៅក្នុងព្រៃ គេហៅទៅខាងជើងកណ្តុរជ្រុំ ខាងព្រំអណ្តោតអីចឹងមើលទៅ --

ក្អោត អណ្តោតហ្នឹងកាលហ្នឹង។ បានជុំគ្នាបាន១០០០នាក់ហ្នឹង បានឡើងមកសាលា ស២០០។ សាលា ស២០០ ហ្នឹង នៅជិតព្រៃវែង គេហៅវត្តស្វាយល្អៀតហ្នឹង។ ប្រមូលគ្នាហ្នឹង គិតទៅច្រើណាស់ ប៉ុន្តែតាមប្រសាសន៍លោក កន្លែងបញ្ជាការយោធាភូមិភាគ២០៣ហ្នឹង ឈ្មោះ សំណាង – កែវ សំណាង – កែវ -- មើល៍ កែវ ម៉ុន ហៅ សំណាង ហ្នឹង។ គាត់ ពេលគាត់បិទវគ្គហ្នឹង គាត់ប្រកាសថា ចំនួនគ្នា ៥០០០នាក់ មកភ្នំពេញហ្នឹង មករៀននៅសាលា ស២០០ហ្នឹង។ តំបន់ទាំងប្រាំនៃភូមិភាគបូព៌ាហ្នឹង មានតំបន់២០, ២១, ២២, ២៣, ២៤ ហ្នឹង។ មករៀននៅហ្នឹងទាំងអស់។ រៀននៅហ្នឹងប្រហែលជាកន្លះខែបានចប់ បានមកភ្នំពេញហ្នឹង។ មកភ្នំពេញហ្នឹង គេឲ្យដើរតែយប់ៗទៀត។ ដើរមកពីស្វាយរមៀតហ្នឹងដេកព្រៃវែង មកពីព្រៃវែងហ្នឹងដេកនៅពាមអាណាម មកនៅនុ៎ងដេកនៅឡូតដ្ឋ ចេញពីឡូតដ្ឋហ្នឹងដេកនៅច្បារអំពៅ។ ហើយនៅពេលនោះ ខ្ញុំមើលទៅទិដ្ឋភាពតាមដងផ្លូវតាំងពីព្រៃវែងមកអ្នកលឿងរហូតដល់ភ្នំពេញ គឺដើមឈើមួយណាក៏ខ្លោចដូចឲ្យង ងាប់អត់មានអីទេ។ ដោយ--

[០៩:៣៦:២៥]

**ស៖** ពូសូមទោស ខ្ញុំកាត់ពូបន្តិច។ តើពូអាចបញ្ជាក់ ឆ្នាំណាពេលដែលពូចូលមកភ្នំពេញនោះ នៅក្នុងខែណា ឆ្នាំណាដែរ ពូអាចបញ្ជាក់បានទេបាទ?

**ឆ៖** នៅប្រហែលជាខែ៩ ខែ១០ ហ្នឹងខែសន្ទូងបែកគុម្ពហ្នឹង កាលហ្នឹង ខ្ញុំចំណាំ។ ពេលឡើងទៅរៀន ដើរកាត់សន្ទូង វាលស្រែហ្នឹង ប្រហែលខែហ្នឹង ខែ៩ ខែ១០ហ្នឹង យូរឆ្នាំហើយ ខ្ញុំអាចភ្លេចថ្ងៃ ភ្លេចខែ ប៉ុន្តែគ្រាន់ចំណាំ--

**ស៖** ឆ្នាំ ពូឆ្នាំណាដែរ?

**ឆ៖** ឆ្នាំ ចុងឆ្នាំ៧៥ហើយអាហ្នឹង កាលហ្នឹង។ រួចដល់ទៅមក ខ្ញុំសង្កេតឃើញទិដ្ឋភាពតាមផ្លូវហ្នឹង គឺសមរភូមិក្តៅណាស់ តាំងពីព្រៃវែង បាណាម អ្នកលឿង រហូតដល់ឡដីឥដ្ឋ ហ្នឹងគឺថាដើមឈើបាក់រាបដល់ដី ផ្ទះថ្ម ផ្ទះសម្បែងអីៗគ្មានទេ។ ឲ្យតែជួបមនុស្សម្នាក់តាមផ្លូវក៏គ្មានដែរ ត្រូវធ្វើដំណើរមកយប់ទៀត។ រហូតមកដល់ភ្នំពេញក៏ស្ងាត់ជ្រងំ។ ដល់ភ្នំពេញសម្រាកនៅច្បារអំពៅហ្នឹងបាន១យប់ បានព្រលឹមឡើង គេឲ្យទ័ពទាំងអស់ដើរពីច្បារអំពៅហ្នឹងក្បាលថ្នល់ ចេញតាមវិមានឯករាជ្យហ្នឹងមកមុខវាំង។ មុខវាំងហ្នឹងមានឈ្មោះ តា ភុំ មានឈ្មោះបង ប៉ង់, ឈ្មោះតា ព្រំ, ឈ្មោះតា គី, ឈ្មោះបង រុយ, ឈ្មោះបង មៀល តាមខ្ញុំចាំអង្គាល់នុ៎ង ខ្ញុំអត់ចាំទេ ប៉ុន្តែគ្រាន់តែចំណាំតែមុខគាត់។ ដើរទៅ គេឲ្យទ័ពហ្នឹងដើរពីរជួរ គ្នា៥០០០នាក់ហ្នឹង យូរណាស់ ដើរមួយព្រឹកថ្ងៃត្រង់។ រួចតា ភុំ ហ្នឹងគាត់ឃើញខ្ញុំដើរ

ហ្នឹង មិត្តណា គាត់សួរខ្ញុំថា "មិត្តឯងចេះបើកឡានទេ? ខ្ញុំថាអត់ផង អ៊ំ។ គាត់ថា "អ៊ីចឹងចេះបរទេះគោទេ? ខ្ញុំថាបរទេះគោ ខ្ញុំចេះ។ អ៊ីចឹងមិត្តឯងទៅណោះម៉ុ"។ បានខ្ញុំមុនហ្នឹងមុនគេ ក្រោយដល់ឃើញម្នាក់ពីរនាក់ហ្នឹងដឹកដៃចេញពីរនាក់ ដឹកដៃចេញទៀត។ គេអ្នកនៅឈររើសហ្នឹង មានបងៗដែលជាថ្នាក់ដឹកនាំហ្នឹង គាត់ចាំរើសហ្នឹង។ រួចអាអ្នកដើរទៅ ចេះតែដើរទៅមិនដឹងទៅណាមកណាទេ។ ប្រៀបបីដូចជាក្បួនអណ្តែតតាមទឹកអ៊ីចឹង ជីវិតតស៊ូបដិវត្តន៍ហ្នឹង។ មិនដឹងជាវាសនាហ្នឹងទៅដល់ណាដល់ណីទេ។

[០៩:៣៩:២៤]

ដល់ទៅ រួចរើសបានគ្នាប្រហែលជា១៥០នាក់។ ដល់គេឲ្យទៅ ទៅដល់ភ្នំពេញលែងមានបាយហូបហើយ សម័យនុ៎ងនោះ។ គេឲ្យហូបនំប៉័ង។ គេថាប្រទេសយើងទើបនឹងងើបផុតពីសង្គ្រាមអ៊ីចឹង រួចនំម្សៅអីនៅសេសសល់ យើងនាំគ្នាហូបអាហ្នឹងទៅ។ ទៅដំបូងមានអី បានមួយឆ្អែតៗហ្នឹង ដល់បានតែ៣ថ្ងៃហ្នឹង នំប៉័ងមួយកំណាត់ៗហ្នឹង។ គេឲ្យទៅឆ្លងទៅត្រើយម្ខាង។ ក្រោយមកបានខ្ញុំស្គាល់ត្រង់ហ្នឹង គេហៅមន្ទីរក-៧ នៅខាងឆ្វេងដៃវាំងហ្នឹង ម៉ុ ប្លុកវីឡាមួយហ្នឹងរហូតមកមុខវត្តឧណ្ណាលោម។ ត្រង់ហ្នឹងជាបរិវេណមន្ទីរនីរសារ ក-៧ ដែលមានប្រធានឈ្មោះតា គី កាលហ្នឹងខ្ញុំចំណាំឈ្មោះគាត់តាគី ហ្នឹងគាត់ជាជនជាតិទៀត និយាយអត់សូវច្បាស់ទេ។ រាងគាត់ខ្មៅភ្នែកស្រលេវបន្តិច។

ទៅនៅកន្លែង តាគី ហ្នឹងដាំគេឲ្យកាប់ព្រៃក្បាលជ្រោយហ្នឹងដេកក្រោមដើមជម្ពូហ្នឹង អត់មានផ្ទះដេកទេ។ បានទៅដល់ហ្នឹងគេបើកអង្រឹងបើកអីឲ្យខាងក្រុមការងាររបស់ តាគី ហ្នឹង ទៅកាប់ទៅយើងដាំបន្លែ ដល់កំពុងដាំបន្លែនៅហ្នឹងបានប្រហែល១អាទិត្យទទួល បងរុយ ប្រធានមន្ទីរ ក-១២ ហ្នឹង អនុប្រធាន ក-១២ ហ្នឹង ហើយនិងប្រធានឈ្មោះ បងមៀល ហ្នឹងគាត់ទៅដើររើស ក្នុងគ្នា -- ទៅដល់ហ្នឹងមានចម្រុះពណ៌គ្រប់ភូមិភាគ--

[០៩:៤០:១៣]

**លោក វ៉ែន ពៅ៖**

**ស៖** ប្រហែលជាខ្ញុំត្រូវកាត់ពូ ពីព្រោះពូអត្ថាធិប្បាយវែងពេក ពេលវេលាខ្លី។ អ៊ីចឹង ខ្ញុំសង្ខេបចូលទៅចំណុចសំខាន់ៗដែលខ្ញុំហ្នឹងសួរពូបន្ត។ ខ្ញុំចង់សួរពូថាតើពូបញ្ជាក់មិញថា ក-១២ ខ្ញុំចង់សួរថា ក-១២ នេះជាមន្ទីរអីទៅបាទ?

**ឆ៖** ក-១២ នេះគឺជាមន្ទីរបើកបររបស់ -- កាលសម័យនោះស្អាកឡាន គេដាក់ ប.ទ ក្នុងលិខិតបើកផ្លូវខ្ញុំហ្នឹងគេដាក់នៅក្នុងអង្គភាពបរទេសរបស់មន្ទីរ៨៧០ រួចដល់ទៅស៊ីញ៉េលិខិតបើកផ្លូវនោះ ឈ្មោះ

សមមិត្ត ខាង ប៉ុន្តែមិនដឹងសមមិត្តខាង ហ្នឹងមួយណាទេ ខ្ញុំអត់ស្គាល់ទេ យើងឋានៈតូចតាចក៏អត់ ហ៊ាន ដេញដោលដែរ។ អាហ្នឹងខ្ញុំគ្រាន់ជម្រាបលោកមេធាវីអ៊ីចេះ។

**ស៖** សូមអរគុណ។ អំមិញពូបានបញ្ជាក់ថា មន្ទីរ៨៧០ សំណួរដែលខ្ញុំចង់សួរពូបន្តថាតើពូដឹង ថាមន្ទីរ៨៧០ ហ្នឹងជាមន្ទីរអី? ហើយអ្នកណាអ្នកប្រាប់ពូថា ជាមន្ទីរ៨៧០បាទ?

[០៩:៤២:៥៧]

**ឆ៖** មន្ទីរ៨៧០ ហ្នឹងបើតាមដឹង ដឹងតាមប្រធានដែលគាត់ប្រជុំគាត់លើកឡើងទេ។ តែមិនដឹង ជាបរិវេនមន្ទីរហ្នឹងនៅត្រង់ណាទេ? បើមន្ទីរក-១២ ខ្ញុំដឹង។ បរិវេនមន្ទីរបើតាមដែលខ្ញុំស្មានដឹងប្រហែល ជានៅ ក-១ ឬក៏ ក-៧។ ប៉ុន្តែសមមិត្ត ខាង ហ្នឹងខ្ញុំអត់ស្គាល់ជាអ្នកណាទេ ព្រោះសម័យនុំងគេធ្វើការ គេលាក់ការណ៍ម្នាក់ឈ្មោះពីរបី ពិបាក។ គ្រាន់ថាយើងមានការគោរពតែប៉ុណ្ណឹងឯង។ ហើយបាទ ជម្រាបជូនអ៊ីចឹង។

**ស៖** ខ្ញុំចង់សួរបញ្ជាក់ តើពូចាប់ផ្តើមចូលធ្វើការនៅមន្ទីរ ក-១២ នៅពេលណា? ហើយតួនាទីពូ គេឲ្យធ្វើអីខ្លះបាទ? ពូអាចរៀបរាប់បានទេបាទ?

**ឆ៖** ក្រោយពីចេញពីក្បាលជ្រោយហ្នឹងមក សមមិត្ត វុយ និងសមមិត្ត មៀល ហ្នឹងគាត់រើស ខ្ញុំមកមន្ទីរ ក-១២ ហ្នឹង មកកន្លែងបើកឡានមានគ្នាចំនួនប្រហែល ៣០នាក់ សុទ្ធតែអ្នកនៅទឹកដីបូព៌ា ហ្នឹងបាទ ហើយមានអ្នកមកពីតំបន់១០៣ខ្លះ ភូមិភាគឧត្តរខ្លះ។ គិតទៅបូកសរុបទៅកាលនោះវាបាន ប្រហែលជា ៨០នាក់អីដែរ។ ប៉ុន្តែខ្ញុំចាំអ្នកបូព៌ាៗហ្នឹង៣០នាក់។ អ្នកមកពីឧត្តរនោះខ្លះ អ្នកមកពី ព្រះវិហារ អ្នកមកពី តាំងពីជនជាតិមកពីខាងរតនគិរីអីក៏មានដែរ។ បាទ រួចហើយខ្ញុំមកដល់មន្ទីរក-១២ ហ្នឹងគឺនៅចុងប្រហែលជាជិត ខែ១១ ហើយធ្លាក់ខ្យល់ពីជើងហើយកាលហ្នឹង ហើយដល់មកដល់ដំបូង ហ្នឹងគេអត់ឲ្យយើងបើកឡានទេ។ គេឲ្យយើងដើររើសឡានដែលប្រជាជនទីក្រុងភ្នំពេញយកបើកទៅ ចោលតាមផ្លូវទៅ តាមផ្លូវលេខ១ តាមផ្លូវទៅកោះធំ ទៅស្អាង តាមផ្លូវទៅតាកែវមកផ្លូវជាតិលេខ៤ហ្នឹង តាមផ្លូវព្រែកក្តាម សុទ្ធតែឡាន។ អាណាខូចទៅដោះយកម៉ាស៊ីនទៅ អាណាដែលនៅល្អៗហ្នឹងចាប់ សប់កង់ទៅ បែងចែកជាក្រុមបីបួនក្រុម។ មួយក្រុមហ្នឹងមានគ្នាប្រាំមួយនាក់។ បើឡានធំនុំងមានគ្នា ដល់ទៅដល់ដប់នាក់។ បើអាឡានអាឡង់រ៉ូវើហ្នឹងមានគ្នាត្រឹមប្រាំនាក់អីទេ វាច្រើនវាអូសអត់រួច។ ប្រមែលប្រមូលមកដល់នៅក-១២ មកនៅដាក់នៅអែបចំការមនកន្លែងក្រសួងកសិកម្មរាល់ថ្ងៃហ្នឹង ខាង ក្រោយហ្នឹងមានបន្ទាយទាហានមួយ ដាក់សុទ្ធតែកូនឡាន ហើយនិងនៅក្បាលថ្នល់ ហើយនិងមានឃ្លាំង

ខ្លះទៀតដាក់អាល្អៗនៅខាងក-៣ ទៅខាងក្នុងជិតក-១ គេហៅឃ្លាំងលេខ៥ និងឃ្លាំងលេខ៤ ហ្នឹងដាក់រថយន្តទំនើប ហ្នឹងបាទ។ មកដល់ដំបូងគឺអ៊ីចឹង។ រួចដល់ទៅអូសឡាន ថ្ងៃយប់ហ្នឹងគេឲ្យរៀនបើកបរពីក្បាលថ្នល់មកវិមានឯករាជ្យហ្នឹងរាល់តែថ្ងៃអ៊ីចឹងទៅ និងយប់ខ្លះរៀនបច្ចេកទេស គេអត់មានឲ្យយើងមកបើកឡានតែម្តង គេឲ្យស្គាល់អ៊ីចឹងសិន។

[០៩:៤៦:៣៨]

ក្រោយមកទៀត ដល់យើងចេះទៅបានគេបណ្តោយឲ្យខ្ញុំបើកឡាន ហ្សេ.អឹម.សេ ទៅដឹកសំរាមនៅកន្លែងតាព្រហ្ម គេហៅមន្ទីរក-៤ អាហ្នឹងខាងកាត់ដេរ។ ប្រមែលប្រមូលសំរាមអីយកទៅចាកចោលស្ទឹងមានជ័យ និងមកដឹកកន្លែងសម្តេច ប៉ែន នុត នៅ, កន្លែងផ្ទះសម្តេច ហ៊ុន សែន រាល់ថ្ងៃហ្នឹង។ ប៉ុន្តែកាលនុំងវីឡាមួយយ៉ាងតូចទេ កាលហ្នឹងខ្ញុំធ្លាប់មកសំរាមនៅហ្នឹង ជួបគាត់ ជួបប្រពន្ធគាត់ ហើយគាត់ប្រពន្ធក្មេងទេសម្តេច ប៉ែន នុត ហ្នឹង ខ្ញុំចំណាំ។

**ស៖** បាទ ពូ! ខ្ញុំអរគុណ ហើយខ្ញុំមានសំណួរបន្តទៀតដែរ។ ពាក់ព័ន្ធនឹងក-១២ មន្ទីរក-១២ នេះពូអាចបញ្ជាក់បានទេ តើមន្ទីរ-១២ នេះមានផ្នែកណាខ្លះ? មានតែផ្នែកបើកបរទេ ឬមានផ្នែកអីផ្សេងទៀតដែរទេបាទ?

**ឆ៖** បាទ លោកមេធាវីខ្ញុំសូមឆ្លើយនឹងសំណួរនេះ។ ក-១២ ហ្នឹងមានបរិវេណហ្នឹងច្រើនកន្លែងណាស់ មើល៍! បើស្នាក់ការធំកណ្តាលហ្នឹងមុនហ្នឹងគេហៅកន្លែងហ្នឹង គេបើនិយាយរួមសម័យនុំងគេចែកប្លុកគ្នា។ ទៅដល់នោះ ដល់ទូតកូរ៉េខាងជើង ដែលជាទូតអាល្លឺម៉ង់រាល់ថ្ងៃហ្នឹង អាកន្លែងរាល់ថ្ងៃគេដាក់អីប៉ង់មេគង្គហ្នឹង ត្រង់ហ្នឹងកន្លែងដាក់ឡានថ្នាក់ដឹកនាំធំៗហ្នឹង។ ឡានសម្រាប់អ៊ំ ខៀវ សំផន, អ៊ំ នួន ជា, អ៊ំ ប៉ុល ពត អីឡានទាំងអស់គាត់អត់មាននៅទុកជាកម្មសិទ្ធិរបស់គាត់ទេ នៅផ្ទះទេ គឺឡានទាំងអស់សម្រាប់គាត់ជិះទទួលបរទេសគឺនៅក-១២ ទាំងអស់។ អាហ្នឹងជាមន្ទីរកណ្តាលមួយរបស់ក-១២ ដែលធំជាងគេ ដែលសមមិត្ត មៀល នៅហ្នឹងជាប្រធាន និងមួយកន្លែងទៀតនៅក្រសួងកសិកម្មរាល់ថ្ងៃនេះ ដោយមកក្រោយដល់បន្ទាយការពារ ទាហានការពារខាងចំការមនហ្នឹង ហ្នឹងក៏បរិវេណក-១២ ដែរ ហ្នឹងសមមិត្ត វុយ គាត់នៅហ្នឹង។ ហើយមុខៗគណបក្សប្រជាជនរាល់ថ្ងៃហ្នឹង អាឃ្លាំងប៉ុន្មានហ្នឹងរហូតក-៣ ហ្នឹងក៏ៗបរិវេណក-១២ ដែរ ហើយទៅក្បាលថ្នល់មួយកន្លែងទៀត អាហ្នឹងខាងឃ្លាំង។

[០៩:៤៩:២៧]

បើនិយាយទៅគេបែងចែកក្រុមបើកបរមានឡានតូច ឡានធំ និងខាងរោងជាង និងខាងឃ្លាំង។

រួចដល់ខាងរោងជាងមកនែអីផ្សារថ្មី ហ្គារាសសុងកុងហ្នឹងមួយ និងហ្គារាសក្បែរមនោរម្យមានវត្តមួយហ្នឹង មួយបរិវេណវត្តហ្នឹងមកដល់ខាងទាល់កន្លែង អ៊ំភា (អ៊ំ អៀង ធីរិទ្ធ) កន្លែងផលិតថ្នាំ ខាងសង្គមកិច្ច មកដល់ហ្នឹង។ អាផ្ទះមួយកម្ពុជាក្រោមហ្នឹងទាំងអស់របស់ ក-១២ ប៉ុន្តែអាហ្នឹងខាងជាង ខាងរោងជាង។

[០៩:៥០:០៩]

រួចគេយកវត្តហ្នឹងដាក់ម៉ាស៊ីនក្រឡឹងនៅលើវិហារហ្នឹងសម័យហ្នឹង រំព្រះចោលអស់ហើយ យកម៉ាស៊ីនក្រឡឹងដាក់លើហ្នឹងសម្រាប់កែច្នៃ ហើយឡានអ្នកណាខូច ត្រូវក្រឡឹង ត្រូវអីៗ របស់អីយ៉ាងម៉េចៗអាហ្នឹងខ្ញុំគ្រាន់ជម្រាបប្រសាសន៍អ៊ីចឹង ហើយមានសមាជិក បើពេលប្រជុំហ្នឹងប្រហែលជា៣០០នាក់តាមខ្ញុំស្មានមើលទៅ។ ៣០០លើសអ៊ីចឹងផង។ ព្រោះវាប្រមូលគ្រប់ផ្នែកមក មានទាំងពីចម្ការបន្លែៗរបស់ គ-១២ហ្នឹង នៅមុខចំការមនហ្នឹង ជាប់ចម្ការបន្លែក-៣ ខាងត្បូងអី ខាងវិទ្យុទាក់ទង ភ្លេចហើយ។ រួចនៅខាងចម្ការបន្លែខាងត្បូងនោះ ខាងរោងចក្រក្រឡឹងដែកទៅ ខាងឧស្សាហកម្មវិញ ហើយទល់មុខនុ៎ង ខាងក្រុមសិល្បៈ គេហៅ គ-៣៤ ក្រុមសិល្បៈកម្ពុជាប្រជាធិបតេយ្យហ្នឹង ប៉ុន្តែនៅត្រើយម្ខាងឯនោះ។ ប៉ុនកាលហ្នឹងទន្លេវាតូច ស្រែកហៅគ្នាឮហ្នឹង។

[០៩:៥១:២៤]

**សៈ** បាទៗ អរគុណពូ។ លោកប្រធាន ខ្ញុំនឹងអានឯកសារនេះ ហើយខ្ញុំមានសំណួរដែលត្រូវសួរចេញពីហ្នឹង គឺឯកសារដែលមាន ERN ជាភាសាខ្មែរ 00482793 ដល់ 00482794។, ERN ជាភាសាអង់គ្លេស 00739526 ដល់ 00739527, ហើយERN ជាភាសាបារាំង 00746474 ដល់ 00746475។ នៅក្នុងនោះខ្ញុំចង់ជម្រាបពូថា ពូបានបញ្ជាក់ថា ពូធ្លាប់បានដឹកសិក្ខាកាមដែលបានបញ្ចប់វគ្គសិក្សានៅសាលានយោបាយក-៦ បុរីកីឡា។ ហើយពូបញ្ជាក់ថា ពូបានដឹកសិក្ខាកាមទាំងនោះដែលមកពីក្រុមភូមិភាគ ភូមិភាគទាំង៦ និងភូមិភាគតំបន់ ពិសេសពីរទៀតទៅទស្សនកិច្ចដើម្បីប្តូរបទពិសោធន៍គ្នាទៅវិញទៅមកនៅទូតគ្រប់ភូមិភាគ ហើយពូក៏បានបញ្ជាក់ផងដែរថា សមមិត្ត ភុំ ដែលជាដឹកនាំគណៈប្រតិភូបានប្រាប់ថានឹងមានស្រុកគំរូ ឲ្យក្រុមសិក្ខាកាមទាំងនោះទៅមើលស្រុកគំរូចំនួនបី។ ទី១ គឺស្រុកប្រសូត្រ នៅភូមិភាគបូព៌ា, ទី២ គឺស្រុកកំពង់ត្រឡាចលើ នៅភូមិភាគបស្ចិម និងទី៣ នៅស្រុកត្រាំកក់ នៅភូមិភាគនិរតី។ សំណួរដែលខ្ញុំចង់សួរដែលថាពូបានចូលរួមដឹកសិក្ខាកាមទាំងនោះ ថាតើពូមាននៅចាំទេ ថាតើមានមេដឹកនាំផ្សេងទៀតក្រៅពីសិក្ខាកាមទៅចូលរួមជាមួយដំណើរទស្សនកិច្ច

នោះដែរទេបាទ?

[០៩:៥៣:៣៣]

**ឆ៖** បាទ អរគុណ ខ្ញុំសូមឆ្លើយនូវសំណួរនេះ។ កាលពីខ្ញុំ និយាយពាក់ព័ន្ធពីរឿងការសិក្សា និងការដឹក។ ខ្ញុំមកដំបូង គេឲ្យរៀននៅក-១៥ គឺគេហៅសាលាបច្ចេកទេសស្វរៀតរាល់ថ្ងៃហ្នឹង។ មករៀនហ្នឹងមានបងប្អូនមកពីស្រុកក្រៅខ្លះទៀត ខ្ញុំចំណាំកាលហ្នឹង។ គេឲ្យក-១៥ហ្នឹង មកពីបរទេសមកមករៀនហ្នឹង ដែលមានសមមិត្ត ភុំ ហ្នឹង គាត់បង្រៀន។ និយាយពីសមមិត្ត ភុំ គាត់បង្រៀនវិញ រួចចាំឈានដល់អានុំង។ រៀននៅក-១៥ហ្នឹង ខ្ញុំធ្លាប់បានរៀន គាត់បង្រៀន។ ដល់ក្រោយមក ការដឹកដូចលោកមេធាវីសួរសំណួរហ្នឹង គឺខ្ញុំអត់បានចូលរៀនទេជាមួយបងៗមកពីតាមភូមិភាគដែលវាថ្នាក់ដឹកនាំគ្រប់ភូមិភាគ និងតំបន់មករៀននៅភ្នំពេញហ្នឹងនោះ។ ប៉ុន្តែខ្ញុំបានជូន គាត់បានមករៀនហ្នឹងចំនួនកន្លះខែ ក៏ប៉ុន្តែមិនដឹងអ៊ំណាម្នាក់ ម្នាក់ណាអ្នកបង្រៀនទេ ខ្ញុំអត់ដឹងទេ អាហ្នឹងជារឿងផ្ទៃក្នុងខាងសាលា ប៉ុន្តែខ្ញុំបានជូនដើរទស្សនកិច្ចគ្រប់ភូមិភាគ។

មានឡានន៎ុងកាលន៎ុងឡានប្រហែលជា ៥០គ្រឿង ឡានក-១២ ហ្នឹងខ្វះទៀត ទៅខ្ចីឡានដឹកជញ្ជូនជើងគោកបន្ថែមទៀតដើម្បីឲ្យគ្រប់ចំនួនសិក្ខាកាមទាំងអស់មកសិក្សា។ រួចការដើរទស្សនកិច្ចហ្នឹងគឺដើររៀនសូត្រពីភូមិភាគមួយទៅភូមិភាគមួយ មើលភាពរីកចម្រើន ភាពជឿនលឿន ដែលជាសុទ្ធតែកម្មាភិបាល និងថ្នាក់ដឹកនាំ ហើយមកហ្នឹង។ ហើយដែលដឹកនាំគណៈប្រតិភូទាំងអស់ហ្នឹង គឺមានតាភុំ ហ្នឹងគាត់ជាអ្នកដឹកនាំប្រតិភូ។ ដំបូងខ្ញុំបើកឡានដឹកគាត់ជាមួយនឹង វុយ ដល់ទៅក្រោយមកបាន ២ថ្ងៃ បងហួន ហ្នឹងគាត់ឈឺ គាត់ឲ្យខ្ញុំមកបើកឡាន ហ្សេអឹមសេ ដឹកភ្ញៀវហ្នឹងវិញ។

[០៩:៥៥:៥៥]

**ឆ៖** ពូសុំទោសខ្ញុំកាត់ពូ ដោយសារពេលវេលា។ សំណួរខ្ញុំជាបន្តទៀតហ្នឹងគឺពាក់ព័ន្ធនឹងពូបានលើកឡើងថា ពូបានឮគេប្រាប់ថាមានស្រុកគំរូបី ដែលខ្ញុំបានអានរួចហើយ។ ថាតើពូដឹងទេថាហេតុអីបានគេយកស្រុកគំរូហ្នឹងជាស្រុកគំរូ ថាជាស្រុកគំរូ ដោយមូលហេតុអីពូដឹងទេ? មានអ្នកណាប្រាប់ពូទេបាទ?

**ឆ៖** កាលហ្នឹងខ្ញុំឮសមមិត្ត ភុំ ហ្នឹងនិយាយផ្ទាល់ប្រាប់សិក្ខាកាមទាំងអស់ទៅដល់ស្រុកប្រសូត្រខេត្តស្វាយរៀងនៃភូមិ -- តំបន់២៣ ភូមិភាគបូព៌ាហ្នឹង។ គាត់ថា "បក្សយើងនឹងជូនកិត្តិយសមួយដល់ស្រុកប្រសូត្រហ្នឹងដែលជាស្រុកជឿនលឿន ខំកសាង និងបង្កបង្កើនផលហ្នឹងបានគ្រប់ផែនការ"។ ស្រុក

នេះជាស្រុកទន់ខ្សោយ ធ្វើស្រែក៏មិនកើតអីពីដើមមក។ ដល់អ៊ីចឹង ដល់មកសម័យហ្នឹងធ្វើកើតបាន ដូចថាគ្រប់ផែនការ មួយហិកតា បីតោនអ៊ីចឹងទៅ ទៅប្រាំមួយតោនអ៊ីចឹងៗ បក្សយើងប្រគល់ទង់កិត្តិយសហ្នឹងឱ្យស្រុកប្រស្វូត្រហ្នឹងមួយ។ និងក្រោយមកទៀត មកដល់កំពង់ត្រឡាចលើមានគណៈខាងភូមិភាគបស្ចិមអ៊ីគេហ្នឹងគេមកទទួល ហើយការជូនដើរទស្សនកិច្ចហ្នឹង មួយភូមិភាគបូព៌ាហ្នឹងទៅដល់ចម្ការកៅស៊ូ ចេញពីនុ៎ងមកភូមិភាគកណ្ដាលមកមើលទំនប់ខាង៦មករា ដែលកាលនុ៎ងតែមិនទាន់ធ្វើទេយ៉ាងកាលហ្នឹង។ ប៉ុន្តែមានទំនប់នៅស្ទោង មើលរហូត ទើបកសាងទេ ១មករា ហើយនិង ៦មករា កាលហ្នឹង--

**ស៖** បាទ ពូខ្ញុំកាត់ពូទៀត។ ពាក់ព័ន្ធនឹងការពូដឹកសិក្ខាកាមទាំងនោះ តើពូមានសង្កេតឃើញស្ថានភាពរស់នៅរបស់ប្រជាជននៅតាមការដ្ឋាន ក៏ដូចជាក្នុងភូមិ តើមានស្ថានភាពយ៉ាងម៉េច ពូមានបានពិនិត្យឃើញយ៉ាងម៉េចខ្លះដែរបាទ?

[០៩:៥៨:២២]

**ធ៖** ទៅតាម -- និយាយរួមទៅតាមការដ្ឋានមួយៗ គេឱ្យមើលតែការដ្ឋាន ឃើញមនុស្សកុះករច្រូតស្រូវ បោកកណ្ដាប់រួមគ្នាហ្នឹង កកកុញសប្បាយណាស់ មើលទៅ ចាក់មីក្រូទ្រហឹងអឹងកងអ៊ីចឹងទៅតាមបទចម្រៀងពីសម័យហ្នឹង។ រីឯរោងបាយតាមសហករណ៍វិញ គេអត់ដែលឱ្យយើងដើរទៅមើលទេ អត់ដែលបានឃើញថា ប្រជាជនហ្នឹងបាយម៉េច គ្រាន់ថាការហូបចុក យើងដឹងហើយទូទាំងប្រទេសហូបជាលក្ខណៈសមូហភាព គឺហូបរួមហ្នឹង ប៉ុន្តែអត់ដឹងបាយទឹករបស់ប្រជាជនហ្នឹងយ៉ាងម៉េចទេ។ មានកន្លែងខ្លះទៀតទេដែលខ្ញុំដើរទៅឃើញហ្នឹង ការធម្មតា ការហូបរួមគ្នាវាមិនស្រួលប៉ុន្មានទេ ការងារហ្នឹង។ រួចទង់កិត្តិយសកាលហ្នឹងខ្ញុំនៅចាំ បក្សយើងប្រគល់ឱ្យហ្នឹងគឺនៅភូមិភាគបស្ចិម ហ្នឹងស្រុកកំពង់ត្រឡាចលើហ្នឹងមួយ និងនៅស្រុកត្រាំកក់ភូមិភាគនិរតីហ្នឹងមួយ។ ប្រគល់ឱ្យបីស្រុក ហើយគេឱ្យសិក្ខាកាមទាំងអស់ហ្នឹងត្រូវរៀនសូត្រពី បីស្រុកហ្នឹង ព្រោះបីស្រុកហ្នឹងជាស្រុកថាទន់ខ្សោយជាទីបំផុតមកដល់សម័យហ្នឹងគេធ្វើបានមួយហិកតា បីតោន។ ដូច្នេះអាអ្នកដែលស្រុកដែលធ្វើស្រូវដែលល្អហ្នឹង ធ្វើម៉េចឱ្យវាបានលើសហ្នឹង បើមិនបានប្រហែលគេ។ អាហ្នឹងជាគោលដៅ។

[១០:០០:០០]

**ស៖** បាទ សូមអរគុណ ខ្ញុំនឹងសួរជាបន្តទៀត។ ពាក់ព័ន្ធទៅនឹងក្រៅពីពូបានដឹកសិក្ខាកាមទាំងនោះ ថាតើក្នុងរបបកម្ពុជាប្រជាធិបតេយ្យទាំងមូល ដែលក្នុងឋានៈលោកពូជាអ្នកបើកបរនៅមន្ទីរក-១២ នោះ តើលោកពូធ្លាប់បានដឹកភ្ញៀវគណៈប្រតិភូបរទេសសំខាន់ៗ ក៏ដូចជាមេដឹកនាំជាន់ខ្ពស់ណាខ្លះ?

ពូអាចរៀបរាប់បានទេ បាទ?

**ឆ៖** ខ្ញុំសូមរៀបរាប់អំពីការដឹកនាំភ្ញៀវបរទេសវិញ។ បើនិយាយពីការដឹកនាំភ្ញៀវបរទេសវិញ ច្រើនណាស់ ១អាទិត្យៗភ្ញៀវមកទស្សនកិច្ចនៅស្រុកយើងហ្នឹងច្រើនណាស់ បើថ្នាក់ការបរទេសហ្នឹង ខ្ញុំរៀបដែលខ្ញុំនៅចាំ បានដូចជាប្រទេស យូហ្គោស្លាវីអីៗអីចឹង ប៉ុន្តែវាច្រើនប្រទេសពេក ខ្ញុំមិនចាំបានទេ ដែលចាំបានធំៗនោះ គឺគណៈប្រតិភូ ថ្នាក់ប្រធានាធិបតីហ្នឹង គឺមានប្រទេសភូមា ប្រទេសឡាវ និង លេខាបក្សកុម្មុយនីស្តចិន ឈ្មោះ ផឹង យឹងគួយ ហៅតាចាយ ហ្នឹង។

[១០:០១:៣៥]

**ស៖** បាទ សូមអរគុណ។ ថាតើពូបានបញ្ជាក់ហើយថា ពូបានដឹកគណៈប្រតិភូប្រធានាធិបតី ធំៗចំនួនបីប្រទេស គឺមានប្រទេសភូមា ប្រទេសលាវ និងប្រទេសចិន។ ខ្ញុំចង់ឲ្យពូបញ្ជាក់បន្ថែមឲ្យ ច្បាស់ទៀត ថាតើនៅពេលគណៈប្រតិភូទាំងនោះមក តើមានមេដឹកនាំណាខ្លះ ទៅចាំទទួលនៅអាកាស យានដ្ឋានពោធិចិនតុងដែរទេ? ពូអាចរៀបរាប់ ឬក៏នៅចាំបានទេបាទ?

**ឆ៖** ឥឡូវ ខ្ញុំសូមរៀបរាប់អំពីការដឹកគណៈប្រតិភូពីមុនមក និងមកដល់ពេលឥឡូវ។ ពីមុនមក ហ្នឹង គឺយើងទៅដឹកគណៈប្រតិភណាក៏ដោយ យើងស្លៀកពាក់តែខោអាវខ្មៅ ស្បែកជើងកងឡាន ឬ ខោអាវស៊ីមីលីមកពីចិនហ្នឹង និងខោអាវត្រួយចេកទេកខ្លួងមកហ្នឹង។ ដល់ទៅមានកម្មវិធីអញ្ជើញភ្ញៀវ ថ្នាក់ប្រធានាធិបតីធំៗមកហ្នឹង អ៊ំវ៉ាន់ ហៅអ៊ំ អៀង សារី ហ្នឹង មុននឹងទៅហ្នឹង គាត់ហៅទៅរៀន មួយព្រឹកនៅមន្ទីរប-១ ហ្នឹង ដើម្បីឲ្យជ្រួតជ្រាបអំពីគោលការណ៍របស់បក្សដែលត្រូវអញ្ជើញថ្នាក់ដឹកនាំ ធំៗហ្នឹងមកទស្សនកិច្ចជាផ្លូវរដ្ឋ និងជាផ្លូវការហ្នឹង។

[១០:០៣:១៦]

ខ្ញុំចង់ឆ្លៀតឱកាសហ្នឹង និយាយអំពីរឿងហ្នឹងបន្តិចទៅចុះ កុំអាលទៅដល់រឿងនុ៎ង។ ព្រោះ វត្តមានដែលទៅរៀនហ្នឹង គឺមានខាងក្រុមខ្ញុំ បើកបរ និងក្រុមដែលមានប្រធានឈ្មោះ បងមៀល ហ្នឹង បងវុយ ហ្នឹង។ វត្តមានទី២ គឺខាងអ្នកការពារ ដែលមានវត្តមាន មេគេហ្នឹង ឈ្មោះបង ខាំមី និងបងឆាន តាមខ្ញុំនៅចាំ។ វត្តមានទី៣ គឺផ្នែកអ្នកបម្រើភ្ញៀវ គិតទាំងអ្នកនៅទីផ្សារ ទាំងអ្នកបម្រើទាំងអស់។ អាហ្នឹងគឺមេគេមានឈ្មោះ តាមខ្ញុំចំណាំ ឈ្មោះយាយ ស៊ីន គាត់ជាមេផុងភោសម្រាប់ភ្ញៀវបរទេសធំៗ និងផុងភោរបស់តាៗ អ៊ំៗ អ្នកសម័យនុ៎ង តាមខ្ញុំដឹង។ ខ្ញុំធ្លាប់ជូនតាៗទៅណាអី ខ្ញុំដឹកក្រុមយាយ ស៊ីន ហ្នឹងទៅហើយ ព្រោះសម័យហ្នឹង យើងអត់មានលក់បាយទេ។

**ឆ៖** សុំទោសពូ ប្រហែលខ្ញុំជាកាត់ពូ ដោយសារពេលវេលា។ ខ្ញុំសូមឲ្យពូឆ្លើយបន្ថែមទៀតពាក់ព័ន្ធនឹង តើពូ -- អម្បាញ់មិញពូបានបញ្ជាក់ហើយថាពូបានរៀន មុនដឹកភ្ញៀវគណៈប្រតិភូសំខាន់ៗនេះ ពូបានរៀនវគ្គមួយជាមួយនឹងលោក អៀង សារី។ តើខ្លឹមសារសំខាន់នៃរៀននោះ តើរៀនអំពីអ្វីខ្លះទៅ ពូបញ្ជាក់សង្ខេបៗមក ចំណុចសំខាន់ៗបាទ?

[១០:០៥:០៥]

**ឆ៖** ខ្ញុំនៅចាំអត្ថន័យគាត់ខ្លះៗនូវបញ្ហារៀនហ្នឹងមុននឹងវគ្គនយោបាយហ្នឹង រៀនហ្នឹងនៅប-១។ ប-១ ហ្នឹងគឺមិនមែននៅរៀនអាផ្ទះកោងហ្នឹងទេ គេធ្វើផ្ទះមួយរាងដូចជង្រុកស្រូវអ៊ីចឹង រាងដូចផ្ទះកន្លែងគេមហាសន្និបាតបក្សនៅស្ទឹងជីនិតអ៊ីចឹង យកតែដែកចាស់ៗហ្នឹង និងឈើចាស់ៗមកធ្វើ ព្រោះសម័យហ្នឹង គេថាមិនការិយាល័យនិយម។ យកអាផ្ទះថ្ម ផ្ទះស្អាត គេធ្វើនៅៗផ្ទះដែលមិនល្អអ៊ីចឹង ដើម្បីកុំឲ្យយើងភ្លើតភ្លើន។ ហើយខ្ញុំសង្កេតមើលការទៅរៀនហ្នឹងទៀត ដូចជាបងៗថ្នាក់ដឹកនាំធំៗនៅការបរទេសហ្នឹង ស្លៀកសុទតែខោអាវចាស់ៗ។ រួចន័យគាត់រៀនកាលហ្នឹង គាត់លើកឡើងច្រើនដែរ ប៉ុន្តែខ្ញុំនៅចាំន័យត្រង់ណេះមួយ គាត់ថាមុននឹងចូលដល់ទៅដល់កម្មវិធីណែនាំហ្នឹង ខ្ញុំសូមលើកយកព្រឹត្តិការណ៍ជាតិព្រឹត្តិការណ៍អន្តរជាតិ គាត់ថាប្រទេសរាល់ថ្ងៃហ្នឹងមានឈ្មោះបោះសំឡេងនៅលើពិភពលោកយ៉ាងខ្លាំងក្រោយពីបានទទួលមហាជ័យជម្នះ១៧មេសា ហ្នឹង។ ហើយមានប្រទេសជាច្រើនចង់មកចងស្ពានមានមេត្រីជាមួយយើងដាក់ការទូត។ តែប្រទេសខ្លះក៏យើងទទួលយក តែប្រទេសខ្លះក៏យើងមិនទទួលយកដែរ។

[១០:០៦:៥០]

រួចបន្តបន្ទាប់មកទៀតគាត់លើកឡើងអំពីការខ្វះខាតស្បៀង។ គាត់ថា "ក្រោយពីការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញប្រហែលជា ៣លាននាក់ហ្នឹង ដូច្នេះប្រជាជនយើងសព្វថ្ងៃមិនមែន -- កំពុងតែប្រឈមមុខនឹងការខ្វះស្បៀង។ ហើយប្រជាជនយើងសព្វថ្ងៃហ្នឹង មិនមែនសម្បូរសប្បាយសម្បូររុងរឿងដូចវ៉ាដ្យូផ្សាយនោះទេសមមិត្ត" គាត់និយាយត្រង់អ៊ីចឹង "គឺកំពុងតែប្រឈមមុខនឹងការអត់ឃ្លានខ្វះស្បៀង, ខ្វះថ្នាំសង្កូវ, ខ្វះទឹកជកម្រ។ រួចចំពោះការវ៉ាដ្យូផ្សាយនេះជានយោបាយយើងទៅបរទេសដើម្បីឲ្យគេមានជំនឿទៅលើកម្ពុជាប្រជាធិបតេយ្យ ដើម្បីឲ្យអ្នកនៅបរទេសចូលមកជួយកសាងប្រទេសឲ្យមានភាពជឿនលឿន"។ អាហ្នឹងក្នុងន័យដែលគាត់និយាយហ្នឹង ចាំពាក្យហ្នឹងជាងគេ។

ហើយចំពោះរថយន្ត បក្សយើងមិននាំចូលទេ រថយន្តប្រភេទទេសចរណ៍ ចាំ១៥ ទៅ -- ១០ ទៅ

១៥ឆ្នាំទៀតទើបបក្សយើងនាំរថយន្តចូល។ យើងទ្រាំប្រើរបស់ជ័យភណ្ឌយើងហ្នឹង ចាស់ប៉ុណ្ណឹងសិនបានហើយ។ ហើយសមមិត្តត្រូវរើសយកតែរថយន្ត មែគសឺដេស-ស និងម៉ាកសេដេសខ្មៅ និងរថយន្តពើហ្ស កាត់សង់កាត់ហ្នឹង តែពីរមុខហ្នឹងទេ។ បីមុខទាំងឡានអាហ្ស៊ីបអាដឺ រត់មុខក្រោយ យកមករៀបចំទទួលគណៈប្រតិភូទៅតាមឋានៈនីមួយៗបាទ។

[១០:០៨:៥៤]

**ស៖** សូមអរគុណ។ ខ្ញុំត្រឡប់មកសំណួរដើមរបស់ខ្ញុំវិញ ពាក់ព័ន្ធនឹងពូបានប្រាប់អង្គសវនាការហើយថា ពូធ្លាប់បានដឹកភ្ញៀវសំខាន់ៗ គណៈប្រតិភូឋានៈប្រមុខរដ្ឋនៃប្រទេសចំនួនបីគឺ ប្រទេសភូមា ប្រទេសលាវ ហើយនិងប្រទេសចិន។ ខ្ញុំចង់ឲ្យពូបញ្ជាក់ថាតើមានមេដឹកនាំណាខ្លះទៅចាំទទួលគណៈប្រតិភូទាំងនោះនៅអាកាសយានដ្ឋានពោធិ៍ចិនតុងបាទ? ពូចាំទេ?

**ឆ៖** បាទ អរគុណ។ ខ្ញុំបង្ហើយព័ត៌មានខ្ញុំបន្តិចសិន ព្រោះវាជាខ្លឹមសារល្អដែរ។ រួចដល់ទៅអ៊ំ អៀង សារី ហ្នឹងគាត់ថា៖ យើងឈប់ស្លៀកពាក់ខោអាវខ្មៅ និងស្បែកជើងកង់ឡានទៅទទួលភ្ញៀវទៀតទៅ ចាប់ពីថ្ងៃហ្នឹងទៅ។ ខាងក្រុមការពារក៏ដូចអ្នកបើកឡាន គឺគាត់ឲ្យអ្នូរឫស្សី គឺត្រង់ហ្នឹងគឺផ្សារកាត់ដេររដ្ឋ។ នាំគ្នាទៅកាត់ខោអាវ ខោហ្នឹងពណ៌ខៀវ អាវហ្នឹងពណ៌ស ពងមាន់ ទាំងខាងអ្នកការពារ និងតែកុងឡានឲ្យមានឯកសណ្ឋានដូចគ្នា មានលក្ខណៈ ជាសមូហភាព។ រីឯអ្នកបម្រើវិញ អាវផ្កាឈូក ស្លៀកសំពត់ហូល ឬក៏សំពត់ខៀវទាំងខាងអ្នកលក់ ទាំងខាងអ្នកបម្រើ ទាំងអ្នកលក់ហ្នឹងក៏ត្រូវរៀបចំអីវ៉ាន់អីៗហ្នឹងឲ្យបាន កុំឲ្យភ្ញៀវខ្លះ ព្រោះភ្ញៀវភូមា ហ្នឹងគេចូលចិត្ត ខ្លះគេចូលចិត្តប្រើត្បូងប្រើអីណា។ ត្រូវរៀបចំអាការងាររស់ហ្នឹងឲ្យបានស្អេកស្កះ។ អាហ្នឹងខ្ញុំចង់បញ្ជាក់រឿងហ្នឹងបន្តិច។ ព្រោះវាជាន័យល្អដែរ គាត់ឈប់ឲ្យស្លៀកពាក់ខ្មៅហើយ ទៅទទួលបរទេស ខ្មៅហ្នឹងចង់ស្លៀក មកស្លៀកដល់កន្លែងមន្ទីរវិញស្លៀកចុះ។ រួចពួកខ្ញុំបានអ៊ីចឹង អរណាស់មិន ដែលបានអាវពណ៌ពាក់ផងហ្នឹងសម័យនុ៎ង។ គាត់ឲ្យកាត់ម្នាក់ពីរកំប្លេ។ មើលឆ្វេងមើលស្តាំមើលលើ មើលក្រោមហើយកាលនោះ។ វាមិនដែលឃើញពណ៌ ដល់មកនាំគ្នាកាត់អ៊ីចឹងទៅ។

[១០:១១:៣៥]

ហើយដល់ទទួល -- និយាយពីការទទួលគណៈប្រតិភូវិញ ដំបូងហ្នឹងគឺទទួលគណៈប្រតិភូភូមាៗហ្នឹងតាមខ្ញុំចាំឈ្មោះគាត់ ហ្នឹងគាត់ឈ្មោះ អ៊ូណេវិន ជាឋានៈប្រជាប្រធានាធិបតី។ ហើយចំណែកឯអ្នកទីទទួលភាគីកម្ពុជាយើង វិញគឺលោកអ៊ំ ខៀវ សំផន គាត់អ្នកទៅទទួលឈរហែរហាមតាំងពី

ពោធិ៍ចិនតុងរហូតមកដល់គេហៅថា វិមានរដ្ឋាភិបាលនៅមុខវត្តភ្នំហ្នឹង។ បាទ ខ្ញុំចាំ។ ហើយនិងនិយាយទៅដកតែអ៊ំ ប៉ុល ពត ចេញទេ ក្រៅពីនុ៎ងទៅទទួលទាំងអស់។ ខ្ញុំចាំគឺមានអ៊ំ អៀង សារី, អ៊ំ វន វ៉េត, អ៊ំ ចេក អន ខាងឧស្សាហកម្ម, អ៊ំ ម៉ី ប្រាង ខាងគមនាគមន៍ផ្លូវដែក, អ៊ំភា ហៅ អៀង ធីរិទ្ធ ហ្នឹងខាងក្រសួងសង្គមកិច្ច--

**ស៖** បាទៗ ពូ ខ្ញុំសូមកាត់ពូ។ ពូបានបញ្ជាក់ហើយថានៅពេលនោះពូបានឃើញវត្តមានរបស់លោក ខៀវ សំផន នៅទីនោះដែរ។ ខ្ញុំចង់សួរថាតើពូមានអ្នកដឹង ឬមានអ្នកណាប្រាប់ពូថាតើលោក ខៀវ សំផន នៅពេលនោះគាត់មានឋានៈជាអ្វីដែរបាទ?

**ឆ៖** នេះអត់ចាំបាច់អ្នកណាប្រាប់ទេ ព្រោះវ៉ាដ្យូផ្សាយរាល់ថ្ងៃ។ កាលទៅរៀនអីយើងដឹង ដឹងពីតួនាទីរបស់គាត់ដូចអ៊ំ ខៀវ សំផន គាត់ជាមាននាទីជាប្រធានគណៈប្រធានរដ្ឋនៃកម្ពុជាប្រជាធិបតេយ្យ។ បើយើងឥឡូវគេហៅប្រធានាធិបតីហើយ។ ព្រោះ អ៊ូណោរិន គាត់ប្រធានាធិបតី ឋានៈគាត់ប្រធានាធិបតីហើយគាត់ទៅទទួលហ្នឹង។ ហ្នឹងគ្រាន់ចង់បញ្ជាក់អ៉ីចឹង។

[១០:១៣:៤៥]

**ស៖** ចុះលោកនួន ជា វិញ ពូបានដឹងទេ ថាពេលនោះគាត់មានឋានៈជាអ្វីដែរ? ហើយអ្នកណាអ្នកប្រាប់ពូ ពូអាចបញ្ជាក់ឲ្យច្បាស់បានទេ បាទ?

**ឆ៖** កាលនោះបងៗនៅនោះប្រជុំក៏ធ្លាប់និយាយ វ៉ាដ្យូក៏ធ្លាប់និយាយ តាមកាសែត ទស្សនាវដ្ដីកម្ពុជាក៏តែងនិយាយ, សមមិត្ត នួន ជា គឺជាប្រធានតំណាងសភាប្រជាជនកម្ពុជា -- ប្រធានសភាតំណាងប្រជាជនកម្ពុជា ឋានៈគាត់។ រីឯអ៊ំ វ៉ាន់ វិញ ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងការបរទេស។ ហើយបើអ៊ំ សុន សេន វិញ ឧបនាយករដ្ឋមន្ត្រីក្រសួងការពារប្រទេស។ ហ្នឹងខ្ញុំចង់ជម្រាបអ៉ីចឹង។

**ស៖** ពាក់ព័ន្ធនឹងពូបានបញ្ជាក់ហើយថាគណៈប្រតិភូភូមាមកនោះ ថាតើមានជូនដំណើរគណៈប្រតិភូទៅទស្សនកិច្ចកន្លែងណាខ្លះនៅពេលនោះ? ពូចាំបានទេបាទ?

**ឆ៖** ខ្ញុំនៅចាំទាំងអស់ចំពោះគណៈប្រតិភូដែលបានអញ្ជើញមកហ្នឹង។ ទទួលពីពោធិ៍ចិនតុងមកហ្នឹងប្រហែលជាម៉ោងប្រាំបួនម៉ោងដប់ហ្នឹង មកដល់សម្រាកនៅវិមានរដ្ឋាភិបាល។ អ៊ូណោរិន ក៏នៅវិមានរដ្ឋាភិបាលទៅ ខាង អ៊ំហែម ក៏គាត់អញ្ជើញទៅផ្ទះទៅ ប៉ុន្តែរៀងថ្ងៃរសៀលបន្តិច ខ្ញុំជូនមិនដឹងគាត់ឋានៈអីទេ គាត់ទៅជូនសារតាំងចំពោះអ៊ំ ខៀវ សំផន នៅវិមាន គេហៅវិមានប្រធាគណៈប្រធានរដ្ឋ

នៅខាងជើងចំការមនហ្នឹង ខ្ញុំបានជូនភ្ញៀវហ្នឹងទៅ។ មួយសន្ទុះក្រោយមកបានឃើញរថយន្តមែគសឺដេស គាត់ បើកដោយ បងហឿន ខ្ញុំចំណាំឈ្មោះគាត់ ព្រោះជាអ្នកនៅជាមួយគ្នាហ្នឹង ហឿន ហ្នឹងគាត់សម្លាក មុខបន្តិច ក៏មកដល់។

[១០:១៦:១៥]

រឹងការមានកន្លែង ការងារយ៉ាងម៉េចៗហ្នឹងយើងមិនដឹងទេ គ្រាន់តែបាននៅចាំគ្រាន់តែសង្កេត ឃើញអ៊ីចឹងថាតាមខ្ញុំចាំហ្នឹង។ គេមកជូនសារតាំងចំពោះមួយប្រធានគណៈប្រធានរដ្ឋយើងហ្នឹង ខាង គណៈប្រតិភូភូមាហ្នឹង។ ដល់តែក្រោយមកយប់ទៅ បានបន្ទាប់ពីហ្នឹងភ្ញៀវខ្លះក៏គេទៅលេងផ្សារ ទៅ ទិញអីៗហ្នឹង ចូលចិត្តទិញណាស់ខាងភូមាហ្នឹង ទិញអីវ៉ាន់ដឹកមិនរួចទេ។ និយាយអត់ប៉ានចូលតាម ច្រកមុខទេ ខ្លាច អ៊ូណេវិន ហ្នឹងឃើញ ចូលតាមច្រកក្រោយ ជំនាន់នុ៎ងខ្ញុំចំណាំ ព្រោះខ្ញុំបើកឡានខាង--

**ស៖** បាទ ខ្ញុំសូមកាត់ លោកពូអាចបញ្ជាក់ក្រៅពីទស្សនកិច្ចនៅទីក្រុងភ្នំពេញ តើមានចេញទៅ ទស្សនកិច្ចនៅតាមខេត្ត ឬតំបន់ ឬក៏ភូមិភាគណាផ្សេងទៀតទេ គណៈប្រតិភូភូមាហ្នឹង?

**ស៖** គណៈប្រតិភូភូមាហ្នឹងគឺអត់មានទៅទស្សនកិច្ចតាមសហករណ៍អីទេ ថ្ងៃរសៀលហ្នឹងមក រួចនេះអ៊ីចឹងទៅ គាត់ចូលទៅមើលវាំង។ ប៉ុន្តែខ្ញុំនៅខាងក្រៅទេ ខ្ញុំអត់បានចូលទៅក្នុងវាំងទេ ទៅតែ គណៈប្រតិភូធំៗ មានអ៊ំ ខៀវ សំផន ហ្នឹងជាអ្នកដឹកនាំជូនដំណើរឯកឧត្តម អ៊ូណេវិន ទៅ។ ទៅដល់ រួចខ្ញុំចេះតែនិយាយលេងជាមួយ បងសាំ, ជាមួយមិត្ត សារុល អី។ “ទៅដល់ហ្នឹងម៉េចដែរ? យី! អ៊ំហែម លេងសំពះព្រះដែរតើអ្ហ៎!” (សើច) អាហ្នឹងនិយាយជាក់ស្ដែង។ រួចសំពះ រួចយើងទាំងអស់គ្នាសំពះនុ៎ង សំពះតែគាត់ជាមួយ អ៊ូណេវិន ហ្នឹង។ ព្រោះសម័យនុ៎ងគេអត់មានសាសនា បានខ្ញុំនិយាយទៅហាក់បីដូច ជា ជំពប់នឹងសំណើច សូមទោសមិនមែនមើលងាយមើលថោកទេ។

[១០:១៨:២៥]

រួចដល់ទៅល្ងាចៗ ទៅគេមានជប់លៀងទទួលភ្ញៀងហ្នឹងនៅវិមានរដ្ឋចំការមនៗ។ រួចមក១ថ្ងៃ ២ថ្ងៃកាលហ្នឹង រួចក៏ទៅទស្សនកិច្ចនៅសៀមរាបអង្គរ។ ខ្ញុំអត់បានទៅទេ ទៅសៀមរាបហ្នឹង គ្រាន់តែ ជូនភ្ញៀវឡើងយន្តហោះទៅ គេទៅនុ៎ង ហើយ អ៊ូណេវិន ក៏ឡើងយន្តហោះទស្សនកិច្ចនៅអង្គរហ្នឹង មិនដឹងនៅអង្គរណាខ្លះ ខ្ញុំចាំអត់បានទេ ខ្ញុំអត់បានទេ។ រួចគាត់ទៅប្រទេសគាត់វិញទៅ បាទមួយ--

**ស៖** បាទ សូមអរគុណ។ បាទ! ពាក់ព័ន្ធនឹងគណៈប្រតិភូមួយទៀត គឺគណៈប្រតិភូឡាវ ពូអាច បញ្ជាក់បានទេបាទ?

**ឆ៖** ចំពោះគណៈប្រតិភូឡាវ ក៏ដូចតែគណៈប្រតិភូភូមាដែរ ព្រោះជាឋានៈគាត់ជាប្រធានាធិបតី។ ខ្ញុំនៅចាំឈ្មោះគាត់យ៉ាងច្បាស់ គឺឈ្មោះគាត់ឈ្មោះ អ៊ូណៅវិន។ គណៈប្រតិភូឡាវហ្នឹង ប្រធានាធិបតីឡាវហ្នឹងឈ្មោះ អ៊ូណៅវិន--

**ស៖** សូមទោសប្រហែលជាពូជាន់គ្នា--

[១០:២០:០០]

**ឆ៖** អ៊ើ សូមទោស! បាទឈ្មោះ សុផានុវង្ស។ រឿងច្រឡំបន្តិច ឈ្មោះ សុផានុវង្ស ដែលទៅទទួលហ្នឹងដោយអ៊ំ ខៀវ សំផន ហៅអ៊ំហែម ហ្នឹងទទួលផ្ទាល់។ រួចរីឯភាគីកម្ពុជាយើងហ្នឹង ថ្នាក់ដឹកនាំខាងក្រោមៗទៀត ធំៗហ្នឹងគឺទៅទាំងអស់ដូចតែមុនអ៊ីចឹងដែរ។ ទៅទទួលនៅពោធិ៍ចិនតុង មានអ៊ំអៀង សារី, អ៊ំសុន សេន, អ៊ំវន វ៉េត, អ៊ំម៉ី ប្រាង អីហ្នឹង។ ថ្នាក់រដ្ឋមន្ត្រីៗហ្នឹងទាំងអស់និយាយទៅៗទទួល។ ដល់តែមកដល់ ជប់លាងអីដូចរាល់ដងអ៊ីចឹង ជូនទៅផ្សារដូចរាល់ដងអ៊ីចឹង ទៅមើលវាំង ទៅមើលអ៊ីចឹង។ ដល់តែយប់មើលសិល្បៈអីដូចគ្នា ទៅមើលសិល្បៈហ្នឹង។ គណៈប្រតិភូយើងហ្នឹងទទួលទៅមើលសិល្បៈហ្នឹងនៅមហោស្រពទន្លេបាសាក់ហ្នឹង។ គាត់មកប្រហែលជាពីរ ១យប់ ២ថ្ងៃឬក៏ប៉ុន្មានប៉ុណ្ណឹងទេ មិនជាយូរទេ។ រួចពីហ្នឹងទៅក៏ទៅទស្សនកិច្ចនៅសៀមរាប ក៏អ៊ំខៀវ សំផន ក៏ទៅដែរ។ ប៉ុន្តែកាលនុំងឡានវាខ្វះខាត។ ដល់តែឡានខ្វះខាតអ៊ីចឹង មិត្តមៀល – សមមិត្តមៀល ប្រធានមន្ទីរក-១២ហ្នឹង គាត់ឲ្យខ្ញុំយកឡានទៅប្រហែល១០គ្រឿងនោះ ក្រុមការងារខ្ញុំមាន ខ្ញុំនៅចាំកាលហ្នឹង មានបងផា, បងសាំ, បងសារុន, បងទង់, បងឡាត់, រាល់ថ្ងៃក៏គាត់នៅរស់ដែរនៅខាងតំបន់--

[១០:២១:៤៩]

**ស៖** បាទពូ ខ្ញុំសូមកាត់ពូ ដោយម៉ោងខ្ញុំវាជិតអស់ហើយ។ ពាក់ព័ន្ធនឹងភ្ញៀវសំខាន់ទី៣ គឺគណៈប្រតិភូចិន ពូអាចបញ្ចាក់បានទេបាទ?

**ឆ៖** បាទ ខ្ញុំសូមឆ្លើយគណៈប្រតិភូចិនហ្នឹង គឺលេខាបក្សកុម្មុយនីស្តចិន កាលនុំងគេប្រកាសអ៊ីចឹង។ ឈ្មោះគាត់ ឈ្មោះ ឆឹង យឹងគួយ ហៅ តាចាយ។ ដំណើរទស្សនកិច្ចជាផ្លូវរដ្ឋរបស់ប្រទេសមហាមិត្តចិនកាលហ្នឹង គឺមកកម្ពុជាយើងហ្នឹងយូរជាងគេ ខ្ញុំរាប់ទៅបាន១៦ថ្ងៃ គឺខ្ញុំជូនរហូត និងមិត្តរួមនៅក-១២ហ្នឹង អ្នកបើកបរ ទាំងអ្នកការពារ ទាំងអ្នកបម្រើអីហ្នឹងជូនទៅរហូត។ ហើយដល់ទៅខាងកម្ពុជាវិញដូរវិញហើយ។ អ៊ំ ខៀវ សំផន លែងទៅហើយពេលហ្នឹង។ អ៊ំ ប៉ុល ពត គាត់ទៅម្តង។ ពេលភ្ញៀវចុះពីលើយន្តហោះមក ហើយឈរលើនេះវេទិកាត្រួតពលហ្នឹង ឃើញអ៊ំ ប៉ុល ពត ហ្នឹងគាត់ឈរ

គោរពទង់ជាតិត្រួតពលអីហ្នឹងជាមួយសម-- គេលែងហៅឯកឧត្តមហើយកាលហ្នឹង សមមិត្ត ធឹង យើងគួយ មកហ្នឹង។ មានភ្ញៀវត្រៀបត្រាទទួលរាប់ម៉ឺននាក់នោះ រហូតពីពោធិ៍ចិនតុងមកដល់វិមានរដ្ឋាភិបាល កន្លែងដដែលហ្នឹងមុខវិមាន មុខវត្តភ្នំដដែលហ្នឹង។ ប៉ុន្តែគ្រាន់តែដូរថ្នាក់ដឹកនាំ។ អ៊ំ ខៀវ សំផន គាត់នៅកន្លែងម្តង, អ៊ំប៉ុល ពត គាត់មកម្តង។ ហើយនិងសូមបញ្ជាក់ថាថ្នាក់រដ្ឋមន្ត្រីក៏មកដែរ មកទាំងអស់ ដូចមកមុនៗអ៊ីចឹងដែរ។ រួចទៅដល់ល្ងាចទៅ ទៅជប់លៀងនៅវិមានចំការមនដូចគ្នាហ្នឹង។ រួចទៅមើលសិល្បៈ រួចទៅជូនភ្ញៀវទៅផ្ទះ។ ដល់តែព្រលឹមឡើងចេញទៅភូមិភាគបូព៌ា ទៅទស្សនកិច្ច ឆ្លងតាមព្រែកក្តាមនោះ ឡានប្រហែលច្រើនណាស់។ កាលហ្នឹងឡានជាប់ប្រហែល១០០ ដាក់ពីរខ្សែ មួយខ្សែខាងទន្លេបិទ មួយខ្សែត្រឹមតែកំពង់ចាម។ ខ្ញុំនៅចាំច្បាស់ ព្រោះឡានឆ្លងអត់ទាន់ យើងអត់ស្ពានណាកាលនុ៎ង សាឡាង។ រួចសាឡាងកាហ្នឹងមិនមែនសាឡាងស្រួលឯណា សាឡាងអូស កន្លែងក្បាលអូសនោះ។

[១០:២៤:៥៣]

**សៈ** បាទពូ ខ្ញុំសូមទោស ខ្ញុំប្រហែលជាកាត់។ នេះសំណួរខ្ញុំចុងក្រោយហើយ ខ្ញុំផ្ទេរជូនលោកពេជ អង្គ។ សំណួរចុងក្រោយរបស់ខ្ញុំ គឺពាក់ព័ន្ធនឹង ពូបានបញ្ជាក់ហើយថា ពូបានដឹកភ្ញៀវសំខាន់ៗមួយចំនួន ខ្ញុំចង់សួរពូថាពូដឹងទេថានៅរបបកម្ពុជាប្រជាធិបតេយ្យនោះមានស្ថានទូតបរទេសណាខ្លះប្រចាំនៅកម្ពុជាប្រជាធិបតេយ្យ? ពូចាំ ឬក៏ពូស្គាល់ទេបាទ?

**ឆៈ** ចំពោះស្ថានទូតដែលប្រចាំនៅកម្ពុជាប្រជាធិបតេយ្យ គឺខ្ញុំចាំបានច្រើនដែរ ប៉ុន្តែគ្រាន់ចាំកាលហ្នឹងវាប្រហែលជាមានជាង១០ប្រទេស។ ទូតខ្លះមាន គេហៅថា “គេហដ្ឋានហ្នឹងនៅភ្នំពេញ ទូតខ្លះគេគ្រាន់តែមកជូនសារតាំងចំពោះរដ្ឋាភិបាលយើង គេមានគេហដ្ឋានគេនៅប៉េកាំងក៏មានដែរ” អាហ្នឹងតាមខ្ញុំស្តាប់វ៉ាដ្យូទេណា។ រីឯទូតដែលនៅភ្នំពេញហ្នឹង គឺមានទី១ ធំជាងគេទូតចិន និងកូរ៉េខាងជើង ទូតវៀតណាម ទូតអាល់បានី រ៉ូម៉ានី យូហ្គោស្លាវី គុយបា អេហ្ស៊ីប ហើយមានប្រទេសស៊ុយអ៊ែតដែរ កាលហ្នឹង ស៊ុយអ៊ែតហ្នឹង ប្រហែលអាសយដ្ឋាននៅប៉េកាំងទេ តាមខ្ញុំដឹង។ ស៊ុយអ៊ែត និងរ៉ូម៉ានីហ្នឹង -- រ៉ូម៉ានីនៅហ្នឹងរ៉ូម៉ានី។ ប៉ុន្មានប្រទេសហ្នឹងដែលៗខ្ញុំចាំ ប៉ុន្តែមានជាង១០ប្រទេសកាលហ្នឹង។ សូមឆ្លើយតែប៉ុណ្ណឹងចុះ។

[១០:២៦:៤៩]

E1/185.1

**លោក វ៉ែន ពៅ៖**

សូមអរគុណ។ លោកប្រធាន ខ្ញុំអស់សំណួរហើយ ខ្ញុំសូមឱ្យសហភាគីខ្ញុំសួរបន្ត។ បាទ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ ។ ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាក ២០នាទី ចាប់ពីពេលនេះទៅរហូតដល់ម៉ោងដប់មួយខ្វះដប់នាទី សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី និងអ្នកជំនាញដល់សាក្សីរូបនេះនៅក្នុងអំឡុងពេលសម្រាក និងឱ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្តល់សក្ខីកម្មនេះវិញនៅវេលាម៉ោងកំណត់ គឺដប់មួយខ្វះដប់នាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:២៧ នាទី ដល់ម៉ោង ១០:៥១ នាទី)*

[១០:៥០:៥៥]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងវេទិកាជូនទៅក្រុមសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម អង្គសវនាការទាំងមូល។ ដើមបណ្តឹងរដ្ឋប្បវេណី និងសាធារណជន។

**សួរដោយលោក ពេជ អង្គ៖**

**ស៖** ជម្រាបសួរលោក ស សារិន! ខ្ញុំបាទ ពេជ អង្គ ជាមេធាវីជាតិនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី សម្រាប់ពេលដែលនៅសេសសល់ សម្រាប់ខ្ញុំសួរសំណួរជូនលោក គឺមានរយៈពេលតែ១០នាទី ដែលនៅសេសសល់តែប៉ុណ្ណោះ។ ដូច្នេះខ្ញុំសូមមេត្តាឆ្លើយខ្លីៗចំពោះសំណួររបស់ខ្ញុំ ហើយនិងផ្តោតជាពិសេស អំពីការអប់រំផ្នែកនយោបាយ។ តើលោកអាចបញ្ជាក់បានទេនៅសម័យខ្មែរក្រហម តើក្រៅពីអ្វីដែលលោកបានឆ្លើយជាមួយលោកមេធាវី វ៉ែន ពៅ ថាតើលោកមានធ្លាប់ចូលរួមនៅក្នុងវគ្គអប់រំនយោបាយអ្វីផ្សេងទៀតដែរឬទេ ដែលនៅក្នុងនោះមានថ្នាក់ដឹកនាំសម័យនោះ ជាអ្នកធ្វើបទឧទ្ទេសនាម?

[១០:៥២:២៧]

**លោក ស សារិន៖**

**ឆ៖** ក្រៅ -- ការសិក្សានយោបាយ ក្រៅពី សមមិត្តគុំ មក ខ្ញុំធ្លាប់បានចូលសិក្សានយោបាយនៅបុរីកីឡាហ្នឹង ដែលបង្រៀនដោយលោកអ៊ំ នួន ជា ហ្នឹង និងលោកអ៊ំ ខៀវ សំផន ហ្នឹង។ ធ្លាប់បាទ។

**ស៖** តើនៅក្នុងពេលនោះ លោកអាចបញ្ជាក់បានទេ មានអ្នកចូលរួមប៉ុន្មាននាក់? ហើយខ្លឹមសារដែលលោកអ៊ំទាំងពីរនាក់ហ្នឹង បានបង្រៀនពេលនោះ ផ្តោតទៅលើបញ្ហាអ្វីខ្លះ?

**ឆ៖** ការសិក្សានយោបាយពេលនោះ គឺមានគ្នាច្រើនណាស់។ បុរីកីឡា បើយើងនិយាយទៅពេញមុខហ្នឹង ជាប់ប្រហែលជាប្រាំ-ប្រាំមួយរយនាក់យ៉ាងតិច។ មានហៀរមកខាងៗទៀត ដោយមានភ្ញៀវមកពីមន្ទីរ កៗហ្នឹង ជុំវិញមន្ទីរ៨៧០ ដែលហៅថា ក-១, ក-២, ក-៣ រហូត ក ជាង៣០ ដែលខ្ញុំបានធ្លាប់ស្គាល់ហ្នឹង គឺមកភាគច្រើនកម្មាភិបាល មកទាំងអស់ និងក្រសួងថាមពល ដែលខ្ញុំចាំហ្នឹង មានក្រសួងថាមពល ក្រសួងដឹកជញ្ជូនជើងគោក ក្រសួងដឹកជញ្ជូនជើងទឹក និងខាងផ្លូវដែក ខាងសាធារណការ និងភ្ញៀវខ្លះមកខាងក្រសួងឧស្សាហកម្ម។

[១០:៥៤:៣៩]

**ស៖** ខ្ញុំសូមកាត់ តើមានសិក្ខាកាមមកពីតាមខេត្តទេ ថ្នាក់ស្រុក ឬក៏ថ្នាក់ឃុំ មានទេ?

**ឆ៖** ជម្រាបប្រសាសន៍ កាលនុំងមាន។ ប៉ុន្តែយើងមិនដឹងថា ស្រុកណាប៉ុន្មាន ខេត្តណាប៉ុន្មាន ភ្ញៀវវាច្រើន មាន ប៉ុន្តែភាគច្រើនសុទ្ធតែកម្មាភិបាលថ្នាក់ខ្ពស់បន្តិចទេបានគេឲ្យមករៀន។ និយាយទៅតូចត្រឹមខ្ញុំ ខ្ញុំអត់ទាន់មានចូលបក្ខជនអីទេ ប៉ុន្តែមេចេះតែឲ្យទៅរៀនទៅៗ។ ក្រៅពីនុំងសុទ្ធតែបក្ខជនថ្នាក់ដឹកនាំមូលដ្ឋាន ខ្ញុំសង្កេតមើលឃើញអីចឹងបាទ។

**ស៖** តើលោកអាចជម្រាបបានទេ ខ្លឹមសារនៃការបណ្តុះបណ្តាលពេលនោះគេនិយាយអំពីអ្វីខ្លះ ហើយអ្នកណានិយាយអំពីបញ្ហាអ្វី?

**ឆ៖** ខ្លឹមសារបង្រៀនកាលនោះគឺអ៊ំ នួន ជា ហ្នឹងគាត់បង្រៀនព្រឹក ដល់ពេលល្ងាចទៅ អ៊ំ ខៀវ សំផន។ រៀនហ្នឹងប្រហែលជា៣ថ្ងៃ ៤ថ្ងៃទាំងថ្ងៃឆ្លងជីវទស្សន៍បើខ្ញុំចាំ។ ហើយបង្រៀនហ្នឹង គឺរៀនពីមហាជ័យជម្នះរបស់បក្សន័យជ្រៅៗណាស់បើនិយាយទៅ ការងារហ្នឹង។ តែមុននឹងចូលដល់ការងារហ្នឹង ខ្ញុំសូមនិយាយបន្តិច នៅក្រោមឯកសណ្ឋានខោស្លឹកឫស្សី អាវហោប៉ៅបី ក្រមាបង់ក និងស្បែកជើងពុម្ពយ៉ាងចាស់ៗ គាត់មុខស្រាប់ដឹងហើយ ដែលជាសម្លៀកបំពាក់វណ្ណៈអធន ក្នុងឋានៈជាបក្ស ក្នុងឋានៈជាមេដឹកនាំពីសម័យនុ៎ង។

[១០:៥៧:១៨]

បាទ ពេលដែល -- ខ្ញុំសូមពេលចូលដល់រៀនឯកសារហ្នឹងគឺខ្ញុំចង់និយាយអំពីនៅក្នុងសាលាពោរពេញទៅដោយពាក្យស្លោក។ ពាក្យស្លោកនៅពេលនេះអត់មាននិយាយដូចមុនៗទេ ដូច "ជយោ! បក្សកុម្មុយនីស្តកម្ពុជាដ៏មហិមា មហាអស្ចារ្យ" តាមខ្ញុំចាំណ៎ា នៅខាងក្រោយអត់មានរូប ឡេនីន អត់មានរូប កាល់ម៉ាក្ស, អត់មានរូប ទូ សាមុត, អីប្អូនប្រាំនាក់--

**ស៖** បាទ ខ្ញុំសូមអធ្យាស្រ័យតើលោកពូអាចបញ្ជាក់ខ្លឹមសារបានទេ ហើយចំណុចមួយទៀតពាក់ព័ន្ធទៅនឹងជីវទស្សន៍។ ថាតើពេលដែលគេធ្វើជីវទស្សន៍ហ្នឹងគេធ្វើយ៉ាងម៉េចខ្លះ? ពេលធ្វើជីវទស្សន៍នោះ? ដោយសារពេលវេលាខ្ញុំមានខ្លីណាស់។

[១០:៥៨:២៣]

**ឆ៖** ឥឡូវខ្ញុំមុននឹងឈានចូលដល់នេះ ខ្ញុំសូមរៀបរាប់អំពីពាក្យស្លោកនៅក្នុងហ្នឹងពីព្រោះវាមានន័យសំខាន់ដែរ។ ធ្វើម៉េចពេលវេលាលោកសហាមេធាវីក៏មានតម្លៃ។ រីឯពាក្យខ្ញុំនិយាយហ្នឹងបើរំលងទៅក៏វាមិនមានន័យ។ អ៊ីចឹងខ្ញុំសូមទោស ខ្ញុំសូមរៀបរាប់បន្តិចចុះ។ បាទ រួចដល់ទៅពាក្យស្លោកខាងស្តាំដៃដាក់ "កម្ទេច សេ.អ៊ី.អា អាមេរិកនិងបរិវារ" សរសេរអក្សរធំៗណាស់ ម្ខាងស្តាំដៃ។ បើយើងអង្គុយបែរមុខមកជើងវិញឃើញអ៊ីចឹងខាងស្តាំដៃ។ ខាងនេះដាក់ពាក្យស្លោកថា "កម្ទេចនិងបោសសម្អាត អេ.អ៊ី.អា, កា.ហ្សេ.បេ និងខ្មាំងយួនវាតទីលេបទឹកដី" ដែលខ្ញុំចាំណ៎ា។ ហើយមុននិងលោកអ៊ំ នួន ជា ឡើងមកហ្នឹង យើងត្រូវគោរពទង់បក្សទាំងអស់គ្នា។ ខ្ញុំចង់និយាយអំពីន័យគោរពទង់ បក្សសម័យនុ៎ង ក៏ធ្វើឲ្យមនុស្សតស៊ូប្តូរផ្តាច់ចងអាឃាតចំពោះខ្មាំងសត្រូវ។

ចំពោះន័យគោរពទង់បក្សហ្នឹងមានន័យជ្រាលជ្រៅណាស់។ អ៊ីចឹង ខ្ញុំសូមលោកប្រធានខ្ញុំរៀបរាប់ពីន័យគោរពទង់បក្សមុននឹងបក្សមកដល់ហ្នឹងសម័យហ្នឹង ហើយដែលកម្រអ្នកណានៅចាំណាស់។ នៅ ឌី.ស៊ី.ខេម ក៏អត់មាននេះអាបទហ្នឹង។ នៅក្នុងន័យមុនបក្សចូលមកដល់ហ្នឹង គឺគេត្រូវក្រោកឈរច្រៀងទាំងអស់ក្នុងន័យចម្រៀងហ្នឹង និងខ្ញុំសូមនិយាយឲ្យសវនាការដឹង និងក្មួយនៅខាងក្រោយដែលជាក្មេងជំនាន់ក្រោយ ឲ្យដឹងថាញញួរ និងកណ្ដៀវហ្នឹងគេគោរព គេថាម៉េចខ្លះ។ ខ្ញុំចង់និយាយអ៊ីចឹងទេ។

[១១:០០:៥១]

គឺន័យគឺមានគេច្រៀងថា "ក្រោកឡើងអស់អ្នកក្រខ្ញុំគេទាំងប៉ុន្មាន ក្រោកឡើងអស់អ្នកក្រតោកយ៉ាករាល់ប្រាណ ក្ដៅណាស់ស្មើរប្រេះដើមទ្រូងធ្លាយចេញ គ្រានេះម្តងស្លាប់រស់មិនស្តាយ។ របបចាស់យើងកម្ទេចឲ្យអស់ចេញ មិនទោម្ទេញប្តេជ្ញាបូជាចិត្តកាយ អាំងទែរណាស្យូណាល់ គឺជាសង្គមអនាគត (ន័យត្រង់ហ្នឹងគេថាបីដង)"។ ពេលនោះអ៊ំ នួន ជា ក៏មកដល់នៅក្រោមឯកសណ្ឋាន ដូចខ្ញុំនិយាយអ៊ីចឹង។ គាត់និយាយឡានឡាំប្រឹតាដំបូលកំណាត់ទេ អត់មានជិះរថយន្តទំនើបល្អៗ កម្រមានអ្នកណាដឹងអត្តសញ្ញាណគាត់ណាស់។ ទឹកអត់មានអ្នកបម្រើទេ គាត់ស្ពាយប៊ីដុងគាត់មកពីស្រុកចិនមួយការ៉ុងកូនកែវនោះមួយ ដាក់អ៊ីចឹង។ មកដល់គាត់និយាយថា "នេះជាសំឡេងបក្សកុម្មុយនីស្តកម្ពុជា សូមគោរពសមមិត្តទាំងពីរប្រភេទដែលមានវត្តមានមកចូលរួមសិក្សានយោបាយពេលហ្នឹង"។ នៅពេលនោះគាត់អំពី "មហាជ័យជម្នះរបស់បក្ស មហាជ័យជម្នះចាស់ មហាជ័យជម្នះថ្មី។ មហាជ័យចាស់ហ្នឹងគឺមហាជ័យជម្នះ១៧មេសា ដែលយើងវាយឈ្នះចក្រពត្តិអាមេរិក និងបរិវារ មានភ្នំពេញ បាងកក ព្រៃនគរហ្នឹងយ៉ាងធំទៅហើយ។ តែបន្ទាប់មកទៀតគឺមហាជ័យជម្នះដែលយើងធ្វើបាន គឺមហាជ័យជម្នះលើកទំនប់ជីប្រឡាយ ជាក្រឡាឈើត្រង់ពាសពេញផ្ទៃប្រទេស"។ មហាជ័យជម្នះទី២។

[១១:០៣:១០]

"រីឯមហាជ័យជម្នះមួយទៀត គឺធំជាងនេះទៀត គឺមហាជ័យជម្នះដែលបក្សយើងទើបនឹងរកឃើញ គឺខ្មាំងស៊ីរូងផ្ទៃក្នុង ដែលប៉ងឃាឃីសម្លាប់បក្សយើង ក៏ប៉ុន្តែត្រូវបក្សយើងរកឃើញ"។ ហើយន័យប៉ុន្មានទៀតជ្រាលជ្រៅណាស់--

**លោក ពេជ អង្គ៖**

បាទ សូមអធ្យាស្រ័យលោកពូ ដោយសារខ្ញុំអស់ពេលហើយ ហើយខ្ញុំត្រូវគោរពម៉ោងដែលជាពេលវេលារបស់ខាងតំណាងសហព្រះរាជអាជ្ញា។ លោកពូនៅមានឱកាសធ្វើផ្តល់ចម្លើយថែមទៀត។

អ៊ីចឹងលោកប្រធាន ខ្ញុំសូមអរគុណចំពោះការផ្តល់ឱកាសឲ្យខ្ញុំសួរសំណួរចំពោះដើមបណ្តឹងរដ្ឋប្បវេណី។ ពេលនេះសូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាបន្តអង្គជំនុំជម្រះផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញាដើម្បីមានឱកាសដើម្បីតាំងសំណួរដេញដោលចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។

**លោក ឃីត វេយ្យន័រ៖**

សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រមជាទីគោរព។ លោក ស សារិន អរុណសួស្តីលោក ឈ្មោះខ្ញុំឈ្មោះ ឃីត វេយ្យន័រ ហើយខ្ញុំជាតំណាងសហព្រះរាជអាជ្ញានៅក្នុងសំណុំរឿងនេះ។

[១១:០៤:៥៦]

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក ឃីត វេយ្យន័រ៖**

**ស៖** ខ្ញុំនឹងសួរសំណួរមួយចំនួនទៅកាន់លោក អំពីប្រធានបទជាក់លាក់មួយចំនួន។ ប្រធានបទទាំងអស់នោះស្តីអំពីការសម្លាប់ទាហាន លន់ នល់។ ខ្លឹមសារនៃសន្ទរកថាធ្វើឡើងដោយ ខៀវ សំផន និង នួន ជា នៅក្នុងវគ្គអប់រំនយោបាយដែលលោកបានចាប់ផ្តើមនិយាយរួចមកហើយនោះ។ មួយទៀតគឺការស្លាប់នៅមន្ទីរសន្តិសុខ។ ហើយប្រសិនបើខ្ញុំនៅសល់ពេលវេលានោះ ខ្ញុំនឹងលើកឡើងអំពីប្រធានបទ ស្តីអំពីការណែនាំដែលគេប្រាប់ទៅលោកថាត្រូវនិយាយអ្វីខ្លះទៅគណៈប្រតិភូបរទេសនៅពេលដែលគេមកធ្វើទស្សនកិច្ចនៅក្នុងប្រទេសនាសម័យនោះ។ ខ្ញុំដឹងថាលោកបានទទួលឱកាសឲ្យមកផ្តល់សក្ខីកម្មពាក់ព័ន្ធទៅនឹងភស្តុតាងនៅក្នុងតុលាការនេះ។ ហើយខ្ញុំក៏ដឹងថាលោកក៏បានយល់អំពីប្រធានបទដែលខ្ញុំនឹងចោទសួរលោក ហើយប្រធានបទទាំងអស់នេះគឺជាបញ្ហាដែលពាក់ព័ន្ធទៅនឹងភស្តុតាងដែលលោកនឹងឆ្លើយជូនតុលាការ។ ហេតុដូច្នេះហើយ ខ្ញុំសូមស្នើឲ្យលោកផ្តោតអារម្មណ៍ទៅលើសំណួររបស់ខ្ញុំ ហើយសូមអធ្យាស្រ័យ ប្រសិនបើពេលខ្លះទៅខ្ញុំកាត់សម្តីលោកនៅក្នុងពេលដែលលោកឆ្លើយផ្តល់សក្ខី-កម្មនោះ។

[១១:០៦:៥៣]

តាមពិតទៅ ខ្ញុំមិនមែនធ្វើឡើងកាត់សម្តីលោកដោយមិនគោរពលោកនោះទេ គ្រាន់តែខ្ញុំកាត់សម្តីលោកដើម្បីជួយឲ្យលោកពន្យល់ភស្តុតាងដែលលោកគ្រោងនឹងឆ្លើយនេះជូនតុលាការ។ ដូច្នេះហើយ

តើយើងអាចចាប់ផ្ដើមដែរឬទេ? តើខៀវ សំផន បានថ្លែងអ្វីខ្លះនៅក្នុងវគ្គអប់រំនយោបាយនាពេលនោះ? វគ្គអប់រំនយោបាយនោះគឺធ្វើឡើងនៅបុរីកីឡា។ លោកបានឆ្លើយទៅលើចំណុចទាំងអស់នេះហើយ នៅក្នុងកំណត់ហេតុរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។ ខ្មែរត្រង់ទំព័រ 00482822, បារាំង 00746494, អង់គ្លេស 00739552 រហូតទៅដល់ 53។ លោកបាននិយាយថា ខៀវ សំផន បានលើកឡើងអំពីចំណុចទាំងអស់នោះ៖ "ទី១ និយាយអំពីត្រូវតែគោរពតាមមាគ៌ាបក្ស ហើយនិងគោរពតាមវណ្ណៈកសិករ ទី២ ភាពចាំបាច់ត្រូវបោសសម្អាតលុបចោល គោលជំហរ ទ្រព្យសម្បត្តិឯកជន ទី៣ ត្រូវតែកម្ទេច និងដកហូតសគល់មូលធននិយម សក្តិភូមិ អ្នកគ្រប់ ម្ចាស់ដី និងវណ្ណៈដែលកេងប្រវ័ញ្ចផ្សេងទៀតនៅក្នុងកម្ពុជាប្រជាធិបតេយ្យ។ ហើយចំណុចទី៤ ត្រូវបោសសម្អាតពួកយួន"។ សំណួរទី១របស់ខ្ញុំនោះ គឺចង់សួរដូចតទៅ តើលោកអាចនិយាយពន្យល់លម្អិតបន្ថែមដែរឬទេនៅលើពាក្យពេចន៍ដែល ខៀវ សំផន បានថ្លែងឡើងនៅពេលដែលគាត់នោះបានថ្លែងជូនទៅដល់អ្នកដែលចូលរួមក្នុងកិច្ចប្រជុំឲ្យធ្វើការកម្ទេច និងដកហូតសគល់ពួកមូលធននិយាយនោះ?

[១១:១០:០៧]

**ឆ៖** អរគុណលោក ឃីត រេយ៍ន័រ ដែលបានផ្ដល់សំណួរដល់ខ្ញុំបាទ។ ខ្ញុំសូមឆ្លើយអំពី ទី១ ពីរឿងការសម្លាប់ទាហាន លន់ នល់, ការសម្លាប់ទាហាន លន់ នល់--

**ស៖** សូមអធ្យាស្រ័យលោក ចំណុចការសម្លាប់ទាហាន លន់ នល់ ជាប្រធានបទមួយដោយឡែកនោះទេ ខ្ញុំបានសួរសំណួរសំខាន់មួយ និងជាក់លាក់អំពីចំណុចហ្នឹងមែន ក៏ប៉ុន្តែខ្ញុំចង់ឲ្យលោកឆ្លើយទៅនឹងសំណួរដែលខ្ញុំបានសួរលោកអម្បាញ់មិញ។ តើលោកអាចពន្យល់លម្អិតនូវអ្វីដែលលបានថ្លែងដោយខៀវ សំផន នៅក្នុងវគ្គអប់រំនយោបាយ នៅពេលនោះគឺគាត់បាននិយាយអំពីការកម្ទេចគាស់រំលើងពួកវណ្ណៈនាយទុននាពេលនោះ។ តើលោកអាចនិយាយពន្យល់បន្ថែមនៅចំណុចនេះបានដែរឬទេ?

[១១:១១:២០]

**ឆ៖** ចំពោះអត្ថន័យដែលលោកអ៊ំទាំងពីរបង្រៀនមកលើរូបខ្ញុំ និងខ្ញុំមានសម្ភាសទៅជាមួយ ឌី.ស៊ី.ខេម ហើយ ឌី.ស៊ី.ខេម ក៏យកឯកសារនេះមកដាក់នៅតុលាការនេះ។ ខ្ញុំសូមសំណូមពរដល់អង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ព្រោះកាលណាខ្ញុំនិយាយជាទូទៅ ន័យនេះជ្រៅណាស់ វាត្រូវប៉ះពាល់ដល់អាយុជីវិតរស់នៅរបស់ខ្ញុំបាទទៀត។ បាទ សូមជម្រាបលោកសហព្រះរាជអាជ្ញា។ ខ្ញុំផ្អាកសក្ខីកម្មខ្ញុំត្រឹមហ្នឹងសិន សូមទោស។ ទាល់តែមានការអន្តរាគមន៍ពីអង្គការសហប្រជាជាតិ និងរាជ

រដ្ឋាភិបាលដែលលោកជាអ្នកបង្កើតតុលាការហ្នឹង ជួយការពារខ្ញុំអស់មួយជីវិត ខ្ញុំនឹងជួយតុលាការវិញនូវអ្វីដែលគាត់បង្រៀនហ្នឹងប្រាប់តុលាការ។ អរគុណ។ សំណូមខ្ញុំមានតែប៉ុណ្ណឹងទេ។ ហើយខ្ញុំនឹងជួយអង្គការសហប្រជាជាតិវិញនូវកាដូព័ត៌មានខ្លះ កុំឲ្យពិភពលោកជួបរឿងអាស្រូវដូចកម្ពុជា កុំឲ្យពិភពលោកមានសង្គ្រាមវិនាសកម្មដូចជាអាវុធបេ៥២ ដែលដូចជាអាណត្តិលោក ឃើត ហ្វ័រហេម ដែលជាប្រធានអង្គការសហប្រជាជាតិពីសម័យមុននោះ ទល់ភ្នែកមើល មិនមើលកម្ពុជារងគ្រោះយ៉ាងម៉េចទេ។ អាវុធបេ៥២ ខ្ញុំសូមជូន ជម្រាបជូនលោកសហព្រះរាជអាជ្ញាសាហាវណាស់ គឺជាអាវុធ--

**សៈ** លោក ស សារិន ខ្ញុំកាត់សម្ដីលោក ខ្ញុំចង់សួរបញ្ជាក់ចំណុចមួយចំនួន។ លោក ស សារិន លោកបាននិយាយថា "ដោយសារកាលៈទេសៈ និងហេតុការណ៍ដែលបានកើតឡើងមកដល់ពេលនេះ គឺលោកមានអារម្មណ៍ភិតភ័យចំពោះលោកខ្លួនឯង និងគ្រួសាររបស់លោក ដែលលោកមកផ្ដល់សក្ខីកម្មនៅចំពោះតុលាការនេះ ឬក៏យ៉ាងម៉េច?

[១១:១៣:៥២]

**ឆៈ** បាទ អ៊ីចឹងមែន។ ខ្ញុំមានការភិតភ័យអំពីអសន្តិសុខផ្ទាល់ខ្លួនរបស់ខ្ញុំ ព្រោះខ្ញុំមើលគំរូដូចលោក ផាន់ ងោ អ៊ីចឹង ជារឿងនយោបាយនិយាយអំពីខ្មែរក្រហម រួចពេលនេះខ្ញុំនិយាយចំពោះមុខគាត់អ៊ីចឹងតែម្ដង ហើយរឿងហ្នឹងវាអ៊ីចឹងមែន។ កើតជារឿង បានជាខ្មែរយើងងាប់រាប់លាននាក់ហ្នឹង ដោយសារស្អី? ដោយសារសាលាកម្មាភិបាលហ្នឹងហើយ ដែលបង្រៀនឲ្យគាត់ហ្នឹងហើយ ដែលខ្ញុំសូមបង្អើបគ្រួសៗហ្នឹង ក៏ប៉ុន្តែនេះវាជារឿងអសន្តិសុខចំពោះខ្ញុំហ្នឹងវា៧០ភាគរយរួចហើយដែលខ្ញុំទម្លាយពីបញ្ហានេះ មកប្រាប់តុលាការប៉ុណ្ណេះ។ អ៊ីចឹង ខ្ញុំសូមស្នើអ៊ីចឹងដល់អង្គការសហប្រជាជាតិ សូមអាណិតមេត្តាស្នើដល់រាជរដ្ឋាភិបាលឲ្យលោកមានវិធានការជួយការពារខ្ញុំ ខ្ញុំនឹងវិលត្រឡប់មកធ្វើសក្ខីកម្មជាបន្ត ដើម្បីឲ្យតុលាការដឹងឫស ដឹងគល់ពីការពិត។ អរគុណ។ ហើយខ្ញុំនឹងជួយរាជរដ្ឋាភិបាលទៀតនូវកាដូព័ត៌មានខ្លះ ជួយដល់រាជរដ្ឋាភិបាលឲ្យជឿនលឿន។ មិនមែនកេងប្រវ័ញ្ចនយោបាយ ន័យនេះមិនមែនកេងប្រវ័ញ្ចនយោបាយ យកឆ្កៀតនិងយកឱកាស ដើម្បីនិយាយកេងប្រវ័ញ្ចអីទេ អាហ្នឹង។ ហើយខ្ញុំក៏មានកាដូ ជាពាក្យពេចន៍ខ្លះ ជាអនុសាសន៍ខ្លះជូនដល់លោក បាន គីមូន ដែលជាប្រធានអង្គការសហប្រជាជាតិ។ ឲ្យកុំឲ្យពិភពលោកវាជួបប្រទះ ដូចកម្ពុជា ដូចខ្ញុំនិយាយនេះ។

**សៈ** លោក ស សារិន ខ្ញុំនឹងព្យាយាមជួយជ្រោមជ្រែងលោក សួរសំណួរបន្ថែមទៀត។ ខ្ញុំមិនចង់បានព័ត៌មានលម្អិតនោះទេ ក៏ប៉ុន្តែអ្វីដែលលោកនិយាយនេះ គឺថាមនុស្សមួយចំនួនរាល់គ្នានោះបាន

និយាយបញ្ហាមួយចំនួនទៅដល់លោក ហើយផ្តល់ជាតម្រុយទៅដល់លោក ឬក៏មានហេតុការណ៍កាលៈទេសៈណាមួយធ្វើឲ្យលោកមានការភ័យខ្លាចនៅពេលនេះ? ឬក៏ការភ័យខ្លាច ដែលលោកលើកឡើងអម្បាញ់មិញនេះ ជាការភ័យខ្លាចទូទៅ កើតឡើងទូទៅ នៅពេលដែលលោកមកតុលាការនេះតែប៉ុណ្ណោះ។

[១១:១៦:២៨]

**ផៈ** អត់មានអ្នកណាប្រាប់ខ្ញុំទេ តែនេះជាទស្សនៈរបស់ខ្ញុំ គិតទៅឃើញ វាមានបញ្ហាអសន្តិសុខគឺអ៊ីចឹងសម្រាប់កម្ពុជា។ ខ្ញុំនិយាយឲ្យអស់ទៅ។ ខ្មែរក្រហមសព្វថ្ងៃ មិនមែនគាត់សប្បាយចិត្តយកមេគាត់មកកាត់ទោសអ៊ីចឹងទេ។ បើយកមកអ៊ីចឹង គាត់មិនចូលមកសមាហរ័ណកម្មទេ ខ្ញុំប្រាប់លោកសហព្រះរាជអាជ្ញា។ អ៊ីចឹង ខ្ញុំនិយាយទៅ ខ្ញុំដើរទៅវិញ វាមានបញ្ហាអសន្តិសុខដល់ខ្ញុំច្រើនណាស់។ មិនមែនជារឿងធម្មតាទេ និយាយទៅសារព័ត៍មានផ្សព្វផ្សាយ។ ជីវប្រវត្តិរបស់ខ្ញុំ ប្រាប់គេដឹងអស់រលីង។ ហ្នឹងលោកពិចារណាទៅ។ រូបលោក រូបខ្ញុំ។ ជីវិតកើតមកចង់តែរស់ តែយើងរស់ឲ្យវាមានន័យ។ ខ្ញុំជួយតុលាការអង្គការសហប្រជាជាតិ គួរតែតុលាការអង្គការសហប្រជាជាតិ ជួយខ្ញុំវិញផង។ ខ្ញុំសំណូមពរតែប៉ុណ្ណឹងទេ។ បើមិនអ៊ីចឹងទេ សក្ខីកម្មខ្ញុំ សូមបញ្ចប់តែប៉ុណ្ណឹងចុះ។ ខ្ញុំមានលទ្ធភាពជួយតែប៉ុណ្ណឹង ហើយបើជួយខ្ញុំបាន ខ្ញុំនឹងនិយាយពីរឿងពីរ៉ាវហ្នឹងឲ្យអស់។ ព្រោះខ្ញុំនៅចងចាំ៧០ភាគរយ។ លោកគ្រូជាទីគោរពរបស់ខ្ញុំ ដូច អ៊ំ ខៀវ សំផន, អ៊ំ នួន ជា, អ៊ំ ប៉ុល ពត ក៏ដោយ អ៊ំ អៀង សារី ខ្ញុំនៅចងចាំពាក្យពេចន៍គាត់ទាំងអស់។ ក្នុងនាមគាត់ជាថ្នាក់ដឹកនាំ រីឯខ្ញុំជាឧបករណ៍ដាច់ថ្លៃរបស់បក្ស។ បាទ សម័យនុ៎ង គេប្រើពាក្យអ៊ីចឹង។ គឺខ្ញុំស្រឡាញ់គាត់ បានខ្ញុំចាំពាក្យពេចន៍ទាំងហ្នឹង។ អរគុណ។

[១១:១៨:២៣]

**សៈ** ខ្ញុំកាត់សម្តីដដែលម្តងទៀតហើយ ដោយសារតែខ្ញុំព្យាយាមជួយជ្រោមជ្រែងទៅដល់លោក។ លោកបានឆ្លើយប្រាប់មជ្ឈមណ្ឌលឯកសារកម្ពុជា។ ចម្លើយនោះ គឺបានដាក់បញ្ចូលទៅក្នុងសំណុំរឿងក្នុងក្តីនេះរួចមកហើយ។ ដូច្នេះ បានន័យថា ចៅក្រមដែលកំពុងនៅចំពោះលោកនេះ មានឱកាសបានអានចម្លើយរបស់លោក មុនពេលដែលលោកមកតុលាការនេះរួចមកហើយ។ ហើយអ្នកដែលមានសិទ្ធិពិនិត្យសំណុំរឿងក៏បានមើលរួចហើយដូចគ្នា។ ខ្ញុំក្នុងនាមសហព្រះរាជអាជ្ញាព្យាយាមទាញយកភស្តុតាងដែលពាក់ព័ន្ធពីលោក។ ខ្ញុំមិនអាចដាក់ពាក្យសុំតាមវិធានតុលាការ ដែលថាលោកសុំឲ្យលោកចាត់ទុកដោយតុលាការធ្វើការការពារលោក ដោយសារតែលោកគឺជាបុគ្គលមួយមានការភិតភ័យ នៅពេលមក

ផ្តល់សក្ខីកម្មនៅទីនេះ។ ដូច្នេះ ខ្ញុំសូមសួរសំណួរទៅកាន់លោកនាពេលនេះ --

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកមេធាវីការពារក្តីលោក ខៀវ សំផន!

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ សូមគោរពក្រុមប្រឹក្សាជំនុំជម្រះ។ ខ្ញុំបាទឡើងមកនេះ ដើម្បីជួយជូនមតិដល់ក្រុមប្រឹក្សាជំនុំជម្រះ អំពីសំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណី។ ដោយមុននេះ លោកបានស្នើសុំឱ្យមានវិធានការការពាររូបគាត់ ដែលគាត់មានការព្រួយបារម្ភពីសុវត្ថិភាព។ ខ្ញុំយល់ថាដើមបណ្តឹងរដ្ឋប្បវេណីគឺជាភាគីនៅក្នុងទីនេះ នៅក្នុងសំណុំរឿងនេះគាត់មិនមែនជាសាក្សីដែលតុលាការត្រូវមានវិធានការបង្ខំឱ្យឆ្លើយ ឬក៏មិនឆ្លើយនៅចំពោះមុខអង្គសវនាការនៅពេលនេះនោះទេ ហើយក៏គ្មានគោលការណ៍សម្រាប់ការចាប់បង្ខំនេះដែរ។ ដូច្នេះ ការស្នើសុំមិនបង្ហាញសក្ខីកម្មបន្តទៀតរបស់ដើមបណ្តឹងរដ្ឋប្បវេណីអង្គជំនុំជម្រះ គួរតែមានការពិចារណាហើយធ្វើការសម្រេចអំពីបញ្ហានេះ ថាតើអនុញ្ញាតឱ្យគាត់ឆ្លើយបន្ត ឬមួយក៏មានវិធានការអ្វីបន្តទៀត។ បាទ សូមអង្គជំនុំជម្រះមេត្តាពិនិត្យលើចំណុចនេះបាទ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក សុន អរុណ៖**

ខ្ញុំៗបាទសុំខ្ញុំបន្ថែមលើ--

**ប្រធានអង្គជំនុំ៖**

កុំអាល់ទាន់លោកតំណាងសហព្រះរាជអាជ្ញា សូមអញ្ជើញលោកមេធាវីជាតិការពារលោក នួន ជា!

**លោក សុន អរុណ៖**

ខ្ញុំឈ្មោះ សុន អរុណ សហមេធាវីជាតិការពារលោក នួន ជា សូមគាំទ្រគំនិតសហមេធាវី របស់លោក ខៀវ សំផន ទាំងអស់ក្នុងគំនិតដែលសាក្សីមិនព្រមធ្វើសហប្រតិបត្តិការ -- មិនព្រមធ្វើសក្ខីភាពនៅពេលនេះនៅចំណុចនេះ។ ខ្ញុំសូមគាំទ្រមេធាវីខាង ខៀវ សំផន។ អរគុណ។

[១១:២២:០៨]

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា!

**សួរដោយលោក ឃីត រេយ៉ន័រ៖**

**ស៖** ខ្ញុំសូមឲ្យលោកឆ្លើយសំណួរថាតើពិត ឬក៏មិនពិតនោះទេ? ក្នុងករណីដែលលោកទទួលបានការធានាសន្តិសុខចំពោះលោក តើលោកនឹងស្ម័គ្រចិត្តមកផ្តល់ចម្លើយនៅក្នុងតុលាការនេះដែរឬទេ?

**លោក ស សារិន៖**

**ឆ៖** នៅពេលដែលមានការធានាពីសុវត្ថិភាពសន្តិសុខ ខ្ញុំនឹងវិលមកផ្តល់ចម្លើយជូនតុលាការ។

**ស៖** ខ្ញុំនឹងអានចម្លើយចេញពីក្នុងចម្លើយរបស់លោក ហើយសុំឲ្យលោកធ្វើការមិនឆ្លើយទៅលើចំណុចនេះ។ ក៏ប៉ុន្តែខ្ញុំសូមឲ្យលោកធ្វើការពិចារណានៅពេលដែលខ្ញុំសួរទៅកាន់លោក។ ទំព័រអង់គ្លេស 00739567, ខ្មែរ 00482836, បារាំង 00746507, នេះជាអ្វីដែលលោកបានលើកឡើង "ក្នុងនាមជាមនុស្ស ក្នុងនាមមានមនសិការជាមនុស្ស ខ្ញុំគួរតែប្រាប់លោកនូវអ្វីដែលខ្ញុំបានស្តាប់ឮ និងបានឃើញ។ វាមិនមែនមានន័យថាខ្ញុំស្អប់ ខៀវ សំផន ឬ នួន ជា នោះទេ។ ដូច្នេះហើយទើបខ្ញុំនិយាយអាក្រក់អំពីគាត់នោះ។ ខ្ញុំសូមសច្ចាថាពាក្យសម្តីដែលខ្ញុំបានឆ្លើយគឺជាការពិត។ ខ្ញុំកាន់ព្រះពុទ្ធសាសនា មានពាក្យអ្វីជាងពាក្យសម្បថ អត់មាននិយាយបំភ្លើសទេ។ (អាហ្នឹងជាពាក្យសម្តីគាត់និយាយអ៊ីចឹង) ខ្ញុំចង់និយាយជូនអង្គសវនាការតុលាការកាត់ទោសខ្មែរក្រហមឲ្យបានដឹងថា នេះជាកំហុសរបស់គាត់មែន ឬក៏អត់? ខ្ញុំអត់មានបំភ្លើសទេ។ ដូចខ្ញុំបានរៀបរាប់មកអ៊ីចឹង ដែលខ្ញុំធ្លាប់រស់នៅក្នុងរបបហ្នឹងមានតែប៉ុណ្ណឹងបាទ"។ សំណួររបស់ខ្ញុំចង់សួរទៅកាន់លោកថា ប្រសិនបើលោកផ្តល់ការធានានោះ តើលោកនឹងនៅតែផ្តល់ការពិត ចម្លើយការពិតទៅដល់តុលាការខ្មែរក្រហមនេះដដែល? តើអ៊ីចឹងដែរឬទេ?

[១១:២៥:១៨]

**ឆ៖** បាទ។

**ស៖** នៅពេលដែលយើងនិយាយអំពីចំណុចនេះ នៅពេលដែលយើងនិយាយអំពីការធានាសុវត្ថិភាព និងសន្តិសុខដែលនឹងផ្តល់ជូនលោកទៅកាន់ -- និងគ្រួសាររបស់លោកដើម្បីឲ្យសវនាការនេះអាចស្តាប់ចម្លើយរបស់លោកនោះ តើខ្ញុំយល់ត្រឹមត្រូវដែរឬទេ គឺនៅពេលនេះលោកនឹងមិនចង់ឲ្យភាគីគ្រប់គ្នានៅក្នុងទីនេះគឺថាសួរលម្អិតលោកអំពីព័ត៌មានដែលលោកបានឆ្លើយនោះទេ? តើអ៊ីចឹងដែរឬទេ?

**ឆ៖** ដូចខ្ញុំមានសំណូមពររួចទៅហើយ បើមិនមានការពារអសន្តិសុខរបស់ខ្ញុំទេ សក្ខីកម្មខ្ញុំសូម

បញ្ចប់ត្រឹមប៉ុណ្ណឹងចុះ។ ខ្ញុំជួយតុលាការបានតែត្រឹមប៉ុណ្ណឹង។

**ប្រធានអង្គជំនុំ៖**

ដើមបណ្ដឹងរដ្ឋប្បវេណីគួរតែត្រូវបានឆ្លើយមុន ហើយគួរតែត្រូវធ្វើបន្ទាប់នឹងតំណាងសហព្រះរាជអាជ្ញា ព្រោះអានេះជាពាក់ព័ន្ធនឹងខ្លួនផង ហើយពាក់ព័ន្ធនឹងភាគីម្ខាងផង។ យើងដូចជាធ្វើសវនាការនេះដូចជាច្រើនលើកច្រើនសាមកហើយ មិនមែនតែធ្វើម្ដងហ្នឹងទេ ជាង១ឆ្នាំដែលធ្វើសវនាការ។ បញ្ហាមួយមិនគប្បីឡើងចុះៗនិយាយបញ្ច្រាស ឆ្លើយតបចុះឡើងពីរបីសានោះទេ។

យើងអនុញ្ញាតឲ្យលោកស្រីម្ដងទៀត ប៉ុន្តែលើកក្រោយសូមលោកស្រីរៀបចំនូវរបៀបក្នុងការលើកឡើងនូវសំណើសុំដែលមានអត្ថន័យស្របជាមួយនឹងភាគីសហព្រះរាជអាជ្ញា។ លោកស្រីឃើញហើយមេធាវីពីររូបគឺគាត់បានឆ្លើយតបរួចហើយ ហើយតំណាងសហព្រះរាជអាជ្ញាតបរួមហើយ ហើយឥឡូវនេះតំណាងដើមបណ្ដឹងរដ្ឋប្បវេណីចាប់ផ្ដើមថ្មី អ៊ីចឹងការតបហ្នឹងថ្មីទៀត។ ពេលវេលាបំណងពន្លឿននៃកិច្ចដំណើរការនីតិវិធីត្រូវអាក់ខាន ដោយមិនបានបំពេញនូវគោលបំណងឡើយ។

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា អ៎! មេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី!

[១១:២៨:១៦]

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

សូមអរគុណលោកប្រធាន។ ខ្ញុំដឹងថាខ្ញុំក្រោកនេះវាយឺតបន្តិចហើយ ក៏ប៉ុន្តែខ្ញុំចង់និយាយដែរ ព្រោះថាសំខាន់ណាស់ចំពោះដើមបណ្ដឹងរដ្ឋប្បវេណីនេះ។ ជាលើកទី១ ដែលលោកមេធាវីនេះ អ៎! លោកដើមបណ្ដឹងរដ្ឋប្បវេណីនេះគាត់ព្រួយបារម្ភ។ ដូច្នេះខ្ញុំសូមដោយគោរព ដល់អង្គជំនុំជម្រះសូមផ្អាកសវនាការបន្តិចសិនដើម្បីពន្យល់ទៅដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ អំពីអ្វីដែលយើងនិយាយនៅទីនេះ អ្វីដែលជាសិទ្ធិ ហើយនិងកាតព្វកិច្ចរបស់គាត់ ហើយនិងដើម្បីឲ្យគាត់យល់ គាត់ដឹងអំពីអ្វីដែលអាចកើតឡើងចំពោះរូបគាត់ គឺថាភ័យខ្លាចជាដើមនោះ។ អ៊ីចឹងគួរឲ្យសោកស្ដាយណាស់ បើយើងមិនបានពន្យល់រឿងរ៉ាវទាំងអស់នេះទៅដល់គាត់។ ហើយដូចមេធាវី ខៀវ សំផន បានលើកឡើងដែរ គឺថាគាត់ជាភាគី ដូច្នេះយើងគួរតែនិយាយពិភាក្សាជាមួយគាត់បន្តិចសិនមុននឹងបន្តសវនាការយើងតទៅទៀត។ សូមអរគុណលោកប្រធាន។

[១១:២៩:២៣]

**ប្រធានអង្គជំនុំ៖**

អរគុណ។ សូមអញ្ជើញលោក វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម។ គឺថាការអន្តរាគមន៍ពីដើមបណ្តឹងរដ្ឋប្បវេណី គឺវាដូចនឹងខ្ញុំ។ ដូច្នេះហើយខ្ញុំមិនមានអ្វីត្រូវបន្ថែមនោះទេ។

[១១:២៩:៥០]

*(ចៅក្រមពិភាក្សាគ្នា)*

[១១:៣៥:១៦]

**ប្រធានអង្គជំនុំ៖**

លោកតំណាងសហព្រះរាជអាជ្ញាមានបញ្ហាអីទៀតទេ? សូមលោកនិយាយសរុបម្តងបានហើយ ឥឡូវហ្នឹងគឺមិនអាចសួរគាត់អំពីសំណួរសារធាតុពាក់ព័ន្ធជាមួយនឹងអង្គហេតុដែលគាត់បានដឹង ក្នុងន័យឲ្យគាត់ផ្តល់សក្ខីកម្មទេ គឺសំណួរពាក់ព័ន្ធជាមួយនឹងមូលហេតុទាំងឡាយនៃសំណើរបស់គាត់ សុំឲ្យអង្គជំនុំជម្រះ។ អំមិញគាត់មិនប្រើអ៊ីចឹងទេ គឺគាត់ប្រើអង្គការសហប្រជាជាតិជាមួយរាជរដ្ឋាភិបាលកម្ពុជាចាត់វិធានការការពារសុវត្ថិភាព អាយុជីវិតគាត់ និងគ្រួសាររបស់គាត់។ អ៊ីចឹងសូមឲ្យបើសួរគឺសួរទាក់ទិននឹងបញ្ហានេះដែលទាក់ទិនផ្ទាល់ទៅនឹងបទប្បញ្ញត្តិនៅក្នុងវិធានផ្ទៃក្នុងមួយចំនួន ដែលបានចែងរួចហើយ ដើម្បីបញ្ជាក់ពីបញ្ហានេះ ហើយអង្គជំនុំជម្រះនឹងដោះស្រាយបញ្ហានេះមុនដោយដោះស្រាយព្រមគ្នា ឬក៏ទន្ទឹមគ្នាជាមួយនឹងការប្រឹងប្រែរបស់ក្រុមសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីដែលបានលើកឡើងអម្បាញ់មិញថា ជាកូនក្តីរបស់ខ្លួនដែលមានបញ្ហាដូច្នេះ ក្នុងនាមជាមេធាវីការពារដើមបណ្តឹងរដ្ឋប្បវេណី គឺគាត់ខ្លួនសុំនូវឱកាសសមស្របមួយចំនួនសម្រាប់សម្របសម្រួលពន្យល់ដល់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ ដើម្បីឲ្យគាត់យល់អំពីកិច្ចដំណើរការប្រព្រឹត្តនាពេលនេះ ហើយនិងសារប្រយោជន៍នៃសក្ខីកម្មរបស់គាត់ចំពោះមុខអង្គជំនុំជម្រះ។ អ៊ីចឹងសូមបញ្ជាក់ឲ្យបានភាគីពាក់ព័ន្ធគឺឲ្យលើកតែបញ្ហានេះតែប៉ុណ្ណោះ ដោយអង្គជំនុំជម្រះនឹងយកបញ្ហានេះទៅពិនិត្យពិចារណាស្របពេលនឹងអង្គជំនុំជម្រះផ្តល់ពេលវេលាសមស្របជូនទៅមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីធ្វើការសម្របសម្រួលជាមួយនឹងកូនក្តីរបស់ខ្លួនលើបញ្ហានេះ។

ជូនតំណាងសហព្រះរាជអាជ្ញាមុន!

[១១:៣៨:១៣]

**លោក ឃីត វេយ៍ន័រ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមិនសួរអ្វីដែលក្រៅពីការណែនាំរបស់តុលាការទេ ដូច្នេះយើងមានបទបញ្ញត្តិនៅនេះហើយ ប៉ុន្តែលោកប្រធាន វិធាន២៩ អនុវិធាន៤(ង) អនុញ្ញាតឲ្យផ្តល់ភស្តុតាងនៅក្នុងសវនាការជាអសាធារណៈនៅពេលដែលតុលាការពិចារណាសម្រេចលើវិធានការការពារ។ ដូច្នេះ លោក ស សារិន អាចនឹងឆ្លើយបាននៅក្នុងសវនាការជាអសាធារណៈ ហើយនិងវិធានមួយទៀតក៏បានចែងបន្តទៅទៀតដែរ គឺវិធាន២៩(៦), បាទ ៧៩(៦) សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អរគុណ។ សូមអញ្ជើញលោកមេធាវីជាតិការពារក្តីលោក ខៀវ សំផន!

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំចង់បញ្ជាក់អំពីការលើកឡើងរបស់សហមេធាវីនាំមុខអន្តរជាតិ សហមេធាវីនាំមុខដើមបណ្តឹងអន្តរជាតិ ដែលបញ្ជាក់ថាលោក ស សារិន គាត់ទើបតែបាននិយាយជាលើកដំបូងអំពីការព្រួយបារម្ភរបស់គាត់ក្នុងការឆ្លើយសំណួរនានាពាក់ព័ន្ធទៅនឹងសំណុំរឿងនាពេលនេះ”។ តាមការពិតទៅ លោក ស សារិន បានសរសេរជាលិខិតមួយរួចហើយ ដែលមានជាភាសាខ្មែរលេខ ERN 00482841 ដែលមានលេខឯកសារ D230/1.1.874d ហើយលេខឯកសារនេះ (សូមទោស) ហើយឯកសារនេះបានដាក់ជូនទៅខាងការិយាល័យសហចៅក្រម (សូមទោស) ការិយាល័យសហព្រះរាជអាជ្ញារួចហើយ, ចុះថ្ងៃទី២០ (សូមទោស) ចុះថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០០៩ ដែលមានចុះហត្ថលេខាដោយលោក ស សារិន ដែលបញ្ជាក់ខ្លឹមសាររបស់វា គឺបញ្ជាក់អំពីការព្រួយបារម្ភអំពីបញ្ហាសុវត្ថិភាពរបស់លោក ស សារិន ខ្លួនឯង។ ប៉ុន្តែចំណុចដែលគួរពិចារណាមួយទៀតគឺថា នៅក្នុងលិខិតនេះបញ្ជាក់ថាលោកធ្វើជាសាក្សី មិនមែនជាដើមបណ្តឹងរដ្ឋប្បវេណីនោះទេ។

[១១:៣៩:៥៩]

បើដូច្នេះ អាចមានការយល់ច្រឡំ ឬក៏មិនមានការយល់ច្បាស់អំពីនីតិវិធី ឬមួយយ៉ាងម៉េចអានោះ ខ្ញុំមិនអាចដឹងបានអំពីបញ្ហារបស់លោក ស សារិន នោះទេ។ ក៏ប៉ុន្តែខ្ញុំគ្រាន់តែចង់ជូនដំណឹងនេះដល់អង្គជំនុំជម្រះពិនិត្យថា ការព្រួយបារម្ភអំពីសុវត្ថិភាពរបស់លោក ស សារិន វាជាបញ្ហាដែលបានលើកឡើងដោយលោក ស សារិន ខ្លួនឯង ហើយយើងក៏មិនទាន់បានដឹងថាតើមានភស្តុតាងអ្វីដែលពាក់ព័ន្ធ

ទៅនឹងការលំបាកនានា ដែលធ្វើឲ្យលោកមានការព្រួយបារម្ភនេះនៅឡើយដែរ។ បាទ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកមេធាវី ដែលបានព័ត៌មានដ៏មានសំខាន់នេះ។ ហើយលោក ស សារិន មុនពេលមកផ្ដល់សក្ខីកម្មនេះ តើលោកបានទទួលការជម្រាបជូនដំណឹងអំពីវិធានការការពារ ដែលភាគី -- ដែលអង្គភាពមួយ គឺអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ដែលតែងតែជម្រាបជូនដំណឹងទៅដល់អ្នកដែលត្រូវផ្ដល់សក្ខីកម្មមុន ជាមុន ដើម្បីសួរថាតើស្នើសុំមានវិធានការពារដែរឬទេ? តើលោកធ្លាប់បានទទួលការប្រាស្រ័យទាក់ទង និងជម្រាបដោយមន្ត្រីនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាចំពោះបញ្ហានេះ ដល់លោកដែរឬទេ?

[១១:៤១:៤១]

**លោក ស សារិន៖**

សូមគោរពលោកប្រធាន។ កន្លងមកគឺមានខាងក្រុមការងារតុលាការហ្នឹង បានលើកឡើងអ៊ីចឹងមែន ថាប្រសិនណាបើលោកខ្លាច លោកនិយាយពីកញ្ចក់ មានគេពង្រួមពង្រីកសំឡេង មិនឲ្យយើងភ័យខ្លាច មិនឲ្យយើងចេញមុខទេ ប៉ុន្តែខ្ញុំឆ្លើយតបនឹងគាត់វិញ "ខ្ញុំថា ខ្ញុំអត់ចូលចិត្តអ៊ីចឹងទេ។ ខ្ញុំចូលចិត្តនិយាយចំៗតែម្ដង។ កុំឲ្យគេថាចេះតែតុបតែង មិនដឹងមនុស្សហ្នឹងមួយណា"។ ខ្ញុំលើកឡើងអ៊ីចឹង ខ្ញុំចង់និយាយច្បាស់ៗអ៊ីចឹង។ មិនចង់និយាយរបៀបដូចថាពួនទេ លោកប្រធាន។ ចង់និយាយឲ្យ--

**ប្រធានអង្គជំនុំ៖**

វិធានការការពារ គឺវាមានលក្ខណៈដោយឡែកពីពួន។ វិធានការការពារ មិនអាស្រ័យលើលោកជាដើមបណ្ដឹងរដ្ឋប្បវេណី ឬក៏សាក្សីណាដែលផ្ដល់សក្ខីកម្មនោះទេ។ ហើយក៏ទំនងជាមិនអាស្រ័យទៅលើការយល់ឃើញរបស់អង្គជំនុំជម្រះដែរ។ វិធានការការពារ ដែលអង្គជំនុំជម្រះយកមកកំណត់នៅក្នុងវិធានដែលអនុវត្តរបស់ខ្លួននេះ គឺយកតាមវិធានការការពារដែលគេប្រើប្រាស់ជាអន្តរជាតិយកមកប្រើ។ តាមមធ្យោបាយសមស្រប ដែលមានចែងនៅក្នុងវិធានដែលបានលើកឡើងដោយតំណាងសហព្រះរាជអាជ្ញាអម្បាញ់មិញនេះរួចហើយ គឺវិធាន២៩ នៃវិធានក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។

ដូច្នេះ វិធានការការពារមិនមែនធ្វើទៅតាមលោកចង់ ថាឲ្យអង្គការសហប្រជាជាតិ ឲ្យសហការជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជាចាត់វិធានការការពារចំពោះរូបលោកនោះទេ។ វិធានការនេះមិនមានទេ។ វិធានការការពារផ្ដល់សមត្ថភាពមកឲ្យអង្គជំនុំជម្រះសាលាដំបូង ឬក៏តាមអង្គភាពដែលពាក់ព័ន្ធ

ពីដើមខ្សែកន្លងមក ដើម្បីចាត់វិធានការដោយផ្អែកលើខ្លឹមសារណាមួយក្នុងចំណោមបណ្តាវិធានការទាំងឡាយដែលមានប៉ុណ្ណោះ។

[១១:៤៤:០៦]

បាទ ជាបន្ត តើអស់លោក លោកស្រី មានសំណួរអីសួរ ចង់សួរពាក់ព័ន្ធនឹងបញ្ហានេះទេ? ភាគី ឬក៏ទៅដើមបណ្តឹងរដ្ឋប្បវេណីទេ ដើម្បីមានមូលដ្ឋានក្នុងការពិចាណា?

បាទ មិនមានទេ។ ឥឡូវនេះ អង្គជំនុំជម្រះសូមជម្រាបភាគី និងសាធារណជនថា អង្គជំនុំជម្រះមិនអាចដំណើរការស្តាប់បន្ត ដំណើរការស្តាប់សក្ខីកម្ម ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ នាពេលនេះបានទេ។ ដោយសារមានបញ្ហា ដូចភាគី និងសាធារណជនជ្រាបហើយ គឺគាត់មានការព្រួយបារម្ភលើបញ្ហាសុវត្ថិភាពខ្លួនគាត់ ឬក៏គ្រួសាររបស់គាត់ នាពេលអនាគត ក្នុងការផ្តល់សក្ខីកម្មចំពោះមុខអង្គជំនុំជម្រះនេះ។ ឥឡូវនេះ គឺអង្គជំនុំជម្រះធ្វើការពិនិត្យពិចារណាលើបញ្ហាស្របជាមួយនឹងភារកិច្ច ឬក៏សំណើសុំមេធាវីរបស់គាត់ គឺក្រុមមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី សូមធ្វើការពន្យល់ ហើយនិងបំភ្លឺរបស់គាត់ ត្រូវការពេលវេលា ហើយអង្គជំនុំជម្រះក៏ត្រូវការពេលវេលាក្នុងការពិនិត្យ ពិចារណាសម្រេចលើបញ្ហានេះតាមវិធានដែលពាក់ព័ន្ធដែរ។

បាទ ដូច្នេះអង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការនៅព្រឹកនេះត្រឹមនេះ ដើម្បីមានពេលទៅពិនិត្យពិចារណាលើបញ្ហានេះ ហើយអង្គជំនុំជម្រះនឹងលើកបន្តធ្វើសវនាការនៅរសៀលនេះ នៅវេលាម៉ោងមួយសាមសិបនាទី។

[១១:៤៥:៣០]

ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួល និងផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី និងអ្នកជំនាញដល់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ នៅក្នុងអំឡុងពេលសម្រាកថ្ងៃត្រង់នេះ ហើយនិងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្តល់សក្ខីកម្ម នៅក្នុងបន្ទប់សវនាការនេះវិញនៅវេលាម៉ោងមួយសាមសិបនាទីរសៀលនេះ។ ហើយមន្ត្រី--

សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា! អំមិញយើងបានជម្រាបលោកហើយ ថាបើលោកមានបញ្ហាអីលើកឲ្យអស់។ ហើយឥឡូវនេះយើងសម្រេចរួចហើយ ហើយលើកបន្ថែមទៀត។ យើងផ្តល់ពេលវេលាឲ្យលោកសមស្រប ហើយលោកឮយើងបញ្ជាក់ច្បាស់លាស់ណាស់!

យើងគិតថាបទពិសោធន៍ក្នុងការដំណើរការគ្រប់គ្រងសវនាការនេះដូចច្រើនឆ្នាំហើយ មិនគួរ

ជួបស្ថានភាពរបៀបនេះសោះ។ អញ្ជើញលោកចុងក្រោយណ៎ះ! មិនគប្បីរំខានដល់កិច្ចការដំណើរការរបៀបនេះទេ។

[១១:៤៦:៤៦]

**លោក ឃីត រេយ៍ន័រ៖**

លោកប្រធានសូមអរគុណចំពោះការណែនាំនេះ។ នៅពេលដែលប្រើពាក្យថា“នឹងប្រជុំសម្រេច” នោះ ខ្ញុំសូមជម្រាបថា ខ្ញុំបញ្ជាក់ថា ខ្ញុំមិនលើកនៅល្ងាចនេះទៀតទេ។ សហព្រះរាជអាជ្ញានឹងធ្វើសំណើជាសំខាន់សម្រាប់ថ្ងៃល្ងាចនេះ ចំពោះលោក ស សារិន ដើម្បីឱ្យគាត់ធ្វើសក្ខីកម្មក្នុងសវនាការជាអសាធារណៈបាទ។

**ប្រធានអង្គជំនុំ៖**

អំមិញនិយាយរួចហើយអាហ្នឹង លោកបានលើករួចហើយ លោកសំអាងច្បាប់ ហើយលើកជាអសាធារណៈ ដើម្បីអង្គជំនុំជម្រះពិចារណាថាតើគួរចាត់វិធានការយ៉ាងម៉េចនៅក្នុងបណ្តាវិធាន២៤.៩ ដែលពាក់ព័ន្ធ សមស្របនឹងអនុវត្តនូវវិធានការនេះ។ សូមអញ្ជើញលោកស្រីមេធាវី!

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមត្រឡប់មកនិយាយអំពីការកត់សម្គាល់របស់សហព្រះរាជអាជ្ញា ពីព្រោះថាសំខាន់ណាស់ចំពោះយើង។ យើងចង់ថាតើយើងនឹងមានសិទ្ធិនិយាយ ឬក៏អត់នៅពេលដែលគាត់ដើមបណ្តឹងរដ្ឋប្បវេណីនេះនឹងធ្វើ ផ្តល់សក្ខីកម្មជាអសាធារណៈ ហើយនិងគាត់ត្រូវការពិភាក្សាជាមួយមេធាវីរបស់គាត់។ តើមុននឹងចេញសេចក្តីសម្រេច យើងសូមឱ្យច្បាស់ទាំងអស់គ្នា ថាយើងត្រូវឱ្យយល់គ្នាឱ្យច្បាស់ ថាត្រូវឱ្យមានការពិភាក្សាជាមួយគាត់ឱ្យច្បាស់លាស់ ហើយនិងត្រូវមានគោលជំហរ ដឹងពីគោលជំហររបស់គាត់ឱ្យច្បាស់លាស់មុននឹងអនុវត្តសំណើរបស់សហព្រះរាជអាជ្ញា។ អ៊ីចឹងយើងត្រូវតែធ្វើសេចក្តីសម្រេចទាំងអស់នេះសិន មុននឹងស្តាប់សក្ខីកម្មរបស់លោកគាត់ជាក្រោយ។

**ប្រធានអង្គជំនុំ៖**

បង្គាប់ឱ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ទៅកាន់បន្ទប់រង់ចាំនៅខាងក្រោមសាលសវនាការនេះ ហើយនិងឱ្យនាំខ្លួនត្រឡប់មកចូលក្នុងបន្ទប់សវនាការនេះវិញនៅរសៀលនេះ នៅវេលាម៉ោងមួយសាមសិបនាទី។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១១:៤៩ នាទី ដល់ម៉ោង ១៣:៥១ នាទី)*

[១៣:៥១:០៥]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សូមអញ្ជើញលោកមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ហើយនិងជម្រាបលោកផងដែរថា សូមលោកផ្ដល់នូវលទ្ធផលនៃការបញ្ចុះបញ្ចូល ឬក៏សម្របសម្រួលជាមួយនឹងដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ ក្នុងការឆ្លើយ ឬមិនឆ្លើយតបនៅក្នុងកិច្ចដំណើរការសវនាការនេះ ដែលគាត់ព្រឹកមិញគាត់បានសូមវិធានការការពារ ហើយមិន -- គាត់បញ្ឈប់ការឆ្លើយតប និងសំណួរទាំងឡាយនៅពេលនេះ ប្រសិនបើមិនមានការចាត់វិធានការការពារតាមសំណើសុំរបស់គាត់ទេ។

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម និងអង្គសវនាការទាំងមូល។ យើងខ្ញុំបានពិភាក្សាជាមួយគាត់ ជាពិសេសលើកអំពីតម្លៃនៃសក្ខីកម្ម តម្លៃផ្នែកសង្គមនៃសក្ខីកម្ម តម្លៃផ្នែកភស្តុតាងនៃសក្ខីកម្ម។ ហើយតែលោកដើមបណ្ដឹងរដ្ឋប្បវេណី ស សារិន គាត់នៅតែលើកថា គាត់នៅមានការព្រួយបារម្ភពាក់ព័ន្ធទៅនឹងសុវត្ថិភាពរបស់គាត់ ហើយនៅតែរក្សាគោលគំនិតរបស់គាត់ដដែល។ ហើយចំណុចមួយទៀត ដែលគាត់មិនបានបញ្ជាក់ឲ្យបានក្បោះក្បាយ គឺថាតើខ្លឹមសារអ្វីដែលជាវិធានការពារដែលគាត់ចង់ស្នើសុំនេះ។ ដូច្នេះខ្ញុំបាទសូមអនុញ្ញាតលោកប្រធាន ដើម្បីឲ្យគាត់លើកអំពីខ្លឹមសារជាលម្អិតបន្តិចពាក់ព័ន្ធទៅនឹងខ្លឹមសារ -- ទាក់ទងទៅនឹងវិធាការការពារដែលគាត់ស្នើសុំនេះ។ ហើយបើអាចធ្វើបាន ការស្ដាប់ពាក់ព័ន្ធទៅនឹងវិធានការការពារជាលម្អិតនេះ សូមឲ្យលោកប្រធានអនុញ្ញាតឲ្យគាត់និយាយក្នុងសវនាការអសាធារណៈ។ សូមអរគុណលោកប្រធាន។

[១៣:៥៣:១០]

ហើយចំណុចមួយទៀត ប្រសិនបើ -- ដែលស្នើឡើងដោយជាពិសេសសហការីរបស់ខ្ញុំ អេលីហ្សាបេត ស៊ីម៉ុនណូហ្វត ប្រសិនបើមានលទ្ធភាព លោក ស សារិន នឹងត្រូវស្ដាប់សក្ខីកម្មពាក់ព័ន្ធទៅនឹងភស្តុតាងបន្តទៀត ស្នើសុំឲ្យមានជាសវនាការជាសម្ងាត់នៅក្នុងការស្ដាប់ភស្តុតាងជាបន្ត ប្រសិនបើមាន។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយមុននឹងសម្រេចស្តាប់នូវសំណើសុំរបស់លោក អង្គជំនុំជម្រះចង់សួរបញ្ជាក់បន្ថែមបន្តិចលោក ស សារិន។ ព្រឹកមិញលោកបានទទួលនូវឯកសារមួយដែលជាឯកសារកំណត់ត្រានូវកិច្ចសម្ភាសន៍ដែលធ្វើឡើងដោយមន្ត្រីស៊ើបអង្កេតនៃមជ្ឈមណ្ឌលឯកសារកម្ពុជាចុះថ្ងៃទី០៥ ទី០៦ ខែឧសភា ឆ្នាំ២០០៩កន្លងមក ដែលបានធ្វើការកត់ត្រាចម្លងចេញពីបទសម្ភាសន៍ ដែលអាត់សំឡេងនោះ ហើយព្រឹកមិញនេះ គឺលោកបានបញ្ជាក់ហើយថា ឯកសារនេះលោកបានធ្លាប់បានទទួលមួយច្បាប់ពីមជ្ឈមណ្ឌលឯកសារកម្ពុជា គឺឯកសារ D230/1.1.874c។

[១៣:៥៤:៤៦]

សំណួរសួរថា តើលោក សារិន តើលោកបានពិនិត្យ បានសិក្សាឯកសារនេះឡើងវិញហើយឬនៅ? ហើយតាមខ្លឹមសារនៃឯកសារដែលលោកបានពិនិត្យមើល ឬក៏បានអាននូវឯកសារដែលបានជូនចំពោះលោកព្រឹកមិញនេះ តើខ្លឹមសារនៃឯកសារនេះ វាមានចំណុច មានការត្រឹមត្រូវទៅនឹងអ្វីដែលលោកបានផ្តល់សក្ខីកម្មចំពោះមុខអ្នកស៊ើបអង្កេតកន្លងមកដែរឬទេ?

**លោក ស សារិន៖**

បាទ ត្រឹមត្រូវ។

**ប្រធានអង្គជំនុំ៖**

លោកបានអានវាទេ បានពិនិត្យវាឡើងវិញទេ ឯកសារដែលបានផ្តល់ជូនលោកនៅចំពោះមុខលោកនាពេលនេះ -- ឥឡូវនេះ?

**លោក ស សារិន៖**

អត់ដែលបានអាន ក៏ប៉ុន្តែខ្ញុំទទួលស្គាល់ថា ខាងឌី.ស៊ី.ខេម គេធ្វើការគឺពិតប្រាកដហើយ។

[១៣:៥៦:០៨]

*(ចៅក្រមពិភាក្សាគ្នា)*

[១៣:៥៩:៣៣]

**ប្រធានអង្គជំនុំ៖**

លោក ស សារិន! សំណួរមួយខ្លីទេ មិនវែងទេ។ សំណួរសួរថា ប្រសិនបើអង្គជំនុំជម្រះស្តាប់សក្ខីកម្មរបស់លោកជាអសាធារណៈ តើលោកសុខចិត្តផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះដែរឬ ទេ?

[១៣:៥៩:៥៨]

**លោក ស សារិន៖**

សូមគោរពលោកប្រធាន! បើសិនជាមានសវនាការជាអសាធារណៈ ដោយមិនមានធ្វើតាមសំណូមពរខ្ញុំពីព្រឹកមិញទេ ខ្ញុំបាទសូមបដិសេធអត់ធ្វើនិយាយអ្វីទាំងអស់ ទោះបីជាអសាធារណៈក៏ដោយ ជាសាធារណៈក៏ដោយ។

**ប្រធានអង្គជំនុំ៖**

សូមកុំអាលសិនលោកមេធាវី។ ភាគីចោទប្រកាន់ហ្នឹងគាត់មានផ្តល់មតិយោបល់មុនណ៎ះ លើបញ្ហានេះដើម្បីភាគីខាងការពារហ្នឹងនិយាយចុងក្រោយ អង្គជំនុំជម្រះនឹងសម្រេចលើបញ្ហានេះភ្លាមពីព្រោះនឹងឲ្យចប់នៅពេលឆាប់ៗនេះដើម្បីកុំឲ្យនៅបញ្ហាហ្នឹងនៅដដែល។

សូមអញ្ជើញលោកភាគី សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងសហព្រះរាជអាជ្ញា តើមានមតិយោបល់យ៉ាងម៉េចលើបញ្ហានេះ? ឥឡូវច្បាស់លាស់ហើយ ជំហររបស់អ្នកដើមបណ្តឹងរដ្ឋប្បវេណីរូបនេះគឺស្តាប់បានច្បាស់លាស់ហើយ ទោះបីអសាធារណគឺគាត់មិនផ្តល់សក្ខីកម្មទេ គឺទាល់តែចាត់វិធានការធានារក្សាការពារដូចគាត់បានលើកឡើងពីព្រឹកមិញ។ ព្រឹកមិញគាត់បាននិយាយហើយ ខ្ញុំរំឭកឡើងវិញ គឺគាត់ស្នើសុំឲ្យអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាចាត់វិធានការការពារគាត់រហូតអស់មួយជីវិត។

[១៤:០១:៣៣]

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន ខ្ញុំគិតថា ជាការសំខាន់ ប្រសិនបើអនុញ្ញាតឲ្យគាត់បញ្ជាក់បន្ថែមទៀតអំពីខ្លឹមសារនៃការស្នើសុំរបស់គាត់បន្ថែមទៀត ដើម្បីឲ្យខ្លឹមសាររបស់គាត់ត្រូវបាននិយាយលម្អិតហើយត្រូវបានស្តាប់។ អ៊ីចឹងនេះជាអ្វីដែលខ្ញុំស្នើសុំ ហើយ-- បាទ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះមិនចាំបាច់ស្តាប់នេះទេ ព្រោះច្បាស់លាស់ហើយ។ សំខាន់គឺដើមបណ្តឹងរដ្ឋប្បវេណីខ្លួនឯងបានសម្រេចចិត្តច្បាស់លាស់ហើយ យើងអត់ឲ្យទាន់គាត់និយាយមូលហេតុទេ ប្រសិនបើគាត់យល់ព្រម ប៉ុន្តែគាត់នឹងបង្ហាញពីមូលហេតុ។ ហើយគាត់ស្នើសុំនេះជាអសាធារណៈ ទើបយើងធ្វើដូច្នេះ ប៉ុន្តែអំមិញគឺគាត់បានបង្ហាញជំហរច្បាស់លាស់ហើយ។ មានបញ្ហាផ្សេងទៀតសូមអាចលើក

ឡើងបាន។

[១៤:០២:៤២]

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន។ គ្រាន់តែសូមបញ្ជាក់ថា ព័ត៌មានដែលគាត់មាន គឺជាព័ត៌មានដែលល្អ ហើយដែលសំខាន់សម្រាប់រឿងក្ដីនេះ ហើយដែលជាគន្លឹះនៃសំណុំរឿងផងដែរ។ ដូច្នេះគួរតែធ្វើយ៉ាងណាឲ្យគាត់ផ្ដល់ព័ត៌មាននេះដោយ បើអាចធ្វើបាន សូម -- ខ្ញុំមានតែប៉ុណ្ណឹង។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកចៅក្រម ហ្វាង់ម៉ាក ដើម្បីសួរបញ្ជាក់ដើមបណ្ដឹងរដ្ឋប្បវេណីបន្ថែមឲ្យច្បាស់ជៀសវាងពេលវេលាអូសបន្លាយ។

**ចៅក្រម ហ្វាង់ម៉ាក ឡាវ៉ែន៍៖**

បាទ សូមអរគុណលោកប្រធាន។

ខ្ញុំសូមសួរទៅដើមបណ្ដឹងរដ្ឋប្បវេណីមួយសំណួរ។ លោក ស សារិន តើលោកអាចបញ្ជាក់បានជូនតុលាការបានទេថា តើវិធានការការពារណាមួយដែលលោកចង់ទទួលបាននោះ? ព្រោះថាយើងបានស្ដាប់ឮថា លោកថា អង្គការសហប្រជាជាតិហើយនិងរាជរដ្ឋាភិបាលកម្ពុជានោះអាចចេញវិធានការការពារ។ ក៏ប៉ុន្តែខ្ញុំចង់ដឹងថា តើលោករូបលោកផ្ទាល់នេះចង់បានវិធានការការពារបែបណាដែរ?

**ប្រធានអង្គជំនុំ៖**

តំណាងសហព្រះរាជអាជ្ញាអង្គុយចុះសិន ចាំឲ្យដើមបណ្ដឹងរដ្ឋប្បវេណីឆ្លើយតបទៅនឹងសំណួររបស់ចៅក្រមជាមុនសិន។

[១៤:០៤:២៧]

**លោក ស សារិន៖**

អរគុណលោកចៅក្រម។ គឺខ្ញុំសូមការការពារនេះពីសមត្ថកិច្ច ប៉ូលិសក៏បាន ប៉េអឹមក៏បាន ឲ្យតែកងកម្លាំងប្រដាប់អាវុធ ប្រហែលជាគ្នាបួននាក់ លុះត្រាខ្ញុំអស់ជីវិត។ ហើយចំពោះបៀវត្សរ៍គឺខ្ញុំអត់មានចេញលុយឲ្យទេ អានេះជាប្រាក់ខែខាងក្រុមការងារ ខាងអ្នកការពារទេ ខ្ញុំនិយាយឲ្យអស់សាច់រឿងបាយទឹកម្ហូបអាហារ ខ្ញុំអត់មានទទួលទេ។ រីឯ ខ្ញុំក៏អត់សុំអីពីតុលាការ ពីរដ្ឋដែរ ខ្ញុំបាយខ្លួនខ្ញុំ ទឹកខ្លួនខ្ញុំ

ទេ។ អាហ្នឹងនិយាយឲ្យអស់សាច់រឿង តែប៉ុណ្ណឹងទេ។ សូមអស់លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ!

[១៤:០៥:៣៧]

**លោក ឃីត រេយ៍ន័រ៖**

សូមអរគុណលោកប្រធាន ដែលបានផ្តល់ឱកាសឲ្យខ្ញុំ។ ខ្ញុំសូមអនុញ្ញាតជម្រាបថា ដំណាក់កាលដំបូងនៅទីនេះ គឺលោក ស សារិន គប្បីផ្តល់សក្ខីកម្មជាសម្ងាត់ ហើយដឹកនាំដោយសហមេធាវីនាំមុខ ដោយខ្ញុំ ឬដោយចៅក្រម ហើយនិងបន្ទាប់មក ដោយមេធាវីការពារក្តី។ ហើយនីតិវិធីនេះ គប្បីតែត្រូវអនុវត្តតាមលំដាប់នេះ។ រីឯសំណើសុំវិធានការការពារ ដែលគាត់មានអារម្មណ៍ថាគាត់មានការភ័យខ្លាច ដែលគាត់មានការភ័យខ្លាចនោះ ដែលយើងនិយាយមកពេលនេះ គឺថាយើងបាននិយាយគ្នានៅក្នុងតុលាការសាធារណៈ។ ដូច្នេះហើយ គឺគប្បីតែធ្វើជាសម្ងាត់ទេការពិភាក្សានេះ។ ដូច្នេះ ការស្តាប់សំណួរចម្លើយ ហើយនិងការឆ្លើយរបស់គាត់ទៅចៅក្រមក៏ដោយ ចំពោះសំណួរដែលភាគីសួរក៏ដូចគ្នានោះដែរ ដែលទាក់ទងទៅនឹងថា តើវិធានការការពារអ្វីដែលសមស្រប? តើវិធានការអ្វីខ្លះ? បែបណាខ្លះ? តើអ្វីជាការពន្យល់ទៅដល់ដើមបណ្តឹងរដ្ឋប្បវេណីអំពីវិធានការ ប៉ុន្តែអ្វីដែលយើងធ្វើនោះ គឺយើងបានឮខ្លះមកហើយ ដូច្នេះគឺថាអាចនឹងបំព្រួញនីតិវិធីបាន គឺខ្ញុំសូមស្នើថា ឲ្យមានសវនាការជាអសាធារណៈ ដែលឲ្យភាគីទាំងអស់អាចសួរបានទៅលោក ស សារិន។ ពេលនោះ ទើបតុលាការអាចសម្រេចថា តើវិធានការណាមួយដែលអាចអនុវត្តបាន? អាចសមស្រប? ហើយនៅក្នុងការសម្រេចជាបញ្ចប់នោះ ប្រសិនបើមិនអាចប្រើវិធានការការពារបានទេ ថាតើភស្តុតាងដែលលោក ស សារិន នឹងឲ្យមកតុលាការហ្នឹង ធ្វើតាមវិធីណា។ ហើយខ្ញុំ ខ្ញុំសូមជម្រាបថា គប្បីតែមានដំណាក់កាលជាបន្តបន្ទាប់ ដែលថាធ្វើឲ្យភាគីទាំងអស់ និងចៅក្រមអាចចូលរួមបាននៅក្នុងដំណើរការស្តាប់សក្ខីកម្មរបស់គាត់។ ហើយដូចដែលខ្ញុំស្នើខាងដើម ដូចជាសហមេធាវីនាំមុខដែរ ថាឲ្យមានសវនាការជាអសាធារណៈ ដើម្បីឲ្យពួកគាត់អាចសួរបាន ហើយយើងខ្ញុំអាចសួរបាន ហើយបើធ្វើបែបនោះ គឺគោរពទៅតាមស្តង់ដារអន្តរជាតិនៅតុលាការ អាយ.ស៊ី.ធី.វ៉ាយ ផងដែរ។ ដូច្នេះហើយ គឺសូមឲ្យអង្គជំនុំជម្រះមេត្តាពិនិត្យពិចារណា និងសម្រេចទៅតាមវិធានផ្ទៃក្នុង ហើយនិងស្របទៅតាមច្បាប់ខំមិនឡ នោះផងដែរ។ សូមអរគុណ។

[១៤:០៨:២២]

**ប្រធានអង្គជំនុំ៖**

លោក វ៉ិចទ័រ កូប៉េ កុំអាល ឲ្យភាគីម្ខាងនិយាយឲ្យអស់សិន!

សូមអញ្ជើញ លោកសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី!

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

ខ្ញុំសូមរំឭកជាបឋម ថាមុននឹងធ្វើការកត់សម្គាល់របស់ខ្ញុំ។ កត់សម្គាល់ថា គឺជាដើមបណ្ដឹងរដ្ឋប្បវេណី មិនមែនជាសាក្សីទេ។ ដូច្នេះ គាត់មានមេធាវីរបស់គាត់ គឺថាយើងបាននិយាយជាមួយគាត់មួយរយៈហើយក្នុងពេលពិសាបាយថ្ងៃត្រង់នេះ។ ហើយយើងធ្វើអ្វីដែលយើងអាចធ្វើទៅបាន គឺថាយើងចង់ដឹងថាអ្វីដែលគាត់ចង់បាន ហើយហេតុអ្វីបានគាត់ចង់បាន? អ្វីដែលគាត់ចង់បាននោះ ដូច្នេះគឺសិទ្ធិរបស់មេធាវីដើមបណ្ដឹងរដ្ឋប្បវេណីក្នុងការធ្វើការងារនេះ មិនមែនសម្រាប់ភាគីទាំងអស់នោះទេ ទោះបីជាការធ្វើសវនាការជាអសាធារណៈក៏ដោយ។

អ៊ីចឹង សូមវិធានការការពារណាមួយនោះ គឺថាជាមេធាវីរបស់គាត់ជាអ្នកពិភាក្សា ហើយយើងមិនត្រូវពិភាក្សានេះ ជាមួយមេធាវី ឬក៏ភាគីផ្សេងទៀតនោះ។ ហើយនៅក្នុងច្បាប់បារាំង មិនមានចែងទេ ហើយនៅចំពោះមុខ អ.វ.ត.ក ឬក៏ចៅក្រមស៊ើបអង្កេត ឬក៏ចៅក្រមនៃអង្គជំនុំជម្រះក៏ដោយ។

[១៤:០៩:៤៧]

ក៏ប៉ុន្តែបើសិនជាតុលាការសម្រេចថា ពិភាក្សាអំពីវិធានការការពារនេះយ៉ាងណានោះ គឺថាត្រូវតែធ្វើជាអសាធារណៈ។ ហើយខ្ញុំអម្បាញ់មិញនេះ ខ្ញុំក្រោកឡើងចង់និយាយអម្បាញ់មិញ គឺថាចង់និយាយថាតើគាត់ចង់បានសវនាការបែបណា? ហើយអម្បាញ់មិញនេះយើងឃើញច្បាស់ហើយថាយើងត្រូវតែបើកសវនាការជាអសាធារណៈ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយអង្គជំនុំជម្រះទំនងជាយល់ដូច្នេះ ទើបអង្គជំនុំជម្រះផ្ដល់ឱកាសជូនទៅសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីមុនពេលអាហារថ្ងៃត្រង់ ដើម្បីធ្វើការសម្របសម្រួលបញ្ចុះបញ្ចូលពន្យល់ដល់កូនក្ដីរបស់ខ្លួន មុនពេលដំណើរការជាបន្ត។

[១៤:១០:៤៤]

អំមិញគឺបានរាយការណ៍រួច អង្គជំនុំជម្រះបានសួររួចហើយ។ អ៊ីចឹងខាងសហមេធាវីនាំមុខជាតិបានឆ្លើយតបរួចហើយ ថាលទ្ធភាពនេះគឺខ្លួនមិនអាចសម្របសម្រួល ឬបញ្ចុះបញ្ចូលពន្យល់ឲ្យដើម

បណ្ដឹងរដ្ឋប្បវេណីនេះឲ្យផ្ដល់សក្ខីកម្មបានទេ ដោយគាត់ប្រកាន់ជំហរតាមសំណើសុំរបស់គាត់ ហើយ និងសំណើមួយទៀតសូមឲ្យធ្វើសវនាការជាសាធារណៈ ដើម្បីស្ដាប់ហេតុផលដែលគាត់សុំវិធានការដូច្នេះ។

អ៊ីចឹងហើយបានជាអង្គជំនុំជម្រះសួរ ថាប្រសិនបើធ្វើសវនាការជាអសាធារណៈ បើចាត់វិធានការត្រឹមធ្វើសវនាការអសាធារណៈ តើគាត់យល់ព្រមផ្ដល់សក្ខីកម្មដែរឬទេ? គាត់បានឆ្លើយថាគាត់អត់យល់ព្រមទេ ដរាបណាគឺចាត់វិធានការការពារដូចអ្វីដែលគាត់ស្នើសុំ គាត់បញ្ជាក់រួចហើយ។ ពិតមែនតែគាត់ដកអង្គការសហប្រជាជាតិចេញមែន ប៉ុន្តែពីព្រឹកគឺមានអង្គការសហប្រជាជាតិជាមួយរួមជាមួយរាជរដ្ឋាភិបាលកម្ពុជាចាត់វិធានការការពារគាត់ រហូតដល់គាត់ទទួលមរណភាព។ អំមិញគាត់បញ្ជាក់បន្ថែមទៀត ត្រូវការកម្លាំងយ៉ាងតិចបីឬបួននាក់ដែលជាបន្ទុករបស់រាជរដ្ឋាភិបាលចំណាយថវិកា ហើយទៅការពារជាតិអស់មួយជីវិត។

[១៤:១១:៥៨]

នេះជាបញ្ហា! សំណួរដែលយើងចង់សួរនោះសួរថា ប្រសិនបើជំហរគាត់អ៊ីចឹង តើស្ដាប់ហេតុផលរបស់គាត់វាមានប្រយោជន៍ បើសិនជាជំហររបស់គាត់ គាត់រក្សាសិទ្ធិក្នុងការសុំវិធានការការពារដូចការស្នើរបស់គាត់។ យើងអត់ចង់សួរហេតុផលអីទេ គ្រាន់តែសួរថាអ៊ីចឹងព្រមដែរទេ? ព្រោះភាគីពាក់ព័ន្ធហ្នឹងគឺ សុំឲ្យមានការធ្វើសវនាការជាទូទៅ យើងអាចកត់សម្គាល់ឃើញថា ភាគីទាំងពីរគឺសុំឲ្យធ្វើសវនាការជាអសាធារណៈ។ ហើយទោះបីជាយើងសួរស្ដាប់សក្ខីកម្មរបស់គាត់មួយព្រឹកមួយទៅហើយក៏ដោយ ដែលសាធារណជនបានស្ដាប់ បានឃើញ បានឮរួចទៅហើយក៏ វិធានការនេះគាត់ស្នើសុំបន្តទៅទៀតនេះវាចាត់ការយ៉ាងដូចម្ដេច? លោកតំណាងសហព្រះរាជអាជ្ញាបានបញ្ជាក់បញ្ហានេះហើយវាជាហេតុផលមួយប្លែក។

[១៤:១២:៥៤]

បញ្ហាទី២ បញ្ជាក់ឡើងវិញដើម្បីឲ្យវាច្បាស់លាស់។ ការចូលរួមក្នុងឋានៈជាដើមបណ្ដឹងរដ្ឋប្បវេណីគាត់ អង្គជំនុំជម្រះផ្ដល់វេទិកាតួនាទីជូនទៅអង្គភាពគាំពារសាក្សី និងអ្នកជំនាញទទួលបន្ទុកកិច្ចការនេះ។ របាយការណ៍សង្ខេបរបស់ខាងអង្គភាពគាំពារសាក្សី និងអ្នកជំនាញបានបង្ហាញច្បាស់លាស់អំពីការស្នើសុំនូវវិធានការការពារ ហើយនិងការដកវិញនូវវិធានការការពារ និងការប្រាស្រ័យទាក់ទងជាហូរហែរវាងមន្ត្រីនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ក្នុងការសម្របសម្រួលចង់ដឹងពីព័ត៌មាន

ជាមួយគាត់។ ជាចុងក្រោយគាត់បានសន្ទនាជាមួយនឹងខាងអង្គភាពគាំពារសាក្សី និងអ្នកជំនាញធ្លាប់បានចាត់បុគ្គលិកឲ្យទៅសន្ទនាជាច្រើនលើកជាមួយនឹងដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ ក្នុងកាលបរិច្ឆេទនៃផ្ដល់សក្ខីកម្មរបស់គាត់។ គ្មានចំណុចណាមួយដែលដើមបណ្ដឹងរដ្ឋប្បវេណីបានលើកឡើងថា គាត់មានក្ដីបារម្ភទាក់ទងនឹងការផ្ដល់សក្ខីកម្មនោះទេ។ កង្វល់ធំរបស់គាត់នោះ គឺការឃ្លាតឆ្ងាយពីចម្ការល្ពៅរបស់គាត់ក្នុងអំឡុងពេលប្រមូលផល។

[១៤:១៤:០២]

នេះសរុបមកវិញ បានន័យថាមិនមានព័ត៌មានអីស្ដីពីបញ្ហានៃវិធានការការពារទេ។ ហើយនៅក្នុងវិធាន២៩ទៀតសោត គឺបានបញ្ជាក់ច្បាស់លាស់អំពីវិធានការការពារតើសុំនៅពេលណា? រហូតដល់ពេលណាដើម្បីមានវិធានការការពារ។ ពិតមែនហើយវាមានករណីពិសេសនៅក្នុង២៩(៤)វាក្យខណ្ឌចុងក្រោយដែលចែងអំពី“ក្នុងករណីពិសេសអង្គជំនុំជម្រះអាចពិចារណាលើពាក្យសុំដែលដាក់យឺតយ៉ាវ”។ អំមិញនេះយើងចាត់ទុកថាជាការដាក់ស្នើសំណើសុំយឺតយ៉ាវ ទើបយើងលើកបញ្ហានេះមកពិចារណា។ ទោះបីការស្នើសុំមិនស្នើសុំមកអង្គជំនុំជម្រះក៏ដោយ ស្នើសុំទៅអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជាក៏ដោយ។ នេះជាហេតុនាំឲ្យមានការជជែក ពិភាក្សាលើបញ្ហានេះឈានទៅដល់ការសម្រេចបន្តិចទៀតនេះ។

[១៤:១៥:០៣]

*(ចៅក្រមពិភាក្សាគ្នា)*

[១៤:២២:២១]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះផ្ដល់ភារៈជូនទៅលោកស្រីចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍ ដើម្បីធ្វើការបញ្ជាក់លើបញ្ហាពាក់ព័ន្ធទៅនឹងសំណើសុំរបស់ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ។

សូមអញ្ជើញលោកស្រីចៅក្រម!

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន។ ដូចដែលលោកបានកត់សម្គាល់ថា ចៅក្រមបានពិភាក្សាលើសំណើរបស់សហព្រះរាជអាជ្ញាថា ការបើកសវនាការអសាធារណៈដើម្បីស្ដាប់ពីមូលហេតុរបស់ដើមបណ្ដឹងរដ្ឋប្បវេណីក្នុងការស្នើសុំ ចង់បានអ្វីដែលថាគាត់មិនចង់និយាយជាសាធារណៈនោះ ដើម្បីពិនិត្យមើល

សំណើរបស់គាត់អំពីវិធានការការពារ។ សំណើនោះគឺត្រូវបានជំទាស់ដោយសហមេធាវីនាំមុខ ប៉ុន្តែសហមេធាវីនាំមុខបានចង្អុលបង្ហាញថា បើសិនជាអង្គជំនុំជម្រះយល់ថា សមស្របដើម្បីបើកសវនាការអសាធារណៈ គឺជាជម្រើសមួយដែលល្អគប្បីធ្វើបែបនោះ ហើយយើងខ្ញុំក៏ចង់ស្តាប់ពីមេធាវីការពារក្តីអំពីចំណុចតូចចង្អៀតថាតើ តូចចង្អៀតថាតើ បើសិនជាយើងបើកសវនាការអសាធារណៈតាមសំណើដែលលើកឡើងដោយដើមបណ្តឹងរដ្ឋប្បវេណី តើមានបញ្ហាអ្វីដែលថាវិធីណា របៀបណាដែលគាត់អាចនឹងផ្តល់សក្ខីកម្មបន្ទាប់ពីយើងផ្តើមសវនាការអសាធារណៈនេះ។ មេធាវីការពារគាត់ថាអាចនឹងយល់បានពីអ្វីដែលលោកស្រីចៅក្រមបញ្ជាក់។ សូមអរគុណ។

[១៤:២៤:១៦]

**លោក វ៉ិចទ័រ កូប៉េះ**

សូមអរគុណលោកប្រធាន លោក លោកស្រីចៅក្រម ខាតវ៉ាយថ៍។ អំពីយើងខ្ញុំវិញ យើងយល់ច្បាស់ហើយ គឺថាដើម្បីរដ្ឋប្បវេណីបានសម្រេចចិត្តថ្ងៃនេះថាលើកឡើងពីសំណើដែលធ្វើឱ្យយើងមានការភ្ញាក់ផ្អើលដោយសារគាត់សុំវិធានការការពារ។ សាធារណជនតាមដានសវនាការនេះមួយព្រឹកមកហើយ។ ហើយពួកគាត់ក៏មានការភ្ញាក់ផ្អើលដែលអំពីសំណើនេះ។ ផលប្រយោជន៍ ឬក៏ប្រយោជន៍នៃតម្លាភាពក៏ជាលក្ខណៈសំខាន់ដែរ។ ប៉ុន្តែបើសិនជាសំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណីហ្នឹង គាត់អាចស្នើជាសាធារណៈ ហើយសាធារណជនក៏ចង់ដឹងថា តើច្បាប់ណាដែលយកមកអនុវត្ត? តើច្បាប់ករណីណាដែលត្រូវប្រើ? តើការពិនិត្យលើការវិនិច្ឆ័យ ការសម្រេចរបស់អង្គជំនុំជម្រះដូចម្តេច? គឺជាការងារដែលធានានូវតម្លាភាព គេចង់ដឹង។ ដូច្នេះគឺមានសេចក្តីសម្រេចមួយចំនួនទាក់ទងទៅនឹងវិធានការការពារដល់ដើមបណ្តឹងរដ្ឋប្បវេណី ថាតើព្រំដែនច្បាប់កម្រិតណា? ដូច្នេះតាមគំនិតរបស់ខ្ញុំគប្បីតែពិភាក្សានៅក្នុងតុលាការនោះឯង។ អ្វីដែលយើងប្រមើល៍មើលឃើញដែលត្រូវការពិភាក្សានោះ នៅក្នុងអសាធារណៈនោះ គឺវិធានការជាក់លាក់ អាចនឹងពិភាក្សា បើសិនជាតុលាការសម្រេចបែបនោះ ដូចជាបញ្ហាជាក់ស្តែងដែលគាត់លើកឡើងអំពីការភ័យខ្លាចជាក់ស្តែងរបស់គាត់ដែលគាត់ទទួលបានជាដើម ហើយនិងបញ្ហាផ្សេងទៀត ខុសពីហ្នឹងគឺគប្បីតែបើកដេញដោលជាសាធារណៈ ដូចដែលយើងធ្វើនៅថ្ងៃនេះ។ គឺបើចង់បើកសវនាការជាអសាធារណៈ គឺលើកលែងតែបញ្ហាជាក់លាក់ដូចដែលខ្ញុំលើកខាងដើមអំមិញ។ ដូច្នេះនេះគឺជាសំណើរបស់ខ្ញុំពីរនេះឯង។ សូមអរគុណបាទ។

[១៤:២៦:២៥]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញមេធាវីអន្តរជាតិការពារក្តីលោក ខៀវ សំផន!

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំដោយសង្ខេបទេទាក់ទងនឹងសវនាការអសាធារណៈនេះ យើងយល់ស្របនឹងមេធាវីលោក នួន ជា ឃើញថាមិនគួរធ្វើដូច្នេះទេ ពីព្រោះថាតាំងពីព្រឹកមកដើមបណ្តឹងរដ្ឋប្បវេណីបានបញ្ចេញមតិក្នុងសវនាការជាសាធារណៈ ហើយគាត់មិនមាន -- គាត់បង្ហាញថាមានការភ័យខ្លាច ហើយគាត់សុំ -- យើងមិនដឹងថាហេតុអីក៏និយាយជាសវនាការនោះទេ ព្រោះថាអសាធារណៈទេ ព្រោះថារហូតដល់ពេលនេះនោះគឺគាត់និយាយជាសាធារណៈហើយ។ ហើយយើងកុំគិតថាគ្មានមូលដ្ឋានណាដែលថានឹងបើកសវនាការអសាធារណៈនោះទេ បើសិនជាតាំងពីដើមមកនោះ គាត់ ឬក៏មេធាវីដើមបណ្តឹងរដ្ឋប្បវេណី រដ្ឋប្បវេណីខ្លួនឯងផ្ទាល់នុ៎ងបានលើកបញ្ហានេះតាំងពីដំបូងមកនោះ ទាក់ទងទៅនឹងវិធានការការពារគាត់នោះ យើងគួរតែធ្វើសវនាការអសាធារណៈ ក៏ប៉ុន្តែបើយើងនិយាយតាំងពីព្រឹកមកនោះ យើងនិយាយជាសាធារណៈទៅហើយ។ ហើយឥឡូវនេះបែរជាសូមបើកសវនាការអសាធារណៈវិញ ខ្ញុំថា ខ្ញុំសូមជំទាស់នឹងសំណើនេះលោកប្រធាន។

[១៤:២៨:០៤]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញលោកមេធាវីការពារជាតិការពារក្តីលោក ខៀវ សំផន!

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ បាទ សូមអនុញ្ញាតគោរពក្រុមប្រឹក្សាជំនុំជម្រះ អង្គសវនាការសាជាថ្មី។ ខ្ញុំបាទយល់ឃើញថា ការពិភាក្សាដេញដោលកន្លងមកនេះ ហាក់ដូចជាច្បាស់ហើយអំពីសំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណីលោក ស សារិន នេះ។

គោលជំហររបស់គាត់គឺច្បាស់ ត្រង់ថា ទោះបីជាសវនាការនោះធ្វើឡើងដោយសាធារណៈ ឬអសាធារណៈក៏ដោយ បើគ្មានវិធានការការពារសម្រាប់រូបលោកតាមសំណើសុំរបស់គាត់ទេហ្នឹង គឺគាត់មិនអាចឆ្លើយទេ។ បាទ អ៊ីចឹងចំណុចនេះគឺបង្ហាញជំហរច្បាស់ហើយ ហើយត្រង់ថាការពិភាក្សាអំពីសវនាការអសាធារណៈហ្នឹង ឬយ៉ាងណានោះ ខ្ញុំយល់ថាវាមិនចាំបាច់ទេ ហើយមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីគាត់ធ្វើកិច្ចការក៏ក្នុងនាមដើមបណ្តឹងរដ្ឋប្បវេណីដែរ បើអ៊ីចឹង បើជំហររបស់ដើម

បណ្ដឹងរដ្ឋប្បវេណីច្បាស់ដូច្នេះហើយ ខ្ញុំយល់ថាមិនចាំបាច់ឲ្យមានសវនាការអសាធារណៈដើម្បីឲ្យពិភាក្សាអំពីនីតិវិធី ឬវិធានការអ្វីណាទៀតទេ។ បាទ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវីជាតិ -- សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី! កម្រិតត្រឹមតែឆ្លើយតបបានហើយ មិនមែនឲ្យជជែកអីផ្សេងពីការឆ្លើយតបការលើកឡើងរបស់ភាគីម្ខាងទៀតទេ។

[១៤:២៩:៥៤]

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាននេះជាគោលបំណងរបស់ខ្ញុំ គឺគ្រាន់តែឆ្លើយតបតែប៉ុណ្ណោះ។ ជាការពិតអ្វីដែលកើតឡើងគឺកើតឡើងនៅពេលចុងព្រឹកមិញទេ ហើយសំណើរបស់យើងខ្ញុំ សម្រាប់សវនាការអសាធារណៈគឺសម្រាប់បន្តទៅទៀត ហើយជាពិសេស ពាក់ព័ន្ធទៅនឹងចំណុចសំខាន់ដែលជាគន្លឹះដែលធ្វើឲ្យលោក ស សារិន មានការព្រួយបារម្ភ។ ហើយដូច្នេះចំណុចនេះហើយ ដែលជាចំណុចដែលគាត់ ធ្វើឲ្យគាត់មានការព្រួយបារម្ភសម្រាប់ខ្លួនគាត់ ហើយដែលគាត់ -- ដែលយើងខ្ញុំយល់ថាបើក្នុងករណីដែលលោក ស សារិន នឹងត្រូវនិយាយបន្តទៀត ទោះនៅក្នុង ទោះថាមានវិធានការ ត្រូវចេញ ឬក៏ថាមិនចេញក៏ដោយ យើងខ្ញុំស្នើសុំឲ្យពិចារណាអំពីលក្ខខណ្ឌស្ដាប់បន្តទៀត។ នេះគឺគ្រាន់បញ្ជាក់ថា សំណើដែលខ្ញុំស្នើសុំឲ្យមានសវនាការជាអសាធារណៈ គឺតែក្នុងករណីដែលមានការស្ដាប់បន្តតែប៉ុណ្ណោះ។ បាទ សូមបញ្ជាក់បន្ថែមប៉ុណ្ណោះ សូមអរគុណ។

[១៤:៣១:២៤]

*(ចៅក្រមពិភាក្សាគ្នា)*

[១៤:៣៦:១៤]

**ប្រធានអង្គជំនុំ៖**

លោក ស សារិន! អង្គជំនុំជម្រះសូមជម្រាបលោកថា សំណើសុំរបស់លោកដែលបានសុំឲ្យអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាផ្ដល់កិច្ចការពារសន្តិសុខសម្រាប់គាត់ អ៎! សម្រាប់លោករូបលោក ចាប់ពីពេលនេះទៅរហូតដល់អស់មួយជីវិតនោះ គឺមិនមានហេតុផលសមស្របទេ។ ហើយអង្គជំនុំជម្រះសូមជម្រាបផងដែរថា អង្គជំនុំជម្រះគ្មានយុត្តាធិការសម្រេចតាមសំណើសុំរបស់លោកបែបនេះទេ។ ហើយអង្គជំនុំជម្រះក៏មិនសម្រេចផ្ដល់នូវវិធានការផ្សេងទៀតជូនលោកដែរ។

ហេតុដូច្នេះអង្គជំនុំជម្រះសម្រេចបញ្ចប់ការស្តាប់សក្ខីកម្មរបស់លោកត្រឹមនេះ ហើយអង្គជំនុំជម្រះសូមអរគុណចំពោះលោក ស សារិន ហើយសូមលោកអញ្ជើញត្រឡប់ទៅលំនៅដ្ឋានរបស់លោក ឬក៏គោលដៅណាដែលលោកមានបំណងចង់ទៅបានហើយ ហើយពេលនេះលោកចាកចេញពីបន្ទប់សវនាការបានហើយ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងមន្ត្រីនៃអង្គភាពគាំពារសាក្សី និងជំនាញក្នុងការជូនលោក ស សារិន ដែលដើមបណ្តឹងរដ្ឋប្បវេណីវិលត្រឡប់ទៅវិញចុះ។

*(សាក្សីចាកចេញពីបន្ទប់សវនាការ)*

អង្គជំនុំជម្រះសូមជម្រាបថា កិច្ចបន្តនៅសវនាការថ្ងៃនេះគឺពេលវេលាដែលនៅសល់នេះអង្គជំនុំជម្រះដំណើរការស្តាប់សក្ខីកម្មសាក្សី ដែលមានរហស្សនាម TCW-752 ហើយដែលនឹងផ្តើមសួរដេញដោលដោយតំណាងសហព្រះរាជអាជ្ញាមុនភាគីដទៃទៀតនៃរឿងក្តី ក្រោយពីឈប់សម្រាក។

ឥឡូវនេះដល់ពេលសមស្របនឹងឈប់សម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីនេះទៅនេះរហូតដល់ម៉ោងបី សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១៤:៣៨ នាទី ដល់ម៉ោង ១៥:០៥ នាទី)*

[១៥:០៥:១៤]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយជាបន្តនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម TCW-752 ដូចអង្គជំនុំជម្រះបានជម្រាបភាគី និងសាធារណជនកាលពីព្រឹកមិញរួចហើយ។ ហើយសូមបញ្ជាក់ម្តងទៀតលោក ផារី តើសាក្សីរូបនេះមានចំណងញាតិលោកហិត ឬញាតិពន្ធជាមួយនឹងភាគីនៃរឿងក្តីដែរឬទេ? ហើយគាត់បានស្បថរួចហើយឬនៅ?

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន! តាមការបញ្ជាក់របស់សាក្សីរូបនេះ គាត់បញ្ជាក់ថា គាត់មិនមាន

ចំណងញាតិលោហិត ឬញាតិពន្ធជាមួយនឹងជនជាប់ចោទ នួន ជា និង លោក ខៀវ សំផន ឬភាគីដើមបណ្ដឹងរដ្ឋប្បវេណីណាមួយដែលត្រូវបានទទួលស្គាល់នៅក្នុងរឿងក្ដីនេះទេ។ ហើយសាក្សីរូបនេះក៏បានធ្វើសម្បថនៅចំពោះមុខលោកតាដំបងដែកកាលពីព្រឹកមិញរួចហើយផងដែរ។ សាក្សីរូបនេះមានមេធាវីឈ្មោះ មឿន សុវណ្ណ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ មន្ត្រីរដ្ឋបាលតុលាការអញ្ជើញសាក្សី រួមនឹងមេធាវីប្រឹក្សាសាក្សីចូលមកកាន់កន្លែងផ្ដល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការ!

*(សាក្សី និងមេធាវីប្រឹក្សាចូលក្នុងបន្ទប់សវនាការ)*

[១៥:០៧:៤៩]

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សួស្ដីលោកសាក្សី! តើលោកឈ្មោះអី?

**លោក អ៊ុង ឆាត់៖**

**ឆ៖** បាទ សូមគោរពលោកប្រធាន។ ខ្ញុំបាទឈ្មោះ អ៊ុង ឆាត់។

**ស៖** អរគុណលោក អ៊ុង ឆាត់ តើលោកមានអាយុប៉ុន្មានឆ្នាំហើយ? លោក អ៊ុង ឆាត់ កុំអាលទាន់ឆ្លើយតប លោកមើលក្បាលមីក្រូហ្វូនដែលឲ្យភ្លើងសញ្ញាក្រហមបែបនេះ គឺមានន័យថាក្បាលមីក្រូនោះប្រតិបត្តិការហើយ អ៊ីចឹងលោកអាចនិយាយបាន ទើបប្រព័ន្ធសំឡេងរបស់លោកចូលទៅប្រព័ន្ធស្ដាប់សំឡេងនៅក្នុងទីនេះ ក៏ដូចជាកន្លែងសាធារណជន ជាពិសេសគឺអង្គភាពបកប្រែភាសាទៅជាភាសាបារាំង និងភាសាអង់គ្លេស។ អ៊ីចឹងពេលដែលស្ដាប់ចម្លើយរួចលោកអង់បន្តិច ដើម្បីឲ្យការបកប្រែហ្នឹងបានពេញលេញ បានត្រឹមត្រូវ។

តើលោកមានអាយុប៉ុន្មានឆ្នាំហើយ?

[១៥:០៨:៤៧]

**ឆ៖** អាយុ៦២ ឆ្នាំ។

**ស៖** សព្វថ្ងៃនេះ តើលោកមានទីលំនៅនៅកន្លែងណា?

**ឆ៖** ខេត្តពោធិ៍សាត់។

**ស៖** លោក អ៊ុង ឆាត់ តើលោកប្រកបមុខរបរអ្វី?

**ឆ៖** ធ្វើស្រែ។

**ស៖** អរគុណ។ តើលោកបាន អាចប្រាប់ដល់សវនាការអំពីឈ្មោះឪពុកបង្កើត ម្ដាយបង្កើត ប្រពន្ធលោកដល់អង្គជំនុំជម្រះបានដែរទេ? ហើយលោកមានកូនប៉ុន្មាននាក់?

**ឆ៖** ខ្ញុំបាទមានកូនប្រាំនាក់។

**ស៖** ឪពុកបង្កើតរបស់លោកឈ្មោះអី?

**ឆ៖** ឪពុកបង្កើតឈ្មោះ ម៉ៅ ឈិត។

**ស៖** អរគុណ។ ចុះម្ដាយបង្កើតរបស់លោក គាត់ឈ្មោះអី?

**ឆ៖** ម្ដាយបង្កើតឈ្មោះ តាត ប៊ិន។

[១៥:០៩:៥៥]

**ស៖** ចុះប្រពន្ធរបស់លោក គាត់ឈ្មោះអី?

**ឆ៖** ឈ្មោះ មិត្ត សែម។

**ស៖** អរគុណលោក អ៊ុង ឆាត់។ តាមរយៈរបាយការណ៍របស់ក្រឡាបញ្ជីសវនាការអម្បាញ់មិញនេះ ថាតាមសមត្ថភាពដែលលោកអាចដឹង លោកមិនមានចំណងញាតិលោហិត ឬក៏ញាតិពន្ធជាមួយនឹងភាគីដែលទទួលយកជាដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងរឿងក្ដីនេះទេ។ ហើយក៏មិនជាប់លោហិត ឬក៏ញាតិពន្ធជាមួយនឹងជនជាប់ចោទ នួន ជា និង ខៀវ សំផន ដែរ។ ហើយតាមរបាយការណ៍ដដែលនេះថាលោកបានធ្វើសម្បថរួចហើយមុនពេលចូលមកកាន់បន្ទប់សវនាការនេះ។ តើពិតមែនដែរឬទេ?

**ឆ៖** បាទ។

[១៥:១០:៤៣]

**ស៖** អង្គជំនុំជម្រះសូមប្រាប់អំពីសិទ្ធិ និងករណីយកិច្ចរបស់លោកក្នុងនាមលោកជាសាក្សី។ លោក អ៊ុង ឆាត់ ក្នុងនាមលោកជាសាក្សីនៅកិច្ចដំណើរការសវនាការចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនាពេលនេះ លោកអាចបដិសេធក្នុងការឆ្លើយតបទៅនឹងសំណួរ ឬក៏សុំឲ្យលោកធ្វើអត្ថាធិប្បាយណាមួយ ឬច្រើនដែលនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង សិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង។ ហើយទន្ទឹមនឹងនេះក្នុងនាមលោកជាសាក្សីមានករណីយកិច្ចត្រូវឆ្លើយតបទៅនឹងសំណួរទាំងឡាយដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះសួរចំពោះលោក លើកលែងតែករណីសំណួរ ឬក៏អំណះអំណាងដែលគេបាន

សួរ និងបានសុំឲ្យលោកធ្វើអត្ថាប្បាយហ្នឹងមាននាំឲ្យដាក់ពិរុទ្ធភាពលោកខ្លួនឯង។ ហើយលោកជាសាក្សីត្រូវតែឆ្លើយការណ៍ណាដែលពិត ដែលលោកបានឃើញ បានដឹង បានឮ បានចាំ ឬធ្លាប់មានបទពិសោធន៍ជួបប្រទះ ឬបានធ្វើការសង្កេតដោយផ្ទាល់នូវព្រឹត្តិហេតុ ហេតុការណ៍ទាំងឡាយដែលពាក់ព័ន្ធទៅនឹងសំណួរដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះសួរលោក។ លោក អ៊ឹង ឆាត់ តើលោកធ្លាប់ផ្តល់សក្ខីកម្ម អំ! កិច្ចសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតដែរឬទេក្នុងអំឡុងពេលប៉ុន្មានឆ្នាំនេះ? ហើយប្រសិនបើផ្តល់ឲ្យ ផ្តល់ឲ្យរយៈពេលប៉ុន្មានដង ហើយធ្វើនៅកន្លែងណា? ធ្វើនៅពេលណា?

[១៥:១២:១៣]

**ឆ៖** បាទ គឺរយៈពេលទៅសម្ភាសសួរខ្ញុំ រយៈពេលពីរដង។

**ស៖** ធ្វើនៅកន្លែងណា? ហើយនៅពេលណាដែរ នៅក្នុងឆ្នាំណា? ហើយនៅកន្លែងណា លោកចាំទេ?

**ឆ៖** ខ្ញុំបាទ មិនបានចាំថ្ងៃខែទេ ពីព្រោះវាយូរឆ្នាំដែរ។ លើកទី១ នៅឯភូមិកំណើតរបស់ខ្ញុំ ផ្ទះកំណើតខ្ញុំ ហើយលើកទី២ មកនៅឯ ជាប់នៅខេត្តពោធិសាត់។

**ស៖** បាទអរគុណ។ ហើយមុនពេលចូលមកផ្តល់ ចូលមកចំពោះមុខអង្គជំនុំជម្រះនៅពេលនេះ តើលោកបានពិនិត្យមើល ឬបានអាន ឬបានស្តាប់ការអានពីបុគ្គលណាម្នាក់នូវកំណត់ហេតុស្តាប់សក្ខីកម្មរបស់លោក ដែលលោកបានធ្វើជាមួយអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតកន្លងមកដើម្បីរំឭកការចងចាំដែរឬទេ?

**ឆ៖** បាទ ខ្ញុំមិនបានអាន ព្រោះខ្ញុំមិនបានដឹងថា មិនដឹងជាសួរអំពីចំណុចអីមុន ម្ល៉ោះហើយខ្ញុំអត់ទាន់បានដឹងថាសួរ ត្រៀមចម្លើយនេះ។ ទាល់តែបានចម្លើយមក បានខ្ញុំបានឆ្លើយកើត។

**ស៖** អង្គជំនុំជម្រះមិនសួរអ៊ីចឹងទេ។ សួរថា លោកមកនេះ មុននឹងផ្តល់ ចូលមកដល់កន្លែងសក្ខីកម្មនេះ លោកបានមើលនូវកំណត់ហេតុដែលលោកផ្តល់សក្ខីកម្មឲ្យអ្នកស៊ើបអង្កេតនៅខេត្តពោធិសាត់កាលពីប៉ុន្មានឆ្នាំមុនហ្នឹងដែរឬទេ ដើម្បីរំឭកការចងចាំនូវពាក្យពេចន៍ទាំងឡាយនូវសម្តីដែលលោកបានផ្តល់សក្ខីកម្មកាលពី ពីរបីបួនឆ្នាំមុននោះ។ តើលោកបានអាន ឬក៏បានស្តាប់អ្នកណាអានឲ្យលោកស្តាប់ដែរឬទេ?

[១៥:១៤:០៩]

**ឆ៖** បាទ ខ្ញុំបានអានមើលខ្លួនឯងខ្លះៗដែរ។

**ស៖** បាទ អរគុណ។ បើតាមសមត្ថភាពដែលលោកដឹង និងចងចាំថាតើលោកអាចបញ្ជាក់បានទេ ថាកំណត់ហេតុដែលស្តាប់ចម្លើយដែលលោកបានអាន ដើម្បីរំឭកការចងចាំនេះ គឺពិតជាត្រឹមត្រូវ និងស៊ីសង្វាក់គ្នាស្របគ្នាទៅនឹងចម្លើយដែលលោកបានផ្តល់កិច្ចសម្ភាសន៍ជាមួយអ្នកស៊ើបអង្កេតកាលពីប៉ុន្មានឆ្នាំមុននោះដែរឬទេ?

**ឆ៖** បានចាំខ្លះៗ ដោយចំណុចដែលបានសម្ភាសពីដើម គឺបានចាំមួយចំនួនធំ។

**ប្រធានអង្គជំនុំ៖**

បាទ ជាបន្តទៅនេះ អង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ មុនភាគីដទៃទៀតនៃរឿងក្តី។

**កញ្ញា សុង ឆវ័ន្ត៖**

ចាស សូមអរគុណលោកប្រធាន។ ជាបឋមសូមគោរពលោកប្រធាន។ សូមគោរព លោក លោកស្រីចៅក្រម និងសូមគោរពអង្គសវនាការទាំងមូល។

[១៥:១៥:៣០]

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយកញ្ញា សុង ឆវ័ន្ត៖**

**ស៖** ជម្រាបសួរលោកសាក្សី នាងខ្ញុំឈ្មោះ សុង ឆវ័ន្ត ជាតំណាងសហព្រះរាជអាជ្ញាជាតិ ហើយអ្នកនៅអង្គុយជាប់ខ្ញុំនេះ គឺឈ្មោះ ឃីត រេយ៍ន័រ គាត់ជាតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ។ ពេលនេះ នាងខ្ញុំមានសំណួរមួយចំនួនចង់សាកសួរទៅលោក។ ហើយខ្ញុំនឹងចាប់ផ្តើមមុន បន្ទាប់មកសហការីអន្តរជាតិរបស់ខ្ញុំ និងចាប់ផ្តើមបន្ត។ សំណួរទី១ ដែលខ្ញុចង់សួរទៅលោក សួរថា តើលោកចាប់ផ្តើមបដិវត្តន៍ ចូលបដិវត្តន៍នៅឆ្នាំណាដែរ? ហើយពេលដំបូងហ្នឹង តើចូលនៅកន្លែងណា?

**លោក អ៊ុំង ឆាត់៖**

**ឆ៖** ខ្ញុំបាទ ចូលបដិវត្តន៍ហ្នឹង គឺមិនបានជាចាំឆ្នាំច្បាស់ទេ ប៉ុន្តែជាក្នុងអំឡុង៧៣។ ៧២, ៧៣ ហ្នឹង ព្រោះកាលនោះ គឺជម្លៀសទៅ មិនបានចាំ ចេះតែរត់ឡើង រត់ចុះ ទៅ ទៅនៅកន្លែងហ្នឹង មិនបានទទួលក្របខ័ណ្ឌអី គេចេះតែចាប់ញាត់ធ្វើទៅ ទៅនៅជាមួយហ្នឹង ប្រហែលជាអំឡុងឆ្នាំហ្នឹង។

**ស៖** ហើយពេលចូលបដិវត្តន៍ហ្នឹង តើនៅក្នុងខេត្តនិងស្រុក ឬភូមិ ឃុំណាដែរ លោកនៅចាំទេ?

**ឆ៖** ចាំ នៅខេត្តពោធិ៍សាត់ដដែល។

**ស៖** ពេលចូលបដិវត្តន៍មុនដំបូងនោះ តើលោកចូលបម្រើជាកងទ័ព ឬក៏មានតួនាទីអ្វីដែរ? ហើយប្រសិនបើមានតួនាទី តើតួនាទីអ្វី? ហើយអ្នកណាជាមេរបស់លោក? លោកចាំឈ្មោះទេ?

**ឆ៖** ចូលហ្នឹង គឺអាជ្ញាធរភូមិឃុំគេ ឲ្យចូលទៅបម្រើការងារជាកងទ័ព។

**ស៖** តើនៅកងទ័ពហ្នឹង លោកចាំទេ ថានៅក្នុងកងពល ឬក៏នៅក្នុងក្រុម ឬក៏នៅក្នុងអីដែរ ពេលហ្នឹង?

**ឆ៖** ជាកងទ័ពថ្នាក់តូចទេ គឺចំណុះឲ្យក្នុងឃុំៗ អ៎! តំបន់ ក្នុងតំបន់៧ មិនបានចាំទេ។

[១៥:១៨:២៥]

**ប្រធានអង្គជំនុំ៖**

ឈប់ៗ មានការអី? សូមរក្សាសណ្ដាប់ធ្នាប់។ បើមានបញ្ហាអី ឆ្បីបៗ ហើយដោះស្រាយជាបន្ទាន់ ជៀសវែងការរំខាននូវកិច្ចដំណើរការ។ សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា ហើយមុននឹងផ្ដល់ជូនទៅបន្តទៀតហ្នឹង គឺអង្គជំនុំជម្រះសូមជម្រាបជូនលោកសាក្សី លោក ឆាត់ ថាក្នុងករណីដែលលោកត្រូវការអញ្ជើញទៅបន្ទប់ទឹក ដោយមូលហេតុបញ្ហាការបត់ជើងតូចរបស់លោកអី គឺលោកសុំឲ្យសុំ ស្នើសុំមកអង្គជំនុំជម្រះណ៎ះ អង្គជំនុំជម្រះនឹងអនុញ្ញាតភ្លាម។

បាទ សូមអញ្ជើញ!

**កញ្ញា សុង ឆវ័ន្ត៖**

ចាស អរគុណលោកប្រធាន ខ្ញុំសូមអនុញ្ញាតបន្ត។

**សួរដោយកញ្ញា សុង ឆវ័ន្ត៖**

**ស៖** លោក អ៊ុង ឆាត់ លោកធ្លាប់បានផ្ដល់សក្ខីកម្ម ឬក៏ធ្លាប់បានឆ្លើយប្រាប់អ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតកាលពីឆ្នាំ២០០៩ ហើយឯកសារដែលខ្ញុំចង់ផ្ដោតជាសំខាន់នោះ គឺឯកសារ D125/176។ នៅក្នុងឯកសារនោះដែរ សំណួរដំបូងដែលអ្នកស៊ើបអង្កេតបានសួរលោកថា “តើមុនឆ្នាំ១៩៧៥ លោករស់នៅឯណា និងបានធ្វើអ្វី?” ខ្ញុំដកស្រង់ “ខ្ញុំធ្វើកងទ័ពខ្មែរក្រហមតាំងពីឆ្នាំ៧១ រហូតដល់ក្រោយរំដោះ១៧ មេសា ឆ្នាំ៧៥ គេបានរំសាយខ្ញុំ។ ទ័ពខ្មែរក្រហមរំដោះបានខេត្តពោធិ៍សាត់នៅថ្ងៃ១៩ ខែមេសា ឆ្នាំ៧៥។ មេកងពលឈ្មោះ តាខ្វែង។ ខ្ញុំជាមេកងតូចមានគ្នា៣០ នាក់ ស្ថិតនៅក្នុងកងពលរបស់ តាខ្វែង។ កងពលខ្ញុំវាយចូលពោធិ៍សាត់តាមច្រកទួលពោធិ៍ជ្រៃ។ ពេល

វាយចូលមកដល់ខេត្តពោធិ៍សាត់ កងខ្ញុំត្រូវបានចាត់តាំងឲ្យយាមកាមសាលាខេត្តពោធិ៍សាត់។ កងខ្ញុំទទួលបន្ទុកខាងរើផ្សារ ឯមួយកងទៀតទទួលបន្ទុកជម្លៀសប្រជាជន"។ សំណួរទី១ ដែលខ្ញុំសាកសួរទៅលោក ចង់សួរថាតើលោកចាំបានទេ នៅពេលណាដែលលោកបានទទួលបញ្ជាឲ្យរើផ្សារ ហើយអ្នកណាជាអ្នកឲ្យលោករើផ្សារ?

[១៥:២១:២០]

**ឆ៖** បាទ ក្នុងពេលរើផ្សារហ្នឹងគឺបញ្ជាកងធំរបស់ខ្ញុំហ្នឹងគេបញ្ជាឲ្យខ្ញុំទៅប្រាប់ប្រជាជននៅក្នុងផ្សារឲ្យចេញពីក្នុងផ្សារ មិនបានជម្លៀសដេញអីទេ គ្រាន់ថាឲ្យចេញ។

**ស៖** លោកនៅចាំឈ្មោះទេថា តើអ្នកណាជាបញ្ជា ហើយការបញ្ជាហ្នឹងគាត់បាននិយាយអ្វីខ្លះទាក់ទងនឹងការបញ្ជាឲ្យរើផ្សារហ្នឹង?

**ឆ៖** គឺចាំឈ្មោះ ដែលឈ្មោះ ធើយ ហើយនិងឈ្មោះ សារឹម តែបញ្ជារួចហើយគេក៏ដកកងទ័ពគេទៅស្រុកមោងវិញទៅ ហើយខ្ញុំក៏នៅយាមនៅហ្នឹង ឲ្យមួយកងតូចហ្នឹងនៅយាមសាលាខេត្ត។

**ស៖** តើ ធើយ និង សារឹម ហ្នឹងគាត់មានតួនាទីអ្វីដែរពេលនោះ?

**ឆ៖** គឺថ្នាក់គាត់ជាអនុសេនាធំ។

**ស៖** គាត់ជាអនុសេនាធំទាំងពីរនាក់ ឬក៏មានតួនាទីផ្សេងគ្នា ធើយ ហើយនិង សារឹម ហ្នឹង? ហើយគាត់អនុសេនាធំប្រចាំនៅកន្លែងណាដែរ?

[១៥:២៣:០១]

**ឆ៖** ហើយគាត់ទាំងពីរនាក់ហ្នឹង ប៉ុន្តែមិនដឹងអ្នកណាធំអ្នកតូច គាត់ដើរតែពីរនាក់ហ្នឹង គឺបទបញ្ជាស្មើៗគ្នា ហើយគាត់ក៏ចេញបាត់ទៅ ក៏មិនដឹងជាគាត់ទៅណា ឮថាទៅបាត់ដំបង ទៅមោង ខ្ញុំក៏តូចជាងគេអត់ដឹងដែរ។

**ស៖** ធើយ និង សារឹម ជាអនុសេនាធំហ្នឹង កាលគាត់មានទីតាំង ឬក៏ប្រចាំការនៅកន្លែងណាដែរ? លោកដឹងទេ?

**ឆ៖** អត់បានដឹងថាកន្លែងគាត់នៅទីណាទេ គ្រាន់តែគាត់មកប្រជុំហេតុផលនៅសាលាខេត្តហ្នឹងគាត់បង្ហាញប្រាប់តែឈ្មោះ ហើយឃើញតែម្ដងហ្នឹងទៅ ក៏គាត់ចេញទៅបាត់ទៅ ទៅខាងស្រុកមោងបាត់ទៅ។

**ស៖** ចុះលោកនៅចាំបានទេថា ទីកន្លែងណាឲ្យពិតប្រាកដ ដែលលោកបានទទួលបញ្ជាពីឈ្មោះ

ធើយ និង សារឹម ហ្នឹង?

[១៥:២៤:១២]

**ធ៖** នៅហ្នឹងសាលាខេត្តហ្នឹង ប្រជុំនៅជិតមាត់ទ្វារខ្លោងសាលាខេត្តពោធិ៍សាត់។

**ស៖** តើវាជាការទទួលបញ្ជានៅក្នុងកិច្ចប្រជុំដែលមានមនុស្សច្រើនចូលរួម ឬក៏មានតែលោក ឬក៏អ្នកផ្សេងណាខ្លះទៀតដែលលោកអាចចាំបានទេ?

**ធ៖** គឺខ្ញុំមិនអាចបានចាំអស់ទេ គឺក្នុងមួយកងតូចខ្ញុំហ្នឹងវាមកគ្រប់ខេត្ត គ្រប់កន្លែង ហើយប្រជុំហើយ ប្រជុំនៅពេលល្ងាចទៀត ខ្ញុំមិនបានជាចាំ ចាំតែគ្នាឯងដែលប្អូននាក់ហ្នឹង ក៏គេប្រមូលទ័ពទៅម៉ោង ខ្ញុំនេះក៏នៅកន្លែងហ្នឹង ខ្ញុំទៅសុំបទបញ្ជាពីមេទាហានខ្ញុំ ឋានៈទ្រើសជាងខ្ញុំហ្នឹង ខ្ញុំសូមមកផ្ទះទៅក៏ចប់គ្នាហ្នឹងទៅ ឆ្នាំហ្នឹង។

**ស៖** ចង់សួរបញ្ជាក់ដែរថា ក្នុងកិច្ចប្រជុំដែលមានបញ្ជាឲ្យរើផ្សារហ្នឹង តើអ្នកដែលចេញបញ្ជាហ្នឹងមានប្រាប់ពីមូលហេតុ ថាហេតុអ្វីឲ្យត្រូវរើផ្សារ ហើយថាតើរើដល់ពេលណា? មានផ្សារវិញ ត្រូវបង្កើតពេលណាអត់ទេពេលនោះ?

**ធ៖** បាទ ពេលនោះ គឺប្រជុំសម្ងាត់ នៅពេលហ្នឹងគឺថាឲ្យប្រាប់បងប្អូនប្រជានុរាស្ត្រហ្នឹងគឺចេញទៅនៅតាមគេហដ្ឋាន គឺមិនបានយកនូវសម្ភារៈអីធំដុំទៅទេ យកតែសម្ភារៈណាដែលអាចយោងទៅរួច គឺថាមិនបានបង្កើតជាផ្សារឬចាយលុយទៀតទេ។ តែប៉ុណ្ណឹងដោយសម្ងាត់ក្រុមការងារហ្នឹង។ តែប៉ុណ្ណឹង។

[១៥:២៦:១៤]

**ស៖** ចុះក្រោយពីបានទទួលបញ្ជាឲ្យរើផ្សារហើយ លោកនៅចាំទេថាថ្ងៃណាដែលលោកចាប់ផ្ដើមអនុវត្តបញ្ជាឲ្យរើផ្សារ ហើយចូលទៅរើផ្សារមួយណាដែរ?

**ធ៖** គឺពេលព្រឹកឡើងហ្នឹងតែម្ដង ម៉ោងប្រាំពីរព្រឹក។ ព្រឹកឡើង។

**ស៖** ចូលទៅរើផ្សារឈ្មោះអី? នៅកន្លែងណាខ្លះដែរលោក?

**ធ៖** នៅតាមមុខសញ្ញាខ្ញុំៗចេញពីសាលាខេត្តមក មកចាប់ដៃគ្នានៅចាំកណ្ដាលក្រុងហ្នឹង គេមុខសញ្ញាគេផ្សេង ពីជើង ពីត្បូង ពីលិច ពីកើតមក ខ្ញុំនៅតាមមុខសញ្ញាខ្ញុំចម្ងាយប្រហែលជា -- ផ្សារតូចដែរ ប្រហែលជាពាក់កណ្ដាលម្នាក់។ ១០០ម៉ែត្រពីគ្នាហ្នឹងទៅ ហើយគ្រាន់តែប្រាប់ទៅប្រជាជនឲ្យថយទៅ តែមិនបានទៅធ្វើគត់ធ្វើអីទេ អត់ទេ គ្រាន់តែប្រាប់ទៅ ប្រជាជនគេចេញបណ្ដើរៗ។

**សៈ** លោកនៅចាំឈ្មោះទេ ផ្សារហ្នឹងឈ្មោះអីដែរ?

**ឆៈ** ផ្សារពោធិ៍សាត់ហ្នឹងតែម្ដង។

[១៥:២៧:៤៤]

**សៈ** ចុះពេលដែលលោកចូលទៅប្រាប់ប្រជាជនឲ្យរើចេញពីផ្សារហ្នឹង តើលោកប្រើឧបករណ៍ ឬការផ្សព្វផ្សាយរបៀបម៉េចដែរ ដើម្បីប្រាប់ប្រជាជន? ហើយតើប្រជាជនហ្នឹង គាត់ឆ្លើយតបយ៉ាងម៉េចដែរជាមួយបទបញ្ជាដែលថាឲ្យរើផ្សារហ្នឹង?

**ឆៈ** បាទហ្នឹងគឺ គេមាន គេមេក្រុមគេផ្សេង។ គេប្រកាសមីក្រូ កូនមីក្រូតូចទៅ ខ្ញុំគ្រាន់តែដើរអមគេហ្នឹងដែរ កៀនៗគេហ្នឹង។ តែមិនបានឲ្យកាន់អាវុធ កាន់អីទេ។

**សៈ** ចុះពេលដែលរើផ្សារហ្នឹង តើរើដើម្បីអី? ហើយចុះអីវ៉ែអីវ៉ាន់នៅក្នុងផ្សារហ្នឹង តើគេចាត់ចែងរបៀបម៉េចដែរ?

**ឆៈ** អីវ៉ាន់ហ្នឹង គឺមិនបានអ្នកណាយកទេ គឺគ្រាន់តែប្រាប់ឲ្យតែប្រជាជនចេញ ចេញអស់ទៅដល់ស្អែកឡើងខ្ញុំក៏បានដឹងថាអីវ៉ាន់ហ្នឹង គេដឹកទៅខាងណាខាងណីទេ ព្រោះខាងខ្ញុំឲ្យទៅឈរជើងនៅកន្លែងដើមវិញ។

[១៥:២៨:១៤]

**សៈ** ចាស សូមអរគុណ។ នៅក្នុងកំណត់ហេតុដែលខ្ញុំបានអានឲ្យលោកមុននេះដែរ លោកបានប្រាប់ថា "កងទ័ពខ្មែរក្រហមរំដោះបានខេត្តពោធិ៍សាត់នៅថ្ងៃទី១៩ ខែមេសា ឆ្នាំ១៩៧៥"។ ចង់សួរលោកបញ្ជាក់ថា នៅថ្ងៃ១៩ មេសា ឆ្នាំ១៩៧៥ តើលោកបានធ្វើអ្វីខ្លះ? ហើយនៅទីណានៅពេលនោះ?

**ឆៈ** អាហ្នឹងគឺខ្ញុំបាទដឹងថាថ្ងៃ១៩ហ្នឹង គឺឡើងមកដល់ក្នុងក្រុង ក្នុងខេត្តហ្នឹង មកដល់សាលាខេត្តហ្នឹងហើយតែម្ដង។

**សៈ** តើលោកមានបានទទួលបញ្ជាដើម្បីចូលរួមជម្លៀសប្រជាជននៅខេត្តពោធិ៍សាត់ហ្នឹងទេ?

**ឆៈ** ខ្ញុំបាទអត់បានចូលរួមទេ ឲ្យនៅយាមនៅតែហ្នឹង នៅតែក្នុងរបងហ្នឹង ក្នុងសាលាខេត្តតែម្ដង។ អត់បានដឹងថា ដឹកនាំប្រជាជនទៅតាមតំបន់ តាមភូមិ តាមឃុំអី អត់។ ក្រុមគេផ្សេង។

**សៈ** ចុះលោកអាចប្រាប់បានទេថា ហេតុអ្វីបានជាលោកដឹងថាមានការជម្លៀសប្រជាជននៅពោធិ៍សាត់នៅថ្ងៃ១៩ មេសា ៧៥ហ្នឹង?

**ឆៈ** ថ្ងៃ១៩ហ្នឹង មិនទាន់បានជម្លៀសទេ។ ជម្លៀសដល់ព្រឹកឡើងនោះទេ។ គឺថ្ងៃ១៩ហ្នឹង គឺខ្ញុំ

បានចូលមកដល់កន្លែងហ្នឹង។ កន្លែងក្នុងខេត្តហ្នឹង ហើយទទួលបទបញ្ជាពេលល្ងាចហ្នឹង។ ព្រឹកឡើងបានឲ្យដើរប្រាប់ប្រជាជនពីល្ងាចឲ្យហើយ ដឹងខ្លួន។ ហើយដល់ពេលក្រុមគេជម្លៀស អាហ្នឹងប្រជាជនខ្លះក៏ជម្លៀស ខ្លះក៏គេទៅតាមដោយខ្លួនគេ។ ហើយដូចជាអ្នកណាមានមុខតួនាទីអីឲ្យទៅតាមមូលដ្ឋានរៀងខ្លួន។ អាហ្នឹងអីចឹង។

**ស៖** តើខ្ញុំយល់ឃើញត្រឹមត្រូវទេតាមអ្វីដែលលោកនិយាយមុននេះ លោកថាមានការដើរប្រាប់ប្រជាជនពីល្ងាច ថាព្រឹកឡើងនឹងមានការជម្លៀសអីចឹង ឬក៏យ៉ាងម៉េចដែរ? សូមលោកជួយបញ្ជាក់លើចំណុចនេះ?

[១៥:៣២:០៥]

**ឆ៖** ពីពេលល្ងាចហ្នឹង គឺបានទទួលតែបទបញ្ជាការប្រជុំរបស់មេបញ្ជាការតែប៉ុណ្ណោះទេ ព្រឹកឡើងបានចេញដំណើរការទៅផ្សព្វផ្សាយនៅតាម -- នៅក្នុងផ្សារ។ មិនបានបញ្ចេញយប់ហ្នឹងទេ។

**ស៖** ចុះពេលល្ងាចហ្នឹង លោកថាបានទទួលបទបញ្ជា តើបទបញ្ជាហ្នឹងជាបទបញ្ជាអ្វី ហើយមានខ្លឹមសារយ៉ាងម៉េចដែរបទបញ្ជានោះ?

**ឆ៖** គឺបទបញ្ជា គឺគេប្រជុំហ្នឹង គ្រាន់តែថាមិនឲ្យមាត់ក គឺធ្វើទៅតាមការណែនាំរបស់គេថាឲ្យគឺថាប៉ុនណា ឲ្យធ្វើប៉ុណ្ណឹង។ មិនបានសួរនាំ ឬក៏មិនបានឲ្យយើងមានយោបល់អីដេញដោលអីទេ គឺថាឲ្យធ្វើទៅតាមបទបញ្ជារបស់បញ្ជាការតែប៉ុណ្ណឹង។

[១៥:៣៣:១០]

**ស៖** ខ្ញុំចង់សួរបញ្ជាក់លោកថា តើបទបញ្ជាហ្នឹង មានន័យថាលោកបានទទួលបទបញ្ជា ឬក៏អ្នកបានចូលរួមប្រជុំពេលល្ងាចហ្នឹង បានទទួលបទបញ្ជាថាឲ្យមានការជម្លៀសប្រជាជននៅព្រឹកស្អែក ឬក៏យ៉ាងម៉េច?

**ឆ៖** ទទួលបទបញ្ជាទាំងអស់គ្នាហ្នឹង ដែលក្នុងមួយកងហ្នឹងគ្រាន់តែថាឲ្យយើងដើរប្រាប់ឲ្យប្រជាជនដឹងខ្លួន ហើយក៏ធ្វើដំណើរទៅតាមសម្រួលរបស់គាត់។ អត់មានរើដំបង្ខំចិត្តក្នុងពេលហ្នឹងតែប៉ុណ្ណឹង។

**ស៖** តើអ្នកណាជាអ្នកដាក់បទបញ្ជានោះ?

**ឆ៖** គឺសមមិត្ត ធើយ និងសារឹម។ ពីរនាក់ហ្នឹង គាត់មានយោបល់។

**ស៖** ចុះនៅក្នុងបទបញ្ជាហ្នឹងមានប្រាប់ទេថា ប្រសិនបើប្រជាពលរដ្ឋគាត់មិនព្រមចេញ តើត្រូវ

ធ្វើយ៉ាងម៉េចដែរ?

**ឆ៖** ក្នុងការបទបញ្ជាហ្នឹង គឺបាននិយាយតែប៉ុណ្ណឹង។ បើសិនជាព្រឹកឡើង យើងទៅប្រាប់បើប្រជាពលរដ្ឋគាត់មិនចេញទេ។ អាហ្នឹងគេថា ចាំគេមានផែនការនៅក្រុមគេផ្សេង។ ចំពោះក្រុមខ្ញុំឲ្យមកនៅកន្លែងវិញ។

[១៥:៣៤:៥៤]

**ស៖** ចុះផែនការដែលលោកនិយាយថា នឹងមានផែនការចំពោះប្រជាជនដែលមិនព្រមចេញហ្នឹង តើវាជាផែនការអ្វី? ហើយក្រុមណាជាអ្នកទទួលបន្ទុក?

**ឆ៖** ខ្ញុំបាទមិនបាន -- គេអត់បានប្រាប់ថាក្រុមណាៗទេ គឺគេលាក់ការណ៍អ៊ីចឹង គឺថាប្រាប់អ្នកណា គឺអ្នកហ្នឹងធ្វើ។ គឺមិនឲ្យបែកការណ៍ គឺថាកងខ្ញុំហ្នឹង គឺមួយកងខ្ញុំគ្រប់គ្រងតែប៉ុណ្ណឹង។ មិនបានឲ្យដឹងទៅខាងណា ខាងណីទៀត គេក៏អត់ប្រាប់ថា ក្រុមណាទៅក្រុមណា ព្រោះក្រុមវាច្រើនដែរ។

**ស៖** ចាស អរគុណលោក។ លោកចាំបានទេ ថាតើជម្លៀសប្រជាជននៅខេត្តពោធិ៍សាត់ហ្នឹង ត្រូវចំណាយពេលប៉ុន្មានដែរ ដើម្បីជម្លៀសប្រជាជនអស់?

**ឆ៖** ខ្ញុំបាទ តាមការដែលដឹងនិងចាំ មិនយូរដែរ ប្រហែលជារយៈពេល១ថ្ងៃ ឬ២ថ្ងៃ ចេញអស់ពីផ្សារដែរ។ វាអស់ពីផ្សារហ្នឹង ខ្ញុំក៏មិនបាននឹកចាប់អារម្មណ៍ថា ប៉ុន្មានថ្ងៃគេត្រូវធ្វើអីៗទៅ ខ្ញុំក៏ដេកនៅតែហ្នឹង រយៈពេលបីបួនថ្ងៃដែរ ស្រាប់តែអស់ប្រជាពលរដ្ឋទៅ នៅតែទ័ពគេផ្សេង គេអត់ឲ្យច្របូកច្របល់គ្នាទេ ព្រោះខ្ញុំនៅនឹងខេត្ត គឺយាមតែរបងខេត្តហ្នឹងតែម្តង មួយក្រុមពួកខ្ញុំ មួយកង។

[១៥:៣៦:៤៣]

**ស៖** ចុះទាហាន លន់ នល់ ពេលហ្នឹងមានការជម្លៀសទាហាន លន់ នល់ ទេ?

**ឆ៖** ឯចំណែកទាហាន លន់ នល់ ខ្ញុំដូចថាពេលនោះ គឺមិនបានឃើញឯកសណ្ឋានជាទាហានអីពិតប្រាកដទេ គឺស្លៀកពាក់ស៊ីវិល ហើយខ្ញុំនៅនឹងខេត្តហ្នឹង ខ្ញុំយាមនៅកន្លែងហ្នឹង ឃើញរយៈពេលចុងក្រោយដែលថា ខ្ញុំថាប្រហែលជាបី -- ២ថ្ងៃហ្នឹង មិនដល់បីទេ ២ថ្ងៃ។ ស្រាប់តែឃើញគេហៅ ឡានតូច ឡានធំហ្នឹងមកច្រើននៅក្នុងសាលាខេត្ត ហើយក៏នាំគ្នាឡើងទៅប្រជុំនៅក្នុងខេត្ត អ៊ំ! លើសាលាខេត្ត ស្រាប់តែចុះមកវិញ ក៏គេដឹកឡានមក ទៅក្រោមបាត់ៗទៅ មិនដឹងជារឿងហេតុអី ខ្ញុំក៏ពុំបានដឹង គេអត់ប្រាប់យើង ឲ្យគ្រាន់តែឈរមើលតែគេហ្នឹង។

**ស៖** ចុះលោកមានបានដឹងទេ តើគេជម្លៀសប្រជាជនឲ្យចេញពីខេត្តហ្នឹង មានគោលដៅទៅ

កន្លែងណាដែរ?

**ឆ៖** ឯចំណែកប្រជាជនទូទៅទាំងអស់នៅក្នុងក្រុងហ្នឹង គឺទៅតាមរៀងខ្លួន អត់មាន ដូចបង្ខំអូសយកទៅដាក់កន្លែងមួយដុបក៏អត់ដែរ គឺទៅតាមរៀងៗខ្លួន ព្រោះថានៅខេត្តពោធិ៍សាត់ មិនដឹងជាគេឡើងឡានទៅខាងណា អ្នកណានៅជិត តាមជិត អ្នកឆ្ងាយតាមឆ្ងាយ ដែលចម្លែកថា រឿងថាអ្នកមន្ត្រីរាជការហ្នឹង ឃើញយកឡានទៅដាក់ចោលនៅក្នុងសាលាខេត្តហ្នឹងជាច្រើន ហើយក៏ឡើងឡានមួយចំនួនទៅតាមផ្លូវទៅជើងវិញ ទៅខាងឯផ្លូវទៅកញ្ជ្រៃនោះវិញ។ ខ្ញុំបាននៅហ្នឹង ឃើញអ៊ីចឹង។

[១៥:៣៨:៤៧]

**ស៖** តើមានបានដឹងពីមូលហេតុទេ តើហេតុអ្វីបានជាពេលនោះ មានបញ្ហាឲ្យជម្លៀសប្រជាជនចេញពីខេត្ត?

**ឆ៖** ខ្ញុំក៏អត់បានដឹងអាផ្នែកនយោបាយរបស់គេដែរ ព្រោះខ្ញុំជាអ្នកកងទ័ព ខ្ញុំអត់បានប្រជុំអី ដឹងរឿងថា ប្រជាជនហ្នឹងត្រូវជម្លៀស ទៅធ្វើកិច្ចការយ៉ាងណា យ៉ាងណី អត់បានទទួលដឹងថា គេត្រូវនិយាយអំពីអីទេ ព្រោះខ្ញុំខាងទ័ព គឺគិតថាពីរឿងថា កាន់តែកាំភ្លើងទៅ មិនដឹងថាផែនការអី ដល់តែថ្ងៃហ្នឹង គ្រាន់តែដាក់បទបញ្ជាឲ្យតែប៉ុណ្ណឹង ប្រាប់ ខ្ញុំក៏មិនដឹងថា យកទៅណា ថាឲ្យនៅតាមស្រុកភូមិវិញស្មានថាធ្វើស្រែ ធ្វើភ្លឺដូចយើងធម្មតា អាងតែសន្តិភាពហើយ។ ខ្ញុំក៏អរ គេក៏អរ ទាំងអស់តែគ្នា។ ខ្ញុំអត់បានទទួលផែនការអីទាំងអស់។

**ស៖** ចុះនៅក្នុងអំឡុងពេលនៃការជម្លៀសហ្នឹង តើលោកឃើញស្ថានភាពរបស់ប្រជាជនដែលត្រូវគេជម្លៀសចេញពីខេត្តហ្នឹង មានស្ថានភាពយ៉ាងម៉េចដែរ? តើពួកគាត់មានការភិតភ័យ? ហើយតើរបស់ទ្រព្យរបស់ពួកគាត់ហ្នឹងយ៉ាងម៉េច ពេលនោះ?

**ឆ៖** ពេលនោះគឺប្រជាជនចេះតែសួរដែរ សួរខ្ញុំថា "ចុះទ្រព្យសម្បត្តិនៅក្នុងក្រុង នៅក្នុងផ្ទះគេមួយៗ តើគេឲ្យវិញដែរអត់?" គេសួរអ៊ីចឹង។ ឯចំណែកខ្ញុំ ខ្ញុំតូចតាចដែលទេ ខ្ញុំអត់បានដឹងទេ ព្រោះហ្នឹងតាមអង្គការកំណត់ ខ្ញុំអត់បានដឹង ទាល់តែចាំមើលអង្គការគេមានបទបញ្ជាអីតទៅទៀត។ ឯទឹកមុខប្រជាជនដែលចេញទៅហ្នឹងក៏មិនបានឮថាកើតទុក្ខអីណាអីទេ អត់ដែលទេ ខ្ញុំឃើញតែទឹកមុខសប្បាយអាងថាទ្រព្យសម្បត្តិនៅផ្ទះ កន្លែងគេ ខ្ញុំក៏មិនបានដឹងដែរ។

[១៥:៤០:៥៥]

**ស៖** តើប្រជាជនទាំងអស់ហ្នឹងនៅពេលដែលគេប្រាប់ឲ្យចេញពីខេត្តពោធិ៍សាត់ហ្នឹង គាត់មាន

សិទ្ធិអាចយកទ្រព្យទៅតាមខ្លួន ឬក៏មានបញ្ហាយ៉ាងម៉េចដែរពាក់ព័ន្ធនឹងទ្រព្យសម្បត្តិរបស់ប្រជាជន?

**ឆ៖** តាមបទបញ្ជាដែលឮថាមិនឲ្យយករបស់របរណាធ្ងន់ យកមិនរួច បើគ្រាន់តែថាមួយវេចស្ពាយ ដូចជាប្រាក់ លុយកាក់អីអាចយកបានតែប៉ុណ្ណឹង សម្ភារៈស្លៀកពាក់ កូនចៅ តែរបស់ធំៗដូចអត់មានឃើញបានយកអីទៅផង។

**ស៖** តើនៅក្នុងអំឡុងពេលដែលជម្លៀសហ្នឹង មានការប្រកាសបែងចែកប្រជាជនស៊ីវិលត្រូវទៅផ្សេង ឬក៏ទាហាន លន់ នល់ ត្រូវទៅផ្សេង ឬក៏មានបទបញ្ជាកំណត់ពាក់ព័ន្ធនឹងការបែងចែកប្រភេទមនុស្សទាំងអស់ហ្នឹងដែរឬទេ?

**ឆ៖** បាទ បើតាមដូចសេចក្ដីប្រកាសនឹងមីក្រូគេ គឺគេអត់មានរើសអើងថា ទាហានទៅផ្សេង ស៊ីវិលទៅផ្សេងទេ។ បងប្អូនណា ប្រពន្ធប្ដីទៅតាមណាទៅតាមហ្នឹងរៀងៗខ្លួន ខេត្តជិតតាមជិត ឆ្ងាយតាមឆ្ងាយ គឺមិនបានអ្នកណាទាក់ ឬក៏បង្ខំចិត្តអីទាំងអស់។ គឺគេប្រកាសអ៊ីចឹង ខ្ញុំក៏នៅស្ដាប់តែកន្លែងយាមហ្នឹងដែរ។

[១៥:៤២:៤៨]

**ស៖** ចុះលោកមានបានដឹងទេថា នៅពេលដែលជម្លៀសហ្នឹង មានការសួរទេថាប្រជាជនត្រូវចេញទៅច្រកណា? ហើយប្រជាជនហ្នឹងជាប្រជាជនស៊ីវិល ឬក៏ជាប្រជាជន ឬក៏ទាហាន លន់ នល់ដែរទេ តាមច្រកនីមួយៗ?

**ឆ៖** តាមដែលខ្ញុំបានដឹងហើយសម្គាល់ឃើញនៅដងផ្លូវធំហ្នឹង ដែលខ្ញុំនៅជាប់សាលាទៅ ផ្លូវវាធំដែរ។ ថាឃើញតែប្រជាជនមូលមីមក មិនបានដឹងថាអ្នកណាជាទាហាន អ្នកណាជាស៊ីវិលទេ គឺបាត់ខោអាវជាឯកសណ្ឋានជាទាហានអស់ សុទ្ធស៊ីវិលទាំងអស់។ អ្នកណាមានម៉ូតូក៏ជិះម៉ូតូ អ្នកណាអីមានរ៉ឺម៉ក ស៊ីក្លូអីក៏ទៅតាមខឹបខេអ៊ីចឹងទៅ វាអត់មានឃើញថា ដឹងតែទាហានផ្សេង ស៊ីវិលផ្សេងអត់ដឹងដែរមើលអត់បានសម្គាល់ដឹង។

[១៥:៤៣:៥៧]

**ស៖** លោកសាក្សីនៅក្នុងចម្លើយដែលលោកបានផ្ដល់ឲ្យអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតត្រង់ឯកសារ D125/176។ ត្រង់សំណួរចម្លើយលេខ២ គឺទី២ បន្ទាប់ពីខ្ញុំបានអានមុននេះ។ អ្នកស៊ើបអង្កេតបានសួរលោកថា "ក្រោយរំដោះខេត្តពោធិ៍សាត់ ថ្ងៃទី១៩ ខែមេសា ឆ្នាំ១៩៧៥ តើលោកបានធ្វើអ្វីខ្លះ នៅឯណា?"។ ខ្ញុំសូមដកស្រង់ "មុននឹងគេបញ្ជូនខ្ញុំទៅមោង ប្រហែលជាអំឡុង

រើផ្សាររួច១០ថ្ងៃ គេបានប្រមូលទាហាន លន់ នល់ មកដាក់នៅសាលាខេត្ត។ កងរបស់ខ្ញុំមិនបានទៅប្រមូលទាហាន លន់ នល់ ពីតាមស្រុកមកទេ គឺគេកងខ្ញុំនៅយាមជុំវិញសាលាខេត្ត ហើយខ្ញុំផ្ទាល់ជាអ្នកយាមនៅមាត់ទ្វារសាលាខេត្ត"។ សំណួរដែលខ្ញុំចង់សួរលោកជាបន្ត ចង់សួរថាមានប្រមូលទាហាន លន់ នល់ មកដាក់នៅសាលាខេត្ត។ តើទាហាន លន់ នល់ ទាំងអស់នោះប្រមូលមកពីកន្លែងណា?

[១៥:៤៥:២១]

**ឆះ** ត្រង់ហ្នឹង គឺខ្ញុំពុំបានដឹងច្បាស់ថាមកពីខាងទេ ព្រោះតួនាទីខ្ញុំ គ្រាន់តែយាមនៅហ្នឹង ស្រាប់តែឃើញឡានចូលមក មិនដឹងជា -- អត់មានសម្លៀកបំពាក់ឯកសារសណ្ឋាន ឬបុណ្យសក្តិអីទេ គឺមានតែឡាន ហើយនិងមកច្រើនគ្នា តែខ្ញុំមិនដឹងថាទាហាន -- ដល់អ្នកស៊ើបអង្កេតសួរទៅថា ហ្នឹងជាទាហាន១ ប្រហែលជាទាហាន ព្រោះអត់មានខោអាវទាហានទេ គឺមកច្រើន។ តែដូចថាមានដូចបងប្អូនសាច់សាលោហិតខ្ញុំ គេនៅជិតហ្នឹងដែរ ខ្លះស៊ីវិល ខ្លះអីក៏មកហ្នឹងដែរ។ អ៊ីចឹងគេឡើងទៅប្រជុំ ហើយខ្ញុំនៅយាមមាត់ទ្វារហ្នឹង។ ប្រជុំរយៈពេលយូរដែរ តាំងពីព្រឹករហូតដល់ប្រហែលជាពីរបីម៉ោងទៅមិនដឹងទេ ខ្ញុំក៏ភ្លេចខ្លះទៅដែរហ្នឹង វាមិនសូវចាំអស់ទេ វាយូរហើយដែរ មិនចាប់អារម្មណ៍ថា -- ស្រាប់ដល់ពេលនោះទៅក៏គេមានបទបញ្ជា ខ្ញុំនៅតែហ្នឹងទេ គេបញ្ជាការធំៗគេឲ្យឡើងឡានទៅរៀន។ គេថាទៅរៀន ខ្ញុំចាំបានច្បាស់តែប៉ុណ្ណឹង។ ថាទៅរៀននៅខាងដងទន្លេសាបឯណោះ។ ទៅជាប់ហ្នឹងនៅទួលពោធិ៍ជ្រៃហ្នឹង គឺនៅជាប់ទន្លេសាបហ្នឹង។ ហើយខ្ញុំក៏ពុំបាន បានដឹងថាដេញដោលពីរឿងអីទេ ព្រោះថាទៅរៀន ទៅចប់ហើយ មុនតែទៅរៀន ហ្នឹងរៀន។ ប៉ុន្តែឮដូចថាជាការគេនៅជិតខ្ញុំហ្នឹង គេថាទៅរៀនអ្នកណាឡើងបុណ្យស័ក្តិអី គេឲ្យធ្វើការហ្នឹងវិញ។ ម្ល៉ោះហើយក៏អ្នកស៊ីវិលក៏ឡើងទៅរៀន អ្នកណាក៏រៀន ខ្ញុំក៏មិនបានចំណាប់អារម្មណ៍ដែរ។ ខ្ញុំដឹងតែប៉ុណ្ណឹង។

[១៥:៤៧:០៤]

**សះ** ចុះនៅពេលដែលគេប្រាប់ទាហាន លន់ នល់ ដែលចេញពីប្រជុំហ្នឹងថាទៅរៀនហ្នឹង តើលោកដឹងទេថា ទាហាន លន់ នល់ ហ្នឹងទៅរៀន ទៅកន្លែងណា? ហើយធ្វើយ៉ាងម៉េចដើម្បីអាចធ្វើដំណើរទៅរៀនដល់កន្លែងហ្នឹងបាន?

**ឆះ** បាទ ពេលនោះ គឺដែលគេហៅមកជួបជុំនៅហ្នឹង ឃើញមួយចំនួនធំឡាន មានឡានតូចឡានធំអីហ្នឹង គឺគេឲ្យជិះឡានរបស់ខ្លួនហ្នឹងទៅ។ ហើយទៅហ្នឹងគឺផ្លូវឆ្ងាយ គឺថាអ៊ីចឹង ជិះឡានទៅ តែខ្លះក៏មានឡានខ្លួនឯង ខ្លះក៏ឡើងជិះឡានជាមួយគេទៅ ខ្ញុំក៏ឈរមើលគេហ្នឹងទៅ។ ហើយគេឡើងឡាន

ទៅបាត់ៗទៅ។ មានទាហានគេ អ្នកទាហានអង្គភាពគេផ្សេងៗ គេបើកអមទៅជាមួយទៅ ក៏ខ្ញុំផ្សេងនៅហ្នឹង។ ខ្ញុំអត់ដឹងរឿង ដឹងតែប៉ុណ្ណឹង។

**ស៖** លោកថាទាហាន លន់ នល់ ដែលចុះពីអង្គប្រជុំហ្នឹង គឺចាប់ផ្ដើមឡើងឡាន ហើយធ្វើដំណើរទៅ។ តើលោកមានបានដឹងទេថា គេធ្វើដំណើរទៅណា ហើយអ្នកដែលធ្វើដំណើរដែលជាទាហាន លន់ នល់ ហ្នឹងលោកចាំបានទេ ប្រហែលជាមានមនុស្សប៉ុន្មាននាក់?

[១៥:៤៨:៥០]

**ឆ៖** តាមដែលខ្ញុំបាទនៅកន្លែងហ្នឹង គឺទៅច្រើន។ ចេញទៅច្រើនៗឡានណាស់។ រយៈពេលប្រហែលជា១ម៉ោងទៅ១ម៉ោង -- ទៅ២ម៉ោងណោះ ថា២ម៉ោងអ៊ីចឹងចុះ ព្រោះខ្ញុំគ្មាននាឡិកាគ្មានអីទេសម័យហ្នឹង។ អត់ដឹងដែរ តែចេញនោះ ថាទៅរៀនៗ ហើយខ្ញុំក៏នឹកឃើញថា គេសន្តិភាពហើយប្រហែលជាគេទៅរៀនអី បំពាក់បុណ្យស័ក្តិអីហ្នឹងដែរហ្នឹង ក៏ខ្ញុំកូនទាហាន មិនបានចំណាប់អារម្មណ៍អីខ្លាំងទៅអ៊ីចឹងទេ។

**ស៖** ខ្ញុំនឹងសួរលោកលម្អិតពាក់ព័ន្ធទៅនឹងបញ្ហានេះទៀត។ ប៉ុន្តែមុននេះលោកបានប្រាប់ថាមានឡើងឡានហ្នឹង ឡានហ្នឹងមានឡានតូច ឡានធំ ឡានផ្ទាល់ខ្លួន។ ហើយចង់សួរលោកថា លោកចាំទេថា ឡានហ្នឹងជាឡានប្រភេទអីគេខ្លះដែរ? ហើយក្រៅពីឡានផ្ទាល់ខ្លួន តើឡានហ្នឹងវាមានឡានរបស់ទាហានខ្មែរក្រហមទេ ពេលនោះ?

[១៥:៤៩:៥៨]

**ឆ៖** ខ្ញុំបាទអត់បានស្គាល់ថាឡានខ្មែរក្រហមយ៉ាងម៉េច ឡានទាហានម៉េចទេ ឃើញតែឡានសម័យហ្នឹង ខ្ញុំអាយុវានៅតិចដែរ។ ខ្ញុំឃើញតែឡានស ឡានខ្មៅ ឡានអីអ៊ីចឹង អាឡាតាក់ស៊ីយើងផងហើយអាឡាន ដូចថាដឹកពីប្អូនដប់ម្ភៃនាក់អីហ្នឹង។ អាឡានតូចហ្នឹងវាច្រើន។ ហើយឡានខ្មែរក្រហមហ្នឹង ដឹកអាឡានទាហានហ្នឹងដែរ អាឡានចំណាំដឹកទាហាន លន់ នល់ ដែរហ្នឹង វា -- ខ្ញុំគ្រាន់ មិនដឹងជាឡានខ្មែរក្រហមម៉េច? ទាហានម៉េចទេ? ខ្ញុំអត់បានស្គាល់។

**ស៖** ហើយមានទាហានលន់ នល់ ប៉ុន្មាននាក់នៅពេលដែលចេញពីអង្គប្រជុំហ្នឹង ឡើងឡានទៅហ្នឹង?

**ឆ៖** បាទ ខ្ញុំមិនបានចាំ ព្រោះខ្ញុំអត់បានបញ្ជីម្រយអីទេ។ គេឲ្យឈរតែយាមដូចតោអ៊ីចឹង មិនដឹងជាឡើង -- ទៅជាច្រើន។ មិនឮខ្ញុំថា១ម៉ោងជាង ប្រហែលជា២ម៉ោងឯណោះ។ ខ្ញុំចេះតែឡើងទៅ

ខ្ញុំចេះតែឈរតែមើលគេទៅ។ មិនដឹងជាប៉ុន្មានអីប៉ុន្មាន មិនដឹងទាហាន។ បើឯកសណ្ឋាន គ្មានឯកសណ្ឋានទាហានផង ស៊ីវិល ដៃវែង ដៃខ្លីអីអ៊ីចឹង។ ខ្ញុំអត់ចំណាប់អារម្មណ៍ថា សម្គាល់ថាទាហាន លន់ នល់នោះប៉ុន្មាន? ហើយស៊ីវិលនោះប៉ុន្មាន? អត់ដឹងដែរ។

[១៥:៥១:៣២]

**ស៖** លោកសាក្សីនៅក្នុងចម្លើយរបស់លោកជាមួយនឹងសហចៅក្រមស៊ើបអង្កេតត្រង់ឯកសារដដែល ប៉ុន្តែនៅសំណួរទី៣ គឺចុះក្រោមបន្តិចនៅពេលដែលខ្ញុំ មុននឹងខ្ញុំដកស្រង់នេះ នៅត្រង់សំណួរទី៣ ដែលសួរថា "ពេលដែលគេចាត់តាំងលោកឲ្យឈរយាមនៅជុំវិញសាលាខេត្ត តើលោកបានឃើញទាហានលន់ នល់ ប្រហែលប៉ុន្មាននាក់?" ចម្លើយរបស់លោក ដកស្រង់ "បើតាមការប៉ាន់ស្មានរបស់ខ្ញុំមានទាហានលន់ នល់ ចូលរួមប្រជុំប្រហែល២០០នាក់ ព្រោះវាណែនពេញសាលាខេត្ត" បញ្ចប់ការដកស្រង់។ លោកបានឆ្លើយប្រាប់អ្នកស៊ើបអង្កេតថា បើតាមការស្មានរបស់លោក មានទាហានលន់ នល់ចូលប្រជុំប្រហែលជា២០០នាក់។ ហេតុអ្វីបានជាពេលនោះលោកស្មានថាមានមនុស្សចូលរួមប្រហែលជា២០០នាក់?

**ឆ៖** បាទ នៅពេលនោះគឺថា គាត់ដែលសាកសួរខ្ញុំទៅ ខ្ញុំក៏ប៉ាន់ស្មានទំហំកន្លែងសាលាខេត្តប្រជុំហ្នឹង ប្រហែលចំណុះមនុស្សប្រហែលជាប៉ុណ្ណឹង។ ខ្ញុំក៏ថាប៉ុណ្ណឹងដែរទៅ ព្រោះកន្លែងហ្នឹងវាប៉ុណ្ណឹង ប៉ាន់ស្មានហ្នឹងទៅ។

**ស៖** អ៊ីចឹងតើខ្ញុំយល់ជាការត្រឹមត្រូវទេថា ប្រហែល២០០នាក់នេះ ដោយសារតែលោកស្មានចំណុះមនុស្សដែលអាចដាក់បាននៅក្នុងសាលាខេត្ត ឬក៏សាលាដែលគេធ្វើអង្គប្រជុំហ្នឹង។ តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ ហ្នឹងប៉ាន់ស្មានទៅតាមទីធ្លា និងកន្លែងហ្នឹង។

[១៥:៥៣:២៥]

**ស៖** ចុះនៅក្នុងចំណោមមនុស្សដែលចូលរួមប្រជុំនៅសាលាខេត្តហ្នឹង នៅពេលដែលចេញមកវិញ នៅពេលដែលលោកឈរយាមនៅសាលាខេត្តហ្នឹង លោកមានបានដឹងថា ឬក៏ស្គាល់ថាមានអ្នកណាម្នាក់នៅក្នុងអង្គប្រជុំៗ ដែលចុះមកហ្នឹង? ស្គាល់ឈ្មោះ ឬក៏ស្គាល់អត្តសញ្ញាណរបស់គាត់ទេ?

**ឆ៖** ហ្នឹងខ្ញុំ -- អ្នកដែលប្រជុំ ឬក៏អ្នកអត្តសញ្ញាណបណ្ណជាទាហាន?

**ស៖** នាងខ្ញុំនឹងសួរសំណួរលោកម្តងទៀត។ នៅក្នុងអង្គប្រជុំដែលមានទាហាន លន់ នល់ ចូល

រួមប្រជុំនៅសាលាខេត្តនៅថ្ងៃនោះ។ តើនៅពេលដែលមនុស្សចេញពីប្រជុំមកវិញនោះ លោកមានស្គាល់អ្នកដែលចូលរួមប្រជុំហ្នឹងថាមានអ្នកណាម្នាក់ ឬក៏មួយចំនួនដែលលោកស្គាល់ឈ្មោះដែរឬទេ?

**ឆ៖** ខ្ញុំបាទ អត់បានស្គាល់ទេ ព្រោះខ្ញុំជាទាហានមួយដែរ តែខ្ញុំទាហាននៅជាយក្រុង អត់ស្គាល់គេទាហានអ្នក លន់ នល់ ហ្នឹង អ្នកណាមុខម៉េច ហើយឈ្មោះអី ក៏ខ្ញុំបានស្គាល់។ ពុំដែលបាន ខ្ញុំនៅតែស្រុកស្រែ អត់ស្គាល់គេអ្នកណា អាចសម្គាល់បាន សុទ្ធអ្នកផ្សេងៗ។

**ស៖** ចាស អរគុណលោកសាក្សី។ នៅក្នុងចម្លើយដែលលោកបានផ្ដល់ឲ្យអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេត ត្រង់ឯកសារដដែល ប៉ុន្តែចុះមកត្រង់សំណួរចម្លើយលេខ៥។ នៅពេលដែលគេសួរលោកថា “តើលោកស្គាល់ទាហានលន់ នល់ ទេ?” ចម្លើយដកស្រង់ “ខ្ញុំស្គាល់លោក ប៉ុល ជាទាហាន ជានាយទាហានលន់ នល់ កាន់វរសេនាធំ នៅបន្ទាយទួលពោធិ៍ជ្រៃ ក៏មកប្រជុំនិងឡើងជិះឡានទៅជាមួយគ្នាដែរ” បញ្ចប់ការដកស្រង់។ ខ្ញុំចង់ដឹងថា តើលោកស្គាល់ ប៉ុល ហ្នឹងនៅពេលណា?

[១៥:៥៦:១៥]

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយតបសាក្សី! សូមអញ្ជើញលោកមេធាវីជាតិការពារក្ដីលោក ខៀវ សំផន!

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។

ខ្ញុំបាទគ្រាន់តែជួយកែតម្រូវតូចមួយទេ។ ក្នុងកំណត់ហេតុរបស់លោកសាក្សីនេះ គឺមិនមែនឈ្មោះ ប៉ុល ទេ គឺឈ្មោះ ប៊ុល។ បាទ សូមតំណាងសហព្រះរាជអាជ្ញាពិនិត្យ។ សូមអរគុណ។

**កញ្ញា សុង ឆវ័ន្ត៖**

ចាស សូមអរគុណ។

**សួរដោយកញ្ញា សុង ឆវ័ន្ត៖**

**ស៖** តើឈ្មោះហ្នឹងជាឈ្មោះ ប៊ុល ឬក៏ឈ្មោះ ប៉ុល សូមលោកជួយបញ្ជាក់? ហើយលោកស្គាល់គាត់នៅពេលណា?

**លោក អ៊ុំង ឆាត់៖**

**ឆ៖** គឺឈ្មោះ ប៊ុល ហើយស្គាល់ហ្នឹង គឺគាត់នៅបន្ទាយហ្នឹង គឺបន្ទាយនៅក្បែរភូមិខ្ញុំ ខ្ញុំស្គាល់

តាំងពីខ្ញុំនៅបួស។ បួសហ្នឹង នៅបួសហ្នឹង គាត់ទៅវត្ត ស្គាល់គាត់បញ្ហាការអីទេ ធំជាងគេនៅបន្ទាយហ្នឹង។ ប៉ុន្តែគេអ្នកស្គាល់ខាងទាហានលន់ នល់ បានដឹងថា អីធំជាងគេហ្នឹង បាត់ទីយ៉ុង ក៏មិនដឹងអីមិនដឹង ខ្ញុំមិនសួរ។

**ស៖** តើលោកធ្លាប់បានឧស្សាហ៍ជួបឈ្មោះ ប៉ិល ហ្នឹងទេ ពីមុនមក មុនថ្ងៃដែលគេចូលរួមប្រជុំនៅពោធិ៍សាត់ហ្នឹង នៅសាលាខេត្តពោធិ៍សាត់?

[១៥:៥៨:១០]

**ឆ៖** អត់ ខ្ញុំអត់បាន ដែលបានជួបគាត់ទេ ព្រោះខ្ញុំឡើងមកផ្លូវខុសគ្នា គាត់ជាទាហានឯណេះទៅ គេឡើងមកមុន គាត់មិនជាចូលទៅច្រកណា មកប្រជុំ ឡើងឡានទៅជាមួយគេដែរ ហ្នឹងឮតាមដំណឹងដែលអ្នកដែលរស់ៗទេ ថាលោក ប៉ិល ត្រូវងាប់នៅហ្នឹងដែរ តែប៉ុណ្ណឹង ខ្ញុំដឹង ចាំច្បាស់តែប៉ុណ្ណឹងថាទៅងាប់នៅហ្នឹងដែរ។

**ស៖** ទាក់ទងទៅនឹងទាហាន លន់ នល់ ដែលចេញពីកិច្ចប្រជុំមួយនៅសាលាខេត្តពោធិ៍សាត់នៅថ្ងៃនោះ លោកថាមានទាហានលន់ នល់ បានឡើងឡាន បានឡើងជិះឡាន មានឡានធំឡានតូច ហើយថាទៅរៀន។ តើលោកដឹងទេ ក្រោយមកមានអ្វីបានកើតឡើងជាមួយទាហានលន់ នល់ អស់ទាំងនោះ?

**ឆ៖** ពេលនោះគេទៅរៀន រៀនហើយ ស្រាប់តែបាត់អស់ទៅ អត់ឃើញមកវិញ ឃើញតែឡានទទេមកវិញ។ ឡានមកដល់ខេត្តហ្នឹង ឃើញតែឡានទទេៗមកវិញទៅ ឃើញតែទាហានខ្មែរក្រហមហ្នឹងក៏មកដែរទៅ។ ខ្ញុំមិនដឹងថាគេនៅរៀនឯណាឯណី។

[១៥:៥៩:៥៧]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ពេលវេលាដល់សម្រាកហើយនៅរសៀលនេះ ហើយអង្គជំនុំជម្រះក៏សូមរំឭកនិងជម្រាបជូនភាគីតំណាងសហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីផងដែរ ក្នុងការតាំងសំណួរដេញដោលសាក្សីនេះគឺភាគីទាំងពីរនេះគឺមានកន្លះថ្ងៃ គឺពីរវគ្គនៃថ្ងៃសវនាការ។ អ៊ីចឹងអំមិញអស់មួយវគ្គហើយ អ៊ីចឹងនៅស្អែកហ្នឹងភាគីទាំងនៅតែមួយវគ្គពេលព្រឹកទៀតប៉ុណ្ណោះ សូមជ្រាប។

កិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ សវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែក ថ្ងៃអង្គារទី៣០ ខែ

មេសា ឆ្នាំ២០១៣ ចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក។ ហើយសវនាការនៅថ្ងៃស្អែកនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការបន្តស្តាប់សក្ខីកម្ម អ៊ុង ឆាត់ ដែលនឹងសួរដេញដោលដោយតំណាងសហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីមួយវគ្គសវនាការនៅពេលព្រឹក ហើយនិងសួរបន្តបញ្ចប់ដោយក្រុមមេធាវីការពារក្តីទាំងពីរក្រុម។ សូមភាគី និងសាធារណជនជ្រាប។

[១៦:០១:០៣]

លោក អ៊ុង ឆាត់ ការស្តាប់សក្ខីកម្មរបស់លោកនៅមិនទាន់ចប់នៅឡើយទេ អង្គជំនុំជម្រះនឹងធ្វើសវនាការបន្តស្តាប់សក្ខីកម្មរបស់លោកនៅថ្ងៃស្អែកទៀត។ ដូច្នេះ អង្គជំនុំជម្រះកោះអញ្ជើញលោកមកបន្តផ្តល់សក្ខីកម្មនៅថ្ងៃស្អែកទៀត ដែលនឹងចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងមន្ត្រីនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនលោក អ៊ុង ឆាត់ វិលត្រឡប់ទៅកាន់ដែលគាត់ស្នាក់នៅវិញ ហើយនិងឲ្យនាំគាត់ត្រឡប់មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញ នៅថ្ងៃស្អែកនៅវេលាម៉ោងបួនព្រឹក។ ហើយមេធាវីប្រឹក្សាសាក្សី សូមអញ្ជើញចូលរួមសវនាការដូចគ្នានឹងសាក្សី អ៊ុង ឆាត់ ដែរ។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីររូប គឺលោក ខៀវ សំផន និងលោក នួន ជា វិលត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃអ.វ.ត.ក វិញចុះ ហើយនិងឲ្យនាំខ្លួនគាត់ត្រឡប់មកកាន់បន្ទប់សវនាការ ដើម្បីចូលរួមសវនាការនេះវិញនៅព្រឹកថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួន។ ដោយឡែកលោក នួន ជា បង្គាប់ឲ្យនាំខ្លួនគាត់មកត្រឹមបន្ទប់ឃុំខ្លួនមួយនៅក្រោមសាលសវនាការនេះ ដែលមានរៀបចំនូវឧបករណ៍សោតទស្សន៍សម្រាប់គាត់អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការតាមប្រព័ន្ធសោតទស្សន៍។

សម្រាកចុះ៕

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១៦:០២ នាទី)*